ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី

បូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាខេត្ត

ឆ្នាំសិក្សាឆ្នាំ២០២៣-២០២៤

និងទិសដៅសម្រាប់ឆ្នាំសិក្សា២០២៤-២០២៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តមណ្ឌលគិរី
មន្ទីរអប់រំ យុវជន និងកីឡា

សន្ធិបាត
ឯកសរុបទាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡា
ឆ្នាំសិក្សា ២០២៣-២០២៤
និងលើកទិសដៅការងារសម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥

ខែ មករា ឆ្នាំ២០២៥

មាតិកា	**ទំព័រ**
១.សេចក្តីផ្តើម	**១**
២.វឌ្ឍនភាព	១
២.១ លទ្ធផលរួមរបស់វិស័យអប់រំ យុវជន និងកីឡា	១
២.១.១ វឌ្ឍនភាពនៃការផ្តល់សេវាអប់រំ យុវជន និងកីឡា	២
២.១.១.១ ផ្នែកបរិមាណវិស័យ	២
២.១.១.២ ផ្នែកគុណវិស័យ	៦
២.១.២ វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល (MTR_PESP)	១០
២.១.៣ វឌ្ឍនភាព នៃការអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា	១១
២.១.៣.១ វឌ្ឍនភាពនៃការអនុវត្តស្តង់ដាសាលារៀនគំរូ	១៥
២.១.៣.១.១ វឌ្ឍនភាពនៃការពង្រឹងអភិបាលកិច្ចសាលារៀន	១៦
២.១.៣.១.២ វឌ្ឍនភាពនៃការអនុវត្តការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សា ឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស	១៧
២.១.៣.១.៣ វឌ្ឍនភាពនៃការអនុវត្តការយកចិត្តទុកដាក់លើសុខភាពរបស់សិស្សតាមរយៈ កម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា	១៧
២.១.៣.១.៤ ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាលនិងសហគមន៍ ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូរដ្ឋ និងសហគមន៍ ដើម្បីការអប់រំ	១៨
២.១.៣.២ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់សាលារៀន	១៩
២.១.៣.៣ ការអប់រំឌីជីថល	១៩
២.១.៣.៤ ការអភិវឌ្ឍយុវជន	២០
២.១.៣.៥ ការអភិវឌ្ឍអប់រំកាយ និងកីឡា	២១
២.១.៣.២ ការកសាងប្រព័ន្ធ និងអភិវឌ្ឍសមត្ថភាព	២១
២.១.៤ វឌ្ឍនភាពនៃការគ្រប់គ្រង និងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ	២២
២.១.៤.១ វឌ្ឍនភាព នៃការអនុវត្តផែនការ ស្ថិតិ និងការពិនិត្យតាមដានវាយតម្លៃ	២២
២.១.៤.២ វឌ្ឍនភាព នៃការអនុវត្តហិរញ្ញប្បទានសហប្រតិបត្តិការ	២២
២.១.៤.៣ វឌ្ឍនភាព នៃការអនុវត្តកំណែទម្រង់រឹមជ្ឈការ និងវិសហមជ្ឈការ	២៣
២.១.៤.៤ វឌ្ឍនភាព នៃការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ	២៣
២.១.៤.៥ វឌ្ឍនភាព នៃការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ	២៤
២.១.៤.៦ វឌ្ឍនភាព នៃការអនុវត្តហេដ្ឋារចនាសម្ព័ន្ធ	២៤
២.១.៤.៧ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤	២៤
២.១.៤.៨ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា២០២៣-២០២៤	២៧
២.២ លទ្ធផលតាមអនុវិស័យ	២៨

២.២.១ អនុវិស័យការអប់រំកុមារតូច	២៨
២.២.២. អនុវិស័យការអប់រំបឋមសិក្សា	៣៣
២.២.៣ ការអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស	៣៦
២.២.៤ អនុវិស័យការអប់រំក្រៅប្រព័ន្ធ	៤៥
២.២.៥ អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា	៥១
២.២.៦ ការអភិវឌ្ឍយុវជន	៥៣
៣. បញ្ហាប្រឈម	៥៥
៣.១ តាមអនុវិស័យ	៥៥
៣.១.១ អនុវិស័យការអប់រំកុមារតូច	៥៥
៣.១.២. អនុវិស័យការអប់រំបឋមសិក្សា	៥៦
៣.១.៣ អនុវិស័យការអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស	៥៦
៣.១.៤ អនុវិស័យការអប់រំក្រៅប្រព័ន្ធ	៥៧
៣.១.៥ អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា	៥៨
៣.១.៦ អនុវិស័យការអភិវឌ្ឍយុវជន	៥៨
៣.២ ឆ្លងអនុវិស័យ	៥៨
៣.២.១ ការិយាល័យសុខភាពសិក្សា	៥៨
៣.២.២ ការិយាល័យរដ្ឋបាល .បុគ្គលិក និងបណ្តុះបណ្តាល	៥៩
៣.២.៣ ការិយាល័យគណនេយ្យ សម្ភារ និងទ្រព្យសម្បត្តិរដ្ឋ	៥៩
៣.២.៤ ការិយាល័យផែនការ និងគ្រប់គ្រងជំនួយ	៦០
៣.២.៥ ការិយាល័យអធិការកិច្ច	៦០
៤.ទិសដៅការងារឆ្នាំសិក្សា២០២៣-២០២៤	៦០
៤.១ ទិសដៅតាមអនុវិស័យ	៦០
៤.១.១ អនុវិស័យការអប់រំកុមារតូច	៦០
៤.១.២.អនុវិស័យការអប់រំបឋមសិក្សា	៦១
៤.១.៣ អនុវិស័យការអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស	៦២
៤.១.៤ អនុវិស័យការអប់រំក្រៅប្រព័ន្ធ	៦៣
៤.១.៥ អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា	៦៣
៤.១.៦ អនុវិស័យការអភិវឌ្ឍយុវជន	៦៤
៤.២ ទិសដៅឆ្លងអនុវិស័យ	៦៤
៤.២.១ ការិយាល័យសុខភាពសិក្សា	៦៤
៤.២.២ ការិយាល័យរដ្ឋបាល បុគ្គលិក និងបណ្តុះបណ្តាល	៦៥
៤.២.៣ ការិយាល័យគណនេយ្យ សម្ភារ និងទ្រព្យសម្បត្តិរដ្ឋ	៦៥
៤.២.៤ ការិយាល័យផែនការ និងគ្រប់គ្រងជំនួយ	៦៦

៤.២.៥ ការិយាល័យអធិការកិច្ច	៦៨
៥.សេចក្តីសន្និដ្ឋាន	៦៨
តារាងឧបសម្ព័ន្ធ	
ឧបសម្ព័ន្ធទី១៖ វឌ្ឍនភាពនៃការសម្រេចបានចំណុចដៅនៃសូចនាករស្នូល	៦៩
ឧបសម្ព័ន្ធទី២៖វឌ្ឍនភាពនៃការសម្រេចបានចំណុចដៅនៃសូចនាករអនុវិស័យ	៧០
ឧបសម្ព័ន្ធទី៣៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤	៨០
ឧបសម្ព័ន្ធទី៤៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំសិក្សា២០២៣-២០២៤	៨៤
ឧបសម្ព័ន្ធទី៥៖ ប្រធានបទពិភាក្សា	៨៩

១-សេចក្តីផ្តើម

មន្ទីរអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ ឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ និងក្របខណ្ឌការអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា ដោយឈរលើគោលការណ៍ « **ធានាឱ្យពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត**» ដោយផ្សារភ្ជាប់គ្នារវាងការ កសាងផែនការ ការពិនិត្យតាមដាន និងវាយតម្លៃរបស់វិស័យតាមរយៈក្របខណ្ឌលទ្ធផលអនុវិស័យ ដែលបន្សឹគ្នារវាងគោលនយោបាយ និងលទ្ធផលនៅថ្នាក់ជាតិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងការពង្រីក និងលើកកម្ពស់គុណភាពសេវាអប់រំ ។ជាពិសេសឆ្លើយតបទៅនឹងអាទិភាពកំណែទម្រង់បរិវត្តកម្មអប់រំនៅកម្ពុជា ដើម្បីរួមចំណែកសម្រេចឱ្យបាននូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** ដើម្បីកំណើន **ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** ដោយបន្តផ្តោតជាសំខាន់លើ " **ប្រសិទ្ធភាពសមិទ្ធកម្ម** " ទន្ទឹមនឹងនេះយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាល ទី១ កំណត់យកអាទិភាពគន្លឹះ ៥គឺ: " **មនុស្ស ផ្លូវ ទឹក ភ្លើង និង បច្ចេកវិទ្យា** " ជាពិសេស " **បច្ចេកវិទ្យាឌីជីថល** " សម្រាប់ឆ្លើយតបនឹងបដិវត្តឧស្សាហកម្ម៤.០ និងបរិវត្តកម្មឌីជីថល នៃសេដ្ឋកិច្ច និងសង្គមកម្ពុជា ព្រមទាំងតម្រូវការក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ដែលជាគន្លឹះ និងមធ្យោបាយ ដ៏សំខាន់ នៃការ**សម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០** ។

សន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០២៣-២០២៤ និងទិសដៅការងារឆ្នាំសិក្សា២០២៤-២០២៥ នឹងផ្តល់កាលានុវត្តភាពសម្រាប់បុគ្គលិកអប់រំនៅថ្នាក់ក្រុង ស្រុក និងសាលារៀន គ្រប់កម្រិតសិក្សាទាំងអស់ មន្ទីរ ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងដៃគូអភិវឌ្ឍ បានជួបពិភាក្សាពីការបំពេញការងារ ការកំណត់បញ្ហាប្រឈមទៅនឹងវិស័យជាក់លាក់សម្រាប់ឆ្នាំខាងមុខ និងឯកភាពលើសកម្មភាពចាំបាច់មួយចំនួន ។ លទ្ធផលសន្និបាតអប់រំ នឹងផ្តល់ជាធាតុចូលសម្រាប់កែលម្អផែនការយុទ្ធសាស្ត្រវិស័យអប់រំ បង្កើនប្រសិទ្ធភាព ភាពស័ក្តិសិទ្ធនៃយន្តការពិនិត្យតាមដាននិងវាយតម្លៃរបស់ប្រព័ន្ធអប់រំ និងជាធាតុចូលដ៏មានសារៈសំខាន់សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៦ ទាំងថ្នាក់ខេត្ត និងនៅថ្នាក់ក្រុង ស្រុក និងសាលារៀន។

២-ទស្សនភាពការងារ

២.១-លទ្ធផលរួមរបស់វិស័យអប់រំ យុវជន និងកីឡា

ដោយមានការខិតខំប្រឹងប្រែងយកអស់ពីកម្លាំងកាយ កម្លាំងចិត្ត និងស្មារតីទទួលខុសត្រូវខ្ពស់ របស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ អាជ្ញាធរដែនដី ដៃគូអភិវឌ្ឍក្នុងវិស័យអប់រំ និងសប្បុរសជននានា ក្នុងខេត្តមណ្ឌលគិរីទាំងអស់ បានធ្វើឱ្យវិស័យអប់រំទាំងមូលក្នុងខេត្តមានការប្រែប្រួលដើម្បី ឈានទៅសម្រេចឱ្យបាននូវការអប់រំជាមូលដ្ឋានសម្រាប់ ទាំងអស់គ្នា ។ ជាក់ស្តែងក្នុងឆ្នាំសិក្សា២០២៤-២០៥នេះ ខេត្តបុគ្គលិកអប់រំសរុបចំនួន ១.១០៤នាក់ ស្រី

៥៤៥នាក់ (ក្នុងនោះបុគ្គលិកអប់រំជាជនជាតិដើមភាគតិចចំនួន ៣៦៧នាក់ ស្រី ១៨១នាក់) ដោយចែកចេញជាបុគ្គលិកបម្រើការងារនៅក្នុងមន្ទីរអប់រំ យុវជន និងកីឡាចំនួន ៤២នាក់ ស្រី ១០នាក់ និងបុគ្គលិកបម្រើការងារនៅសាលារៀនគ្រប់កម្រិតសិក្សាចំនួន ១.០៦៤នាក់ ស្រី ៥៣៧នាក់ ។ ប៉ុន្តែសម្រាប់បុគ្គលិកអប់រំដែលបម្រើការងារនៅតាមសាលាមត្តេយ្យសិក្សា និងបឋមសិក្សា បានផ្ទេរទៅរដ្ឋបាលក្រុង/ស្រុក ជាអ្នគ្រប់គ្រង ។ សាលារៀនសរុបចំនួន ១៨៤សាលា (មត្តេយ្យសិក្សារដ្ឋ ៣៥សាលា មត្តេយ្យសិក្សាសហគមន៍ ៣២កន្លែង-មត្តេយ្យសិក្សាឯកជន ៥កន្លែង បឋមសិក្សារដ្ឋ ៩១សាលា បឋមសិក្សាឯកជន ៥កន្លែង មធ្យមសិក្សាសាធារណៈ ១៥សាលា និងមធ្យមសិក្សាឯកជន ១សាលា) ដែលមានសិស្សសរុបចំនួន ២៦៩៣០.នាក់ ស្រី ១៣.៦៧៧នាក់ ក្នុងនោះសិស្សជនជាតិដើមភាគតិចចំនួន ៩.៩៩៩នាក់ ស្រី ៥.២៩៩នាក់ ។ បើប្រៀបធៀបនឹងឆ្នាំសិក្សា២០២៣-២០២៤ សាលារៀនកើនចំនួន ៣ សាលា (មត្តេយ្យសហគមន៍ ២កន្លែន និងមត្តេយ្យឯកជន ១កន្លែង) និងសិស្សកើនចំនួន ៧៩៩នាក់ ស្រី ៥៨១ នាក់ ស្មើនឹង ២,៩៦% ស្រី ៤,២% ។ ការងារអប់រំក្រៅប្រព័ន្ធ ឆ្នាំ ២០២៤ មានកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ មានថ្នាក់អក្ខរកម្មចំនួន ១០នាក់ ស្រី ២នាក់ និងមានសិស្សចុះឈ្មោះចូលរៀនដើមឆ្នាំសរុបចំនួន ១៦២នាក់ ស្រី ៨២នាក់ ។ មានបណ្ណាល័យចំនួន ០១កន្លែង ដែលមានអ្នកចូលអានសរុបចំនួន ៣៦៤នាក់ ស្រី ២០២នាក់ ។ និងមានមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន០៥កន្លែង ដោយមានបង្រៀនជំនាញមុខរបរ៤ថ្នាក់ ជំនាញកុំព្យូទ័រ០២ថ្នាក់មានអ្នករៀនចំនួន ៣២នាក់ស្រី ២៣នាក់ សំអាងកាយ ០១ថ្នាក់មានអ្នករៀនចំនួន ១០នាក់ស្រី ១០នាក់ និង ថ្នាក់ចាក់កាបូប ចំនួន១ ថ្នាក់ មានអ្នករៀនចំនួន៣០នាក់ ស្រី២៦នាក់សរុបចំនួន ៥៨នាក់ ស្រី ៤៩នាក់ ។ ក្នុងនោះមាន គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍សរុបចំនួន ២៥នាក់ ស្រី០៩នាក់ ។ មានថ្នាក់សមមូលបឋមសិក្សាចំនួន ៣ ថ្នាក់ គ្រូបង្រៀនចំនួន ៣នាក់ ស្រី ០១នាក់ មានសិស្សសរុបចំនួន ៥៧នាក់ ស្រី ០៩នាក់ ។ សម្រាប់ការងារយុវជនមានក្រុមប្រឹក្សាកុមារចំនួន ៦៥ ក្រុម ក្នុងនោះមានក្រុមប្រឹក្សាកុមារ កម្ពុជាចំនួន ៤៨ភាគរយ ដែលបានដំណើរការ ដោយឡែកក្រុមប្រឹក្សាយុវជនកម្ពុជាមានចំនួន ០៥ក្រុម ហើយក្រុមប្រឹក្សា យុវជនដែលបានដំណើរការគឺ ៨២ភាគរយ ។ ចំពោះក្រុមប្រឹក្សាកុមារកម្ពុជាដែលពុំទាន់មានដំណើរការល្អប្រសើរនោះ គឺ ដោយសារសាលារៀននាយកសាលា និង

គ្រូបង្រៀន មិនទាន់យល់ច្បាស់ពីសារៈសំខាន់នៃការងារនេះ ដូច្នេះធ្វើឱ្យគាត់បោះបង់ការងារក្រុមប្រឹក្សាកុមារកម្ពុជាចោល ។

២.១.១-វឌ្ឍនភាពនៃការផ្តល់សេវាអប់រំ យុវជន និងកីឡា

២.១.១.១ ផ្នែកបរិមាណវិស័យ

ការពង្រឹងនិងការលើកកម្ពស់គុណភាពអប់រំពិសេសវិស័យអប់រំវិទ្យាសាស្ត្របច្ចេកវិទ្យា និងការបណ្តុះបណ្តាលបច្ចេកទេស មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានខិតខំអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ក្នុងក្របខណ្ឌយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលសម្រេចបានសមិទ្ធផលសំខាន់ៗគួរឱ្យកត់សម្គាល់ដូចខាងក្រោម៖

សមិទ្ធផលអប់រំ សម្រេចបានតាមរយៈអន្តរាគមន៍មួយចំនួន ដូចជាការធ្វើយុទ្ធនាការប្រមូលកុមារដល់វ័យសិក្សា ការសាងសង់អគារសិក្សា ការផ្តល់គ្រូបង្រៀន ការផ្តល់ថវិកាដំណើរការសាលារៀន ការចូលរួមរបស់ហគមន៍ ដៃគូអភិវឌ្ឍ ការគាំទ្រពីអាជ្ញាធរដែនដី ការផ្តល់អាហារូបករណ៍ ដល់សិស្សមកពីគ្រួសារក្រីក្រ ការផ្តល់អាហារពេលព្រឹកនៅតាមសាលារៀន ដែលបានបង្កលក្ខណៈឱ្យសិស្សានុសិស្ស មានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានការអប់រំនៅគ្រប់កម្រិត ពីថ្នាក់មត្តេយ្យសិក្សារហូតដល់មធ្យមសិក្សា ។

មត្តេយ្យសិក្សា ៖ ក្នុងឆ្នាំសិក្សា ២០២៤-២០២៥ សាលារៀនមត្តេយ្យសិក្សាគ្រប់រូបភាព ៧២សាលា (មត្តេយ្យសាធារណៈ ៣៥សាលា មត្តេយ្យសិក្សាសហគមន៍ ៣២កន្លែង និងមត្តេយ្យឯកជន ៥សាលា) ដែលមានកុមារទទួលបានសេវាអប់រំ ២.៧៨៣នាក់ ស្រី ១.៤៣៧នាក់ (ក្នុងនោះសិស្សជនជាតិដើមភាគតិច ៩៦៨នាក់ ស្រី ៥០៨នាក់) បើធៀបនឹងឆ្នាំសិក្សា២០២៣-២០២៤ គឺកើន ៣សាលា សិស្សកើន ១៩៨នាក់ ស្រី ១៥០នាក់ ប្រុស ៤៣នាក់ ស្មើនឹង ៧,១% ស្រី ១០,៤% ប្រុស ៣,២% ។ ក្នុងនោះកុមារអាយុ ៣ឆ្នាំ បានទទួលសេវាអប់រំមាន ៤៣០ នាក់ ស្រី ២១៥នាក់ ប្រុស ២១៥នាក់ ស្មើនឹង ១៦,២% ស្រី ១៦,០% ប្រុស ១៦,៣% កុមារអាយុ ៤ឆ្នាំ បានទទួលសេវាអប់រំមាន ១,១០៥នាក់ ស្រី ៦១៥នាក់ ប្រុស ៤៩០នាក់ ស្មើនឹង ៤៧,២% ស្រី ៥១,៧% ប្រុស ៤២,៦% និងកុមារអាយុ ៥ឆ្នាំ បានទទួលសេវាអប់រំ ១.២៤៨នាក់ ស្រី ៦០៧នាក់ ប្រុស ៦៤១នាក់ ស្មើនឹង ៥៤,១% ស្រី ៥១,៥% ប្រុស ៥៦,៨%។

បឋមសិក្សា ៖ សាលារៀនបឋមសិក្សាសរុប ៩៦ សាលា (បឋមសិក្សាសាធារណៈ ៩១សាលា និងបឋមសិក្សាឯកជន ៥សាលា) ដែលលមានសិស្សទទួលបានសេវាអប់រំ ១៧.០៥៩នាក់ ស្រី ៨.៤៥១នាក់ (ក្នុងនោះសិស្សជនជាតិដើមភាគតិច ៦.៥១១នាក់ ស្រី ៣.៣៥២នាក់) បុគ្គលិកអប់រំបម្រើការងារនៅតាមសាលារៀនសាធារណៈសរុបចំនួន ៦៨៨នាក់ ស្រី ៣៥៨នាក់ (ក្នុងនោះបុគ្គលិកជនជាតិដើមភាគតិច ៣៦៤នាក់ ស្រី ១៨៧ នាក់) បុគ្គលិកមិនបង្រៀនចំនួន ៤៩នាក់ ស្រី ១២នាក់ និងថ្នាក់រៀនសរុប ៧២២ថ្នាក់ ។ បើធៀបនឹងឆ្នាំសិក្សា ២០២៣-២០២៤ សិស្សថយចុះ ០៤នាក់ ស្មើនឹង ០,០២% ស្រីកើន ១១៥នាក់ ប្រុសថយ ១១៩នាក់ និងថ្នាក់រៀនកើន ១២ថ្នាក់ ។ អត្រាពិតចូលរៀនថ្មីសរុប ៨៧,៧% ស្រី ៨៧,១% ប្រុស ៨៨,៣% អត្រារួមចូលរៀនថ្មីសរុប ១២៣,៣% ស្រី ១២០,២% ប្រុស ១២៦,២% និងអត្រាពិតនៃការសិក្សាសរុប ១០៣,៩% ស្រី ១០៦,២% ប្រុស ១០១,៧% អត្រារួមនៃការសិក្សាសរុប ១២២,៧% ស្រី ១២៣,៤% ប្រុស ១២២,០% បើធៀបនឹងឆ្នាំសិក្សាមុនគឺមានការកើនឡើងបន្តិចបន្តួច ។

មធ្យមសិក្សា ៖ សាលារៀនមធ្យមសិក្សាសរុប ១៦ សាលា (មធ្យមសិក្សាសាធារណៈ ១៥សាលា និងមធ្យមសិក្សាឯកជន ១សាលា) ដែលលមានសិស្សចូលរៀនសរុប ៧.០៨៨នាក់ ស្រី ៣.៧៨៩នាក់ (ក្នុងនោះសិស្សជនជាតិដើមភាគតិច ២.៥២០នាក់ ស្រី ១.៤៤៥នាក់) បុគ្គលិកអប់រំបម្រើការងារនៅតាមសាលារៀនសាធារណៈសរុប

ចំនួន ២៩៤នាក់ ស្រី ១២៨នាក់ (ក្នុងនោះបុគ្គលិកជនជាតិដើមភាគតិច ២៣នាក់ ស្រី ០៩នាក់) បុគ្គលិកមិនបង្រៀនចំនួន ១៥នាក់ ស្រី ០២នាក់ និងថ្នាក់រៀបសរុប ១៥១ថ្នាក់ ។ បើធៀបនឹងឆ្នាំសិក្សា២០២២-២០២៣ សិស្សកើន ៥៩៦នាក់ ស្រី ៣១០នាក់ ស្មើនឹង ៨,៤% ស្រី ៨,២% និងថ្នាក់រៀនកើន ៣ថ្នាក់ ។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិសរុប ៦៦,៦% ស្រី ៧២,៦% ប្រុស ៦០,៨% អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិសរុប ១៧,៨% ស្រី ១៨,៦% ប្រុស ១៧% បើធៀបនឹងឆ្នាំសិក្សាមុនគឺមានការកើនឡើងបន្តិចបន្តួច និងរៀបចំការប្រឡងជ្រើសរើសសិស្សពូកែទូទាំងខេត្តលើមុខវិជ្ជា អក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា ថ្នាក់ទី៩ ចំនួន ៣ នាក់ ស្រី ០ នាក់ ថ្នាក់ទី ១២ ចំនួន ៣ នាក់ស្រី ១ នាក់ដើម្បីយកទៅប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ដែលជាលទ្ធផលសិស្សពូកែផ្នែក អក្សរសិល្ប៍ខ្មែរថ្នាក់ទី ៩ បានប្រឡងជាប់ក្នុងចំណាត់ថ្នាក់ជ័យលាភីលេខ២ ទូទាំងប្រទេស ។

ការងារអប់រំក្រៅប្រព័ន្ធ: ក្នុងឆ្នាំ២០២៤ ការងារអប់រំក្រៅប្រព័ន្ធបានចូលរួមអនុវត្តគោលនយោបាយអប់រំស្តីពី ធានាឱ្យពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព ដោយសមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត ក្នុងនោះសម្រេចបាននូវសមិទ្ធផលធំ ៗ រួមមាន: កម្មវិធីអក្ខរកម្មវិជ្ជាជីវៈមានថ្នាក់អក្ខរកម្មចំនួន១០ថ្នាក់ គ្រូបង្រៀន ១០នាក់ ស្រី៦នាក់ និងមានសិស្សចុះឈ្មោះចូលរៀនដើមឆ្នាំសរុប ១៦២នាក់ ស្រី ៨២នាក់ ។ មានបណ្ណាល័យ ១កន្លែងមានអ្នកចូលអានសរុប ៣៦៤នាក់ ស្រី ២០២នាក់ ។ មានមជ្ឈមណ្ឌលសិក្សាសហគមន៍៥កន្លែង និងមានគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍សរុបចំនួន២៥នាក់ ស្រី៩នាក់ ដោយមានបង្រៀនជំនាញមុខរបរ ៤ថ្នាក់ ជំនាញកុំព្យូទ័រ ២ថ្នាក់មានអ្នករៀន ៣២នាក់ ស្រី ២៣នាក់ សំអាងកាយ ១ថ្នាក់មានអ្នករៀន ១០នាក់ស្រី ១០នាក់ និង ថ្នាក់ចាក់កាបូប ១ថ្នាក់ មានអ្នករៀន ៣០នាក់ ស្រី ២៦នាក់ ។ មានថ្នាក់សមមូលបឋមសិក្សា ៣ថ្នាក់ គ្រូបង្រៀន ៣នាក់ ស្រី ១នាក់ មានសិស្សសរុប ៥៧នាក់ ស្រី ៩នាក់ ។

ការងារអប់រំកាយ យុវជន និងកីឡា: យោងលិខិតលេខ ០៤៤ មន្ទីរអប់រំយុវជន និងកីឡាបានចេញសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីអប់រំកាយក្នុងម៉ោង និងកីឡាក្រៅម៉ោងសិក្សានៅគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សាឱ្យបានល្អប្រសើរឡើង និងមានប្រសិទ្ធិភាពស្របតាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា ៖

- នៅគ្រប់គ្រឹះស្ថានបឋមសិក្សា ទាំងអស់ទូទាំងខេត្ត បានបញ្ចូលកម្មវិធីអប់រំកាយ ក្នុងកាលវិភាគរួមរបស់ខ្លួន (មួយសប្តាហ៍ ពីរម៉ោង) ដើម្បីឱ្យសិស្សហ្វឹកហាត់ជាប្រចាំ ក្នុងគោលបំណងធ្វើឱ្យរាងកាយរបស់សិស្សមានភាពមាំមួននិងរឹងប៉ឹងល្អប្រសើរ ព្រមទាំងមានចំណងមិត្តភាព និងសាមគ្គីភាព ។
- នៅគ្រប់គ្រឹះស្ថានមធ្យមសិក្សាទាំងអស់ទូទាំងខេត្ត បានបញ្ចូលកម្មវិធីអប់រំកាយកីឡា ក្នុងកាលវិភាគរួមរបស់ខ្លួន(មួយសប្តាហ៍ ពីរម៉ោង) ដើម្បីឱ្យសិស្សហ្វឹកហាត់ជាប្រចាំ ដែលមានវិញ្ញាសាជាច្រើនដូចជា: បាល់ទាត់ បាល់ទះ បាល់បោះ អត្តពលកម្ម និងកីឡាប៉េតង់មួយចំនួន ដើម្បីសុខភាពរាងកាយ និងដើម្បីចូលរួមប្រកួតថ្នាក់ខេត្ត និងទូទាំងប្រទេស ។

- រៀបចំការប្រកួតកីឡាសិស្សបឋមសិក្សាជ្រើសរើសជើងឯកថ្នាក់ខេត្តប្រចាំឆ្នាំសិក្សា២០២៣-២០២៤ លើវិញ្ញាសារបាល់ទាត់(កុមារា-កុមារី).បាល់ទះ(កុមារា-កុមារី).អត្តពលកម្ម(កុមារា-កុមារី).ប៊ូល និងប៉េតង់(កុមារា-កុមារី) ដែលមានក្រុមកីឡាករ-កីឡាការិនីសរុបចំនួន២៥៨នាក់ស្រី១១០នាក់ ។
- រៀបចំការប្រកួតកីឡាសិស្សមធ្យមសិក្សាជ្រើសរើសជើងឯកថ្នាក់ខេត្តប្រចាំឆ្នាំសិក្សា២០២៣-២០២៤ លើវិញ្ញាសារ បាលទាត់(បុរស-នារី).បាល់ទះ(បុរស-នារី).អត្តពលកម្ម(បុរស-នារី).ប៊ូល និងប៉េតង់(បុរស-នារី) ដែលមានក្រុមកីឡាករ-កីឡាការិនីសរុបចំនួន៣៧២នាក់ស្រី១៦២នាក់
- ដឹកនាំប្រតិភូកីឡា ចំនួន១២១នាក់ ស្រី៥០នាក់ ចូលរួមការការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិលើប្រភេទកីឡាបាល់ទាត់(កុមារា-កុមារី).បាល់ទះ(កុមារា-កុមារី).អត្តពលកម្ម(កុមារា-កុមារី).ប៊ូល និងប៉េតង់ និងតែក្វាន់ដូ(កុមារា-កុមារី)ជាលទ្ធផលតែក្វាន់ដូទទួលបានមេដាយមាស០១គ្រឿង មេដាយប្រាក់០១គ្រឿង
- ដឹកនាំប្រតិភូកីឡា ចំនួន១៣៦នាក់ ស្រី៤៤នាក់ ចូលរួមការការប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ជាតិលើប្រភេទកីឡាបាល់ទាត់(បុរស-នារី).បាល់ទះ(បុរស-នារី). ប៊ូល និងអត្តពលកម្ម(បុរស-នារី).ប៉េតង់ និងតែក្វាន់ដូ(កុមារា-កុមារី) ជាលទ្ធផល កីឡាអត្តពលកម្មទទួលបានមេដាយ សំរិទ្ធ០១គ្រឿង ។
- រៀបចំការប្រកួតកីឡាមហាជនជ្រើសរើសជើងឯកថ្នាក់ខេត្តពានរង្វាន់បាល់ទាត់ ឯកឧត្តមអភិបាលខេត្តមណ្ឌលគិរី ឆ្នាំ២០២៤ នេះមានប្រតិភូកីឡាចូលរួមសរុបចំនួន ១២ក្រុម ស្មើនឹង ៣០០នាក់
- ដឹកនាំប្រតិភូកីឡាចំនួន៩៦នាក់ ស្រី៤៨នាក់ ទៅចូលរួមការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិទទួលបានមេដាយសំរឹទ្ធ០១គ្រឿង
- ដឹកនាំប្រតិភូកីឡាចំនួន១៣១នាក់ ស្រី៥២នាក់ ទៅចូលរួមការប្រកួតកីឡាជាតិលើកទី៤ ទទួលបានមេដាយមាស០១គ្រឿង មេដាយប្រាក់០៧គ្រឿង និងមេដាយសំរឹទ្ធ១២គ្រឿង
- ការប្រកួតកីឡាថ្នាក់ជាតិ សម្រាប់សិស្សបឋម និងមធ្យមសិក្សាទទួលបានមេដាយចំនួន១គ្រឿង
- លោកគ្រូដឹកនាំ និងយុវជនចំនួន១៤នាក់ បានចូលរួមវគ្គតម្រង់ទិសយុវជនសម្រាប់អនុវត្តគម្រោងក្នុងកម្មវិធី "ផែនការអាជីកម្មខ្ញុំ" ឆ្នាំ២០២៤ តាមប្រព័ន្ធអនឡាញ
- ប្រតិភូយុវជនចំនួន ៥នាក់ស្រី ៣នាក់ចូលរួមការប្រកួតម្មវិធី "ជជែកដេញដោលយុវជនថ្នាក់ជាតិ ឆ្នាំ២០២៤"
- រៀបចំខួបលើកទី៧៥ នៃទិវាកុមារអន្តរជាតិ ០១ មិថុនា ខួបលើកទី២៣ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៤ ក្រោមប្រធានបទ "វិនិយោគលើកុមារថ្ងៃនេះ សំដៅបង្កើនមូលធនមនុស្សក្នុងយុគសម័យបរិវត្តកម្មឌីជីថល"មានអ្នកចូលរួម ៤០០នាក់ ស្រី ២៦៧នាក់ នៅសាលាបឋមសិក្សាស្រែក្លែងស្រុកពេជ្រាដា
- ដឹកនាំប្រតិភូយុវជនចំនួន១០នាក់ ស្រី០៥នាក់ ចូលរួមវគ្គប្រកួតប្រជែងស្នាដៃយុវជនសតវត្សទី២១ ក្រោមប្រធានបទ " STEM ក្នុងវិស័យថាមពល "
- ដឹកនាំប្រតិភូយុវជនកាយរឹទ្ធិរៀមច្បងចំនួន ៦នាក់ ស្រី ០៣នាក់ ចូលរួមក្នុងកម្មវិធីបោះដំរំកាយរឹទ្ធិរៀមច្បងថ្នាក់ជាតិលើកទី២ក្រោមប្រធានបទ"ចូលរួមក្នុងកាយរឹទ្ធិកម្មដើម្បីវឌ្ឍនភាពអនាគត់របស់ខ្ញុំ " នៅខេត្តកំពង់ធំ

- ដឹកនាំប្រតិភូក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា ចំនួន ១០នាក់ ស្រី ០៦នាក់ ចូលរួមការប្រជុំបូកសរុបចលនាប្រឡងប្រណាំងបីល្អ " កូនល្អ សិស្សល្អ មិត្តល្អ " ក្រោមប្រធាបទ" ការចាប់ផ្តើមរបស់កុមារ និងយុវជន ដើម្បីក្លាយខ្លួនជាប្រជាពលរដ្ឋឌីជីថល " នៅខេត្តសៀមរាប ។
- មជ្ឈមណ្ឌលយុវជនមួយកន្លែងត្រូវបានរៀបចំ និងបំពាក់សម្ភារៈ

២.១.១.២ ផ្នែកគុណភាពវិស័យ

ក្នុងឆ្នាំសិក្សា២០២៣-២០២៤ មន្ទីរអប់រំ យុវជន និងកីឡា បានប្តេជ្ញាចិត្តថា:នឹងចុះគាំទ្រដល់សាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា និងសាលាមធ្យមសិក្សា ដែលជាសាលារៀនគោលដៅដើម្បីណែនាំបច្ចេកទេស លើការរៀបចំផែនការ ការរៀបចំទុកដាក់ឯកសារគាំទ្រការងារបង្រៀន និងការងារផ្សេង ។ ទៀតពាក់ព័ន្ធទៅនឹងសូចនាករដែលត្រូវវាយតម្លៃជាប់ជាស្តង់ដារសាលារៀនគំរូប្រចាំឆ្នាំ២០២៤ ។

•ភាគរយសិស្សថ្មីថ្នាក់ទី១ ដែលបានឆ្លងកាត់ថ្នាក់មត្តេយ្យសិក្សា សម្រេចបាន ៤៤,៩% ស្រី ៤៤,៣% ប្រុស ៤៤,៦%

•**សូចនាករអប់រំដែលសម្រេចបាននៅបឋមសិក្សាសម្រាប់ឆ្នាំសិក្សា២០២៣-២០២៤**

-អត្រាឡើងថ្នាក់សរុប: ៨៦,៤% ស្រី ៨៩.៤% ប្រុស ៨៣.៤%

-អត្រាត្រួតថ្នាក់សរុប: ៥,១% ស្រី ៣,៧% ប្រុស ៦,៥%

-អត្រាបោះបង់ការសិក្សាសរុប:៨,៥% ស្រី ៦,៩% ប្រុស ១០,១%

-អត្រាបញ្ចប់ការសិក្សាសរុប: ៩២,៤៥% ស្រី ១០៣,០៦% ប្រុស ៨៣,០៩%

-អត្រាគង់វង្សសរុប:៦៧,១៧% ស្រី ៧១,៤៩% ប្រុស ៦៣,០៣%

-អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សា ទៅមធ្យមសិក្សាបឋមភូមិសរុប:៨១,៤% ស្រី ៨៦,១% ប្រុស ៧៦,៨%

-ភាគរយសាលារៀនមានទឹកស្អាត បង្គន់អនាម័យ និងកន្លែងលាងសម្អាតដៃ: កម្រិត សូន្យ ១៥,៩% កម្រិតទី១ ៖ ៣៥,២% កម្រិតទី២៖ ៤៨,៩% និងកម្រិតទី៣ គ្មាន

-ភាគរយគ្រូបង្រៀនបឋមសិក្សាមានគុណវុឌ្ឍិតាមស្តង់ដាជាតិ: ១៦,១%

-ភាគរយសាលាកុមារមេត្រី កម្រិតមធ្យម កម្រិតអភិវឌ្ឍ: ៧១,៦%

•**សូចនាករអប់រំដែលសម្រេចបាននៅមធ្យមសិក្សាឆ្នាំសិក្សា២០២៣-២០២៤**

-អត្រាឡើងថ្នាក់នៅមធ្យមសិក្សាបឋមភូមិសរុប: ៨៤,១% ស្រី ៨៥% ប្រុស ៨៣,១%

-អត្រាត្រួតថ្នាក់នៅមធ្យមសិក្សាបឋមភូមិសរុប: ២,៦% ស្រី ១,៧% ប្រុស ៣,៧%

-អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិសរុប: ១៣,៣% ស្រី ១៣,៣% ប្រុស ១៣,២%

-អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិសរុប: ៥៣,៤៨% ស្រី ៦២,០១% ប្រុស ៤៥,៤៥%

-អត្រាគង់វង្សនៅមធ្យមសិក្សាបឋមភូមិសរុប: ៤២,៨៩% ស្រី ៤៩,៣២% ប្រុស ៣៦,៩៥%

-អត្រាឡើងថ្នាក់នៅមធ្យមសិក្សាទុតិយភូមិសរុប: ៨៩,៣% ស្រី ៩០,៣% ប្រុស ៨៨,១%

-អត្រាត្រួតថ្នាក់នៅមធ្យមសិក្សាទុតិយភូមិសរុប: ២% ស្រី ១,៧% ប្រុស ២,២%

-អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិសរុប: ៨,៧% ស្រី ៨% ប្រុស ៩,៦%

-អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិសរុប: ៣៣,៨១% ស្រី ៣៦,៥៤% ប្រុស ២៩,៣២%

-អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិ ទៅមធ្យមសិក្សាទុតិយភូមិសរុប:៨៤,២% ស្រី ៨៣% ប្រុស ៨៥.៧%

-អត្រាគង់វង្សនៅមធ្យមសិក្សាទុតិយភូមិសរុប: ២៩,៥៥% ស្រី ៣៣,៧៧% ប្រុស ២៥,៥៩%

-ភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ: ៩៦,៦% ស្រី ៩៨,២%

-ភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតយភូមិ: ៩៣,៨% ស្រី ៩៤,០៩%

•ការងារអប់រំក្រៅប្រព័ន្ធ

-កម្មវិធីអក្ខរកម្មវិជ្ជាជីវៈមានថ្នាក់អក្ខរកម្មចំនួន ១០នាក់ ស្រី ០៦នាក់ និងមានសិស្សចុះឈ្មោះចូលរៀនដើមឆ្នាំសរុបចំនួន ១៦២នាក់ ស្រី ៨២នាក់ ។

- មានបណ្ណាល័យចំនួន ០១កន្លែង អ្នកចូលអានសរុបចំនួន៣៦៤នាក់ ស្រី២០២នាក់

-មានមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន ០៥កន្លែង និងគណៈគ្រប់គ្រង ២៥នាក់ ស្រី០៩នាក់ ដោយបើកបង្រៀនជំនាញមុខរបរងាយ ៗ ដូចជា ជំនាញកុំព្យូទ័រ០២ថ្នាក់មានអ្នករៀនចំនួន ៣២នាក់ស្រី ២៣នាក់ សំអាងកាយ ០១ថ្នាក់មានអ្នករៀនចំនួន ១០នាក់ស្រី ១០នាក់ និង ថ្នាក់ចាក់កាបូប ចំនួន០១ថ្នាក់ មានអ្នករៀនចំនួន ៣០នាក់ ស្រី ២៦នាក់

-មានថ្នាក់សមមូលបឋមសិក្សាចំនួន ០៣ថ្នាក់ គ្រូបង្រៀនចំនួន ៣នាក់ ស្រី ០១នាក់ មានសិស្សសរុបចំនួន ៥៧នាក់ ស្រី ០៩នាក់ ។

•ការងារអប់រំកាយ យុវជន និងកីឡា

ក្នុងផ្នែកនេះ ត្រូវឆ្លុះបញ្ចាំងពីគុណវិស័យដោយធ្វើការវិភាគ និងវាយតម្លៃលើសូចនាករស្នូលនិងសូចនាកររងលសម្រេចរបស់អនុវិស័យ ធៀបទៅនឹងចំណុចដៅដែលបានកំណត់ ក្នុងរបាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP-MTR ២០២៣-២០២៥)។

- **កម្មវិធីកូនល្អ សិស្សល្អ មិត្តល្អ៖** យុវជន និងកុមារចំនួន ១០នាក់ បានចូលរួមប្រជុំបូកសរុបចលនាប្រឡងប្រណាំង៣ល្អថ្នាក់ជាតិ និងទទួលបានប័ណ្ណសរសើរ "កូនល្អ សិស្សល្អ មិត្តល្អ" ក្រោមប្រធានបទ "ការចាប់ផ្តើមរបស់កុមារ និងយុវជនដើម្បីក្លាយខ្លួនជាប្រជាពលរដ្ឋឌីជីថល" ក្នុងកិច្ចការប្រជុំនេះជាវេទិការអប់រំដែលបានបណ្តុះគំនិតយុវជន និងកុមារចេះធ្វើការងារជាក្រុម ដោយផ្សារភ្ជាប់ទៅនឹងការសិក្សារបស់ខ្លួននៅសាលារៀន បណ្តុះស្មារតីឧស្សាហ៍ព្យាយាម ខិតខំរៀនសូត្រ បង្កើនចំណេះដឹង ចំណេះធ្វើ ព្រមទាំង

ស្រឡាញ់រាប់អានគ្នាដូចបងប្អូន ឱ្យមានទម្លាប់ល្អក្នុងគ្រួសារ សាលារៀន សង្គម និងអាចក្លាយជាអ្នកដឹកនាំប្រកបដោយថាមពលនាពេលអនាគត។

- លោកគ្រូដឹកនាំ និងយុវជនចំនួន១៤នាក់ បានចូលរួមវគ្គតម្រង់ទិសយុវជនសម្រាប់អនុវត្តគម្រោងក្នុងកម្មវិធី "ផែនការអាជីកម្មខ្ញុំ" ឆ្នាំ២០២៤ តាមប្រព័ន្ធអនឡាញ
- ប្រតិភូយុវជនចំនួន ៥នាក់ស្រី ៣នាក់ចូលរួមការប្រកួតម្មវិធី "ជជែកដេញដោលយុវជនថ្នាក់ជាតិ ឆ្នាំ ២០២៤"
- រៀបចំខួបលើកទី៧៥ នៃទិវាកុមារអន្តរជាតិ ០១ មិថុនា ខួបលើកទី២៣ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៤ ក្រោមប្រធានបទ "វិនិយោគលើកុមារថ្ងៃនេះ សំដៅបង្កើនមូលធនមនុស្សក្នុងយុគសម័យបរិវត្តកម្មឌីជីថល"មានអ្នកចូលរួម ៤០០នាក់ ស្រី ២៦៧នាក់ នៅសាលាបឋមសិក្សាស្រែក្លែងស្រុកពេជ្រាដា
- ដឹកនាំប្រតិភូយុវជនចំនួន១០នាក់ ស្រី០៥នាក់ ចូលរួមវគ្គប្រកួតប្រជែងស្មារដៃយុវជនសតវត្សទី២១ ក្រោមប្រធានបទ " STEM ក្នុងវិស័យថាមពល "
- ដឹកនាំប្រតិភូយុវជនកាយរឹទ្ធិរៀមច្បងចំនួន ៦នាក់ ស្រី ០៣នាក់ ចូលរួមក្នុងកម្មវិធីបោះដំរំកាយរឹទ្ធិរៀមច្បងថ្នាក់ជាតិលើកទី២ក្រោមប្រធានបទ " ចូលរួមក្នុងកាយរឹទ្ធិកម្មដើម្បីវឌ្ឍនភាពអនាគត់របស់ខ្ញុំ " នៅខេត្តកំពង់ធំ
- ដឹកនាំប្រតិភូក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា ចំនួន ១០នាក់ ស្រី ០៦នាក់ ចូលរួមការប្រជុំបូកសរុបចលនាប្រឡងប្រណាំងបីល្អ "កូនល្អ សិស្សល្អ មិត្តល្អ" ក្រោមប្រធាបទ"ការចាប់ផ្តើមរបស់កុមារ និងយុវជន ដើម្បីក្លាយខ្លួនជាប្រជាពលរដ្ឋឌីជីថល " នៅខេត្តសៀមរាប ។
- **ការងារកាយរឹទ្ធិកម្ម៖** យុវជនកាយរឹទ្ធិបានចូលរួមពិធីបុណ្យឯករាជជាតិ ០៩ វិច្ឆិកា ទិវាអនាម័យបរិស្ថានដែលបានសម្អាតបរិស្ថានតាមដងផ្លូវ ទីសាធារណៈ
- **ការលើកកម្ពស់ការស្មើគ្រចិត្ត និងការចូលរួមរបស់យុវជន៖** យុវជនចំនួន ១៥នាក់ទទួលបានការ បណ្តុះបណ្តាល និងអនុវត្តគម្រោងការស្មើគ្រចិត្តដើម្បីសហគមន៍ខ្ញុំ ដែលធ្វើឱ្យយុវជនទទួលបានចំណេះដឹង ចេះសរសេរគម្រោង ចេះកៀរគរធនធាន និងធ្វើការងារជាក្រុម ដើម្បីអភិវឌ្ឍសហគមន៍របស់ខ្លួន។
- **ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ** និងជំនាញឌីជីថល និងជំនាញបច្ចេកទេសរយៈពេលខ្លី៖

ការបោះជំរំនិងទស្សនកិច្ចសិក្សា៖ចូលរួមក្នុងកម្មវិធីបោះដំរំកាយរឹទ្ធិរៀមច្បង ថ្នាក់ជាតិលើកទី២ ក្រោមប្រធានបទ " ចូលរួមក្នុងកាយរឹទ្ធិកម្ម ដើម្បីវឌ្ឍនភាពអនាគតរបស់ខ្ញុំ " នៅខេត្តកំពង់ធំ ជាលទ្ធផលទទួលបានការរស់នៅជាក្រុម មានគំនិតឆ្នៃប្រឌិត ចេះដោះស្រាយបញ្ហា ចេះស្រលាញ់បរិស្ថាន វប្បធម៌ប្រពៃណី ។

- **ការប្រកួតប្រជែងសមត្ថភាពយុវជន៖**

- ដឹកនាំប្រតិភូយុវជនចំនួន១០នាក់ ស្រី០៥នាក់ ចូលរួមវគ្គប្រកួតប្រជែងស្នាដៃយុវជនសតវត្សទី២១ ក្រោមប្រធានបទ ″ STEM ក្នុងវិស័យថាមពល ″ ធ្វើឱ្យយុវជនទទួលបានចំណេះដឹងពីមុខវិជ្ជាSTEM (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា) និងទទួលបានបទពិសោធន៍ថ្មីៗ ចំណេះជំនាញ។
- ដឹកនាំប្រតិភូយុវជនចំនួន៥នាក់ស្រី៣នាក់ បានចូលរួមកម្មវិធីជជែកដេញដោលយុវជនឆ្នើមថ្នាក់ជាតិឆ្នាំ២០២៤ យុវជនបានបញ្ចេញភាពក្លាហាន ទទួលបានចំណេះដឹងថ្មីៗ នីតិវិធីក្នុងការតស៊ូមតិ។

- **ការផ្សព្វផ្សាយសកម្មភាពកិច្ចការយុវជន៖** បានផ្សព្វផ្សាយសកម្មភាពកិច្ចការយុវជន ដល់អនុវិទ្យាល័យ និងវិទ្យាល័យទាំង ៥ តាមរយៈក្រុមយុវជនស្ម័គ្រចិត្ត។
- រៀបចំការប្រកួតកីឡាសិស្សបឋមសិក្សាជ្រើសរើសជើងឯកថ្នាក់ខេត្តប្រចាំឆ្នាំសិក្សា២០២៣-២០២៤ លើវិញ្ញាសារបាល់ទាត់(កុមារ-កុមារី).បាល់ទះ(កុមារ-កុមារី).អត្តពលកម្ម(កុមារ-កុមារី).ប៊ូល និងប៉េតង់ (កុមារ-កុមារី) ដែលមានក្រុមកីឡាករ-កីឡាការិនីសរុបចំនួន២៥៨នាក់ស្រី១១០នាក់ ។
- រៀបចំការប្រកួតកីឡាសិស្សមធ្យមសិក្សាជ្រើសរើសជើងឯកថ្នាក់ខេត្តប្រចាំឆ្នាំសិក្សា២០២៣-២០២៤ លើវិញ្ញាសារ បាលទាត់(បុរស-នារី).បាល់ទះ(បុរស-នារី).អត្តពលកម្ម(បុរស-នារី).ប៊ូល និងប៉េតង់(បុរស-នារី) ដែលមានក្រុមកីឡាករ-កីឡាការិនីសរុបចំនួន៣៧២នាក់ស្រី១៦២នាក់
- ដឹកនាំប្រតិភូកីឡា ចំនួន១២១នាក់ ស្រី៥០នាក់ ចូលរួមការការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិលើប្រភេទកីឡាបាល់ទាត់(កុមារ-កុមារី).បាល់ទះ(កុមារ-កុមារី)អត្តពលកម្ម(កុមារ-កុមារី).ប៊ូលនិងប៉េតង់ និងតៃក្វាន់ដូ(កុមារ-កុមារី)ជាលទ្ធផលតៃក្វាន់ដូទទួលបានមេដាយមាស០១គ្រឿង មេដាយប្រាក់០១គ្រឿង
- ដឹកនាំប្រតិភូកីឡា ចំនួន១៣៦នាក់ ស្រី៤៤នាក់ ចូលរួមការការប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ជាតិលើប្រភេទកីឡាបាល់ទាត់(បុរស-នារី).បាល់ទះ(បុរស-នារី). ប៊ូល និងអត្តពលកម្ម(បុរស-នារី).ប៉េតង់ និងតៃក្វាន់ដូ(កុមារ-កុមារី) ជាលទ្ធផល កីឡាអត្តពលកម្មទទួលបានមេដាយ សំរិទ្ធ០១គ្រឿង ។
- រៀបចំការប្រកួតកីឡាមហាជនជ្រើសរើសជើងឯកថ្នាក់ខេត្តពានរង្វាន់បាល់ទាត់ ឯកឧត្តមអភិបាលខេត្តមណ្ឌលគិរី ឆ្នាំ២០២៤ នេះមានប្រតិភូកីឡាចូលរួមសរុបចំនួន ១២ក្រុម ស្មើនឹង ៣០០នាក់
- ដឹកនាំប្រតិភូកីឡាចំនួន៩៦នាក់ ស្រី៤៨នាក់ ទៅចូលរួមការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិទទួលបានមេដាយសំរឹទ្ធ០១គ្រឿង
- ដឹកនាំប្រតិភូកីឡាចំនួន១៣១នាក់ ស្រី៥២នាក់ ទៅចូលរួមការប្រកួតកីឡាជាតិលើកទី៤ ទទួលបានមេដាយមាស០១គ្រឿង មេដាយប្រាក់០៧គ្រឿង និងមេដាយសំរឹទ្ធ១២គ្រឿង

ក.៣ ការអនុវត្តកម្មវិធី និងសកម្មភាពនានា

ក្នុងផ្នែកនេះ ត្រូវបង្ហាញពីលទ្ធផលសម្រេចបានពីអនុវត្តកម្មវិធី ឬសកម្មភាពផ្សេងៗទៀត (អាចគម្រោងដែលអនុវត្តទាំងក្រសួង ឬដៃគូអភិវឌ្ឍ) ដោយបានអនុវត្តនៅតាមរាជធានី ខេត្ត។

២.១.២-ទស្សនភាពនៃការសម្រេចបានសូចនាករស្នូល

ដើម្បីសម្រេចឱ្យបាននូវសូចនាករស្នូលសំខាន់ៗ ដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣ ក៏ដូចជាការចូលរួមសម្រេចនូវផែនការអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាល។ មន្ទីរអប់រំ យុវជន និង កីឡា ខេត្តមណ្ឌលគិរី ជាពិសេសមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ បានខិតខំពុះពារគ្រប់ឧបសគ្គទាំងអស់ ដើម្បីធ្វើយ៉ាងណា ឱ្យកុមារក្នុងវ័យសិក្សាបានចូលរៀនគ្រប់ៗ គ្នា និងបានបញ្ចប់នូវការអប់រំជាមូលដ្ឋាន ៩ ឆ្នាំ ប្រកបដោយគុណភាព សមធម៌ បរិយាបន្ន ភាពឆ្លើយតប និងមានសីលធម៌ល្អចេះរស់នៅជាមួយគ្នាក្នុងសង្គម និងបានចុះគាំទ្របច្ចេកទេស បង្រៀន និងរៀន ព្រមទាំងការងារគ្រប់គ្រងរដ្ឋបាលសាលារៀន និងថ្នាក់រៀនជាប្រចាំ ។

ជារួមតាមរយៈការអនុវត្តគោលនយោបាយចម្បងៗទាំងពីរខាងលើ វិស័យអប់រំរបស់ខេត្តមណ្ឌលគិរី មានការ រីកចម្រើនគួរឱ្យកត់សម្គាល់ លើការធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ ទោះបីជាលទ្ធផល សម្រេចបានក្នុងពេលបច្ចុប្បន្ននៅទាបជាងចំណុចដៅខ្លះៗក៏ដោយ ។ គុណភាព និងប្រសិទ្ធភាពសេវាអប់រំក៏បាន លើកកម្ពស់ ជាបណ្តើរ ។ ជាពិសេសអត្រាឡើងថ្នាក់ អត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សាត្រូវបានកែលម្អជា បណ្តើរ ។ ជារៀងរាល់ឆ្នាំ ទាំងនៅបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ដែលមាននិន្នាការ រីកចម្រើនជាវិជ្ជមានក្នុងដំណាក់កាលនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំកន្លងមកនេះ ។ការអភិវឌ្ឍន៍ស្ថាប័ន និងការពង្រឹងសមត្ថភាពមន្ត្រីក៏ទទួលបានលទ្ធផលជាវិជ្ជមានផងដែរ ពិសេសការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ និង ការពង្រឹងសមត្ថភាពមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ក្នុងការគ្រប់គ្រង ការផ្តល់សេវាអប់រំដល់មូលដ្ឋាន ។ ដើម្បីវាយតម្លៃការ អំពីភាពរីកចម្រើន និងលទ្ធផល លើការងារអប់រំ យុវជន និងកីឡា ទាំងមូលចាំបាច់ត្រូវមានសូចនាករមួយចំនួន សម្រាប់ធ្វើការវាស់វែង និងវាយតម្លៃដើម្បីពិនិត្យអំពីលទ្ធភាពនៃការរីចម្រើនវិស័យអប់រំក្នុងខេត្ត ។

តារាងទី១ ៖ ទស្សនភាពនៃការសម្រេចបានសូចនាករស្នូល

សូចនាករ		ឯកតា	ឆ្នាំគោល	ចំណុចដៅ	ជាក់ស្តែង	ស្ថានភាព
			2023-24	2024-25	2024-25	
គោលនយោបាយទី ១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា						
១.	អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ *(ម.សិក្សាដ្ឋ សហគមន៍ និងឯកជន)*	%	43.8	50.4	54.1	↑
	ប្រុស	%	44.2	52.0	51.5	↑
	ស្រី	%	43.5	48.5	56.8	↑
	អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា	%	99.5	99.5	92.5	↓
	ប្រុស	%	93.5	94.5	83.1	↓
	ស្រី	%	106.5	102.0	103.1	↑

	អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ	%	46.8	47.5	53.5	↑
	ប្រុស	%	43.5	44.4	62.0	↑
	ស្រី	%	50.3	53.0	45.5	↓
	ចំនួនស្រុកដែលសម្រេចអត្រាបញ្ចប់ការសិក្សាបឋមសិក្សា ៨០ភាគរយ	ចំនួន	3/5	3/5	3/5	→
	ចំនួនស្រុកបានសម្រេចអត្រាបញ្ចប់បឋមភូមិយ៉ាងតិច ៤០ ភាគរយ	ចំនួន	2/5	3/5	3/5	↑
	អត្រាអក្ខរកម្មពេញវ័យ(អាយុ ១៥-៤៥)	%	73.9	74.0	74.0	→
	ភាគរយគ្រូបង្រៀនបឋមសិក្សាមានសញ្ញាបត្រទុតិយភូមិ ១២+២	%	81.4	85.0	81.4	→
	ភាគរយគ្រូបង្រៀនមធ្យមសិក្សាមានសញ្ញាបត្រទុតិយភូមិ ១២+២	%	100	100	100	→
គោលនយោបាយទី២ ពង្រឹងស្ថាប័ន ដើម្បីធានាភាពស័ក្តសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់						
	ភាគរយនាយកមធ្យមសិក្សាបានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន	%	66.0	72.8	66	→
	ភាគរយនៃការទូទាត់ថវិកា	%	90	97	97.6	↑

សម្គាល់៖ ↑ សម្រេចបានតាមចំណុចដៅ →អាចទទួលយកបាន ↓សម្រេចមិនបានតាមចំណុចដៅ

២.១.៣-ទស្សនភាពនៃការអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា

អាទិភាពទី១ ការអនុវត្តស្តង់ដាសាលារៀនគំរូ

-បង្កើតគណៈកម្មការបច្ចេកទេសសម្រាប់ចុះគាំទ្រលើការអនុវត្តស្តង់ដាសាលារៀនគំរូសម្រាប់មត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា

-ក្រុមការងារបច្ចេកទេសថ្នាក់មន្ទីរបានចុះបង្ហាត់ផ្ទាល់ដល់សាលារៀនគោលដៅ ដែលត្រូវចូលរួមវាយតម្លៃស្តង់ដាសាលារៀនគំរូកម្រិតថ្នាក់ជាតិ ក្នុងនោះមានមត្តេយ្យ ២សាលា បឋមសិក្សា៣សាលា និង មធ្យមសិក្សា ៤សាលា ដោយក្នុងមួយសាលាចុះបាន ៤ដង

-បើកវគ្គបណ្តុះបណ្តាលសមត្ថភាពដល់នាយកសាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា លើការរៀបចំធ្វើគម្រោងការសៀវភៅសិក្សា ការគណនាសូចនាករ ការរៀបចំផែនការសាលារៀន ការរៀបចំផែនការថវិកាប្រចាំ និងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ដើម្បីជួយគាំទ្រដល់សាលារៀនដែលត្រូវវាយតម្លៃជាស្តង់ដាសាលារៀនគំរូនៅដំណាច់ឆ្នាំ

-ផ្សព្វផ្សាយអំពីខ្លឹមសារសៀវភៅ ស្តីពីការអនុវត្តស្តង់ដាសាលារៀនគំរូដល់សាលារៀនគ្រប់កម្រិតសិក្សាក្នុងខេត្ត ដើម្បីត្រៀមលក្ខណៈក្នុងការប្រកួតប្រជែងយកស្តង់ដាសាលារៀនគំរូនៅឆ្នាំបន្តបន្ទាប់អាទិភាពទី២ ការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ

-មធ្យមសិក្សា០១កន្លែងគឺវិទ្យាល័យ ហ៊ុន សែន កោះញែកបានអនុវត្តជាប់ជាស្តង់ដាសាលារៀនគំរូឆ្នាំ ២០២៣ និងឆ្នាំ ២០២៤ នេះក្រសួងបាន និងកំពុងវាយតម្លៃគ្រឹះស្ថានសិក្សាអនុវត្តស្តង់ដាសាលារៀនគំរូ ចំនួន០៣ ទៀតដើម្បីវាយតម្លៃសាលារៀនគំរូ។

អាទិភាពទី៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ

-បានរៀបចំតារាងស្ថិតិសាលារៀនដែលចាស់ទ្រុឌទ្រោមធ្វើទៅក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានសំណង់)

-កំណត់ពីទីតាំងដែលត្រូវសាលាសង់សាលារៀនគ្រប់កម្រិតសិក្សានាពេលខាងមុខ

-ជួសជុលអគាសាលារៀនដែលចាស់ទ្រុឌទ្រោមនៅតាមតំបន់ដាច់ស្រយាល

-រៀបចំគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីធ្វើរបងសាលារៀនដែលមានបញ្ហាដីធ្លីជាមួយប្រជាជន

អាទិភាពទី៤ ការអប់រំឌីជីថល និងអប់រំស្នេម

-ជំរុញការបង្កើតក្លិបសិក្សា និងការតម្រង់ទិសដល់សិស្ស

-ការបំប៉នសមត្ថភាពគណៈគ្រប់គ្រង និងគ្រូបង្រៀនលើ ការគ្រប់គ្រងដឹកនាំ ការប្រើប្រាស់សម្ភារមុខវិជ្ជាស្នែមក្នុងការ បង្រៀន និងការបង្កើតតេស្ត

-ការធ្វើទស្សនកិច្ចសិក្សាដងស្រង់បទពិសោធន៍លើការគ្រប់គ្រងដឹកនាំ និងការអនុវត្តកម្មវិធីសិក្សាតាមបែបស្នែមនៅសាលាធនធាន

-ការបំពាក់សម្ភារៈពិសោធន៍តាមសាលារៀនគោលដៅ

-ការពង្រឹងសកម្មភាពរបស់សាលាធនធាន និងសាលា

-ពង្រឹងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរបស់របស់សាលាធនធាន

-អនុវត្តម៉ោងសិក្សាបន្ថែមផ្អែកលើមុខវិជ្ជាសំខាន់ៗចាំបាច់

-ការប្រឡងប្រណាំងគ្រូល្អ នាយកល្អ សាលាល្អ និងសាលាស្អាត

-ពង្រឹងលើការបង្រៀនរបស់គ្រូគ្រប់មុខវិជ្ជា ការរៀបចំកិច្ចតែងការបង្រៀន ការប្រើប្រាស់សម្ភារឧបទេស

-អនុវត្តវិធីសាស្ត្របង្រៀនវិទ្យាសាស្ត្រផ្អែកលើគោលវិធីស្នែម រួមមាន ការប្រើប្រាស់រោងជាង កុំព្យូទ័រ ប្រព័ន្ធបច្ចេកវិទ្យា និងបន្ទប់ពិសោធន៍

-សាលាអនុវត្តគម្រោង SEIP CARE និងអគារធនធានបានបំពាក់សម្ភារឧបទេស និងការធ្វើពិសោធន៍

-គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅសាលាធនធាន និងកម្រងវិទ្យាល័យ អូររាំងបានចូលរួមបំប៉នលើផ្នែកបង្រៀនពិសោធន៍តាមរយៈគ្រូបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិអប់រំ

-រៀបចំយន្តការដើម្បីអនុវត្តការគ្រប់គ្រងតាមសាលារៀន៖ ១).ការរៀបចំការធ្វើតេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ២).ការរៀបចំផែនការកែលម្អសាលារៀន ៣).ការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន ៤).ការរៀបចំកិច្ចព្រមព្រៀងលទ្ធផលបំពេញការងារគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀន

-ធ្វើអធិការកិច្ច និងពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តការអប់រំនៅតាមគ្រឹះស្ថានមធ្យមសិក្សា

-បានរៀបចំកម្មវិធីពិព័ណ៌ស្នាដៃសិស្សផ្នែក STEM និងគណិតវិទ្យាក្នុងខែមករា ឆ្នាំ ២០២៤ នៅវិទ្យាល័យ ជ្រោះ ប៊ូស្រា ដោយមានវិទ្យាល័យ ហ៊ុន សែន កោះញែក វិទ្យាល័យ ហ៊ុន សែន កែវសីមា ដែលមានការឧបត្ថម្ភគាំទ្រពី អង្គការ ខេប កម្ពុជា រយៈពេល១ថ្ងៃ។

-ថ្នាក់អក្ខរកម្មវិជ្ជាជីវៈត្រូវបានសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច ៖តាមរយៈហ្វេសប៊ុក យូរធូប តេឡេក្រាម

-បានជំរុញ និងលើកទឹកចិត្តដល់អ្នកសិក្សាឱ្យចូលទៅស្វ័យសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច និងប្រព័ន្ធផ្សព្វផ្សាយផ្លូវការ របស់ក្រសួងអប់រំយុវជននិងកីឡាដូចជា៖(Facebook:https://www.facebook.com/krou.moeys.gov.kh/ YouTube:https://www.youtube.com/moeys)

-វេទិកាសិក្សាតាមអេឡិត្រូនិច (E-Learning) ផ្លូវការរបស់ក្រសួងអប់រំ)

-កម្មវិធីអក្ខរកម្ម សមមូលបឋមសិក្សា ដែលមានតំណភ្ជាប់ (https://eleaning.moeys.gov.kh)

-ថ្នាក់សមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណេត ត្រូវបានសិក្សាតាមកម្មវិធី ប៊ីប ដែលមានតំណ (https:// lsep. moeys.gov.kh)

អាទិភាពទី៥ ការអភិវឌ្ឍបំណិនសតវត្សទី២១ សម្រាប់យុវជន

- ពង្រឹងការងារសហគ្រិនភាពតាមរយៈការអនុវត្តកម្មវិធីអប់រំសហគ្រិនភាពដល់យុវជនក្នុងនិងក្រៅសាលា
- រៀបចំកម្មវិធីប្រកួតប្រជែងផែនការអាជីវកម្មយុវជន
- រៀបចំបោះជំរំវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ដើម្បីលើកកម្ពស់វប្បធម៌វិទ្យាសាស្ត្រនៅក្នុងសង្គម
- បណ្តុះបណ្តាលអំពីអក្ខរកម្មហិរញ្ញវត្ថុ និងអក្ខរកម្មឌីជីថល
- បណ្តុះបណ្តាលជំនាញទន់ និងភាពជាអ្នកដឹកនាំសម្រាប់យុវជន
- បើកវគ្គបំប៉នផ្សព្វផ្សាយស្តីពី « ការងារយុវជនស្មគ្រចិត្ត » ដែលប្រព្រឹត្តិទៅចាប់ពីថ្ងៃទី ១៦ដល់ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៤ នៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡា មានសិក្ខាមចូលរួមសរុបចំនួន៥០នាក់ ស្រី៣០នាក់
- បើកវគ្គបំប៉ន « ការផ្សព្វផ្សាយការងារក្រុមប្រឹក្សាយុវជន» ដែលប្រព្រឹត្តិទៅចាប់ពីថ្ងៃទី០៨ ដល់ថ្ងៃទី០៩ ខែ កក្កដា ឆ្នាំ២០២៤ នៅកម្រងស្រែក្លែង ក្នុងស្រុកពេជ្រាដា មានសិក្ខាមចូលរួមសរុបចំនួន៥០នាក់ ស្រី២៩នាក់
- យុវជនកាយរឹទ្ធិសរុបចំនួន៥០នាក់ ស្រី៣៥នាក់ បានចូលរួមវគ្គសមាជិភាពកាយរឹទ្ធិកម្មតាមកងឯកភាពក្នុង អនុវិទ្យាល័យទួលព្រីង
- លោកគ្រូដឹកនាំ និងយុវជនចំនួន១៤នាក់ បានចូលរួមវគ្គតម្រង់ទិសយុវជនសម្រាប់អនុវត្តគម្រោងក្នុងកម្មវិធី "ផែនការអាជីកម្មខ្ញុំ" ឆ្នាំ២០២៤ តាមប្រព័ន្ធអនឡាញ
- ប្រតិភូយុវជនចំនួន ៥នាក់ស្រី ៣នាក់ចូលរួមការប្រកួតម្មវិធី "ជដែកដេញដោលយុវជនថ្នាក់ជាតិ ឆ្នាំ២០២៤"
- រៀបចំខួបលើកទី៧៥ នៃទិវាកុមារអន្តរជាតិ ០១ មិថុនា ខួបលើកទី២៣ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៤ ក្រោមប្រធានបទ "វិនិយោគលើកុមារថ្ងៃនេះ សំដៅបង្កើនមូលធន

មនុស្សក្នុងយុគសម័យបរិវត្តកម្មឌីជីថល"មានអ្នកចូលរួម ៤០០នាក់ ស្រី ២៦៧នាក់ នៅសាលាបឋមសិក្សាស្រែក្លែងស្រុកពេជ្រាដា

- ដឹកនាំប្រតិភូយុវជនចំនួន១០នាក់ ស្រី០៥នាក់ ចូលរួមវគ្គប្រកួតប្រជែងស្នាដៃយុវជនសតវត្សទី២១ ក្រោមប្រធានបទ " STEM ក្នុងវិស័យថាមពល "
- ដឹកនាំប្រតិភូយុវជនកាយរឹទ្ធិរៀមច្បងចំនួន ៦នាក់ ស្រី ០៣នាក់ ចូលរួមក្នុងកម្មវិធីបោះដំរំកាយរឹទ្ធិរៀមច្បងថ្នាក់ជាតិលើកទី២ក្រោមប្រធានបទ"ចូលរួមក្នុងកាយរឹទ្ធិកម្មដើម្បីវឌ្ឍនភាពអនាគត់របស់ខ្ញុំ " នៅខេត្តកំពង់ធំ
- ដឹកនាំប្រតិភូក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា ចំនួន ១០នាក់ ស្រី ០៦នាក់ ចូលរួមការប្រជុំបូកសរុបចលនាប្រឡងប្រណាំងបីល្អ " កូនល្អ សិស្សល្អ មិត្តល្អ " ក្រោមប្រធាបទ" ការចាប់ផ្តើមរបស់កុមារ និងយុវជន ដើម្បីក្លាយខ្លួនជាប្រជាពលរដ្ឋឌីជីថល " នៅខេត្តសៀមរាប ។

<u>អាទិភាពទី៦ ការអភិវឌ្ឍអប់រំកាយ និងកីឡា</u>

- យោងលិខិតលេខ ០៤៤ មន្ទីរអប់រំយុវជន និងកីឡាបានចេញសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីអប់រំកាយក្នុងម៉ោង និងកីឡាក្រៅម៉ោងសិក្សានៅគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សាឱ្យបានល្អប្រសើរឡើង និងមានប្រសិទ្ធិភាពស្របតាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា។
- រៀបចំលិខិតណែនាំស្តីពីការអនុវត្តកម្មវិធីអប់រំកាយក្នុងម៉ោងនិងកីឡាក្រៅម៉ោងសិក្សានៅគ្រឹះស្ថានបឋមសិក្សានិងមធ្យមសិក្សា
- រៀបចំលិខិតណែនាំស្តីពីការរៀបចំការប្រកួតកីឡាសិស្សបឋម និងមធ្យមសិក្សាថ្នាក់កម្រងក្រុង/ស្រុកនិងថ្នាក់ខេត្ត
- ជំរុញការរៀបចំការប្រកួតកីឡាសិស្សបឋមសិក្សា និងមធ្យមថ្នាក់កម្រង និង ក្រុង/ស្រុក
- រៀបចំការប្រកួតជ្រើសរើសជើងឯកថ្នាក់ខេត្តសម្រាប់កីឡាសិស្សបឋមសិក្សា និងកីឡាសិស្សមធ្យមសិក្សា និងកីឡាមហាជន ថ្នាក់ខេត្ត
- រៀបចំការប្រកួតកីឡាពានរង្វាន់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត
- ពង្រឹងការអនុវត្តសកម្មភាពអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សាឱ្យបានល្អប្រសើរ
- កៀរគរ ទាក់ទាញការចូលរួមឧបត្ថម្ភពីដៃគូវិស័យឯកជន សប្បុរជន និងអង្គការជាតិ អន្តរជាតិ។
- ដឹកនាំប្រតិភូកីឡា ចូលរួមប្រកួតកីឡាជាតិលើកទី៤
- បំផុសសមាគមន៍កីឡាមហាជនឱ្យចូលរួមប្រកួតកីឡាគ្រប់ប្រភេទ និងបង្កើតសមាគមន៍កីឡា
- ជំរុញប្រជាជនម្នាក់លេងកីឡាមួយប្រភេទយ៉ាងតិច ប្រចាំជីវិត

<u>អាទិភាពទី៧ ការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ</u>

-អនុវត្តតាមអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៩ របស់រាជរដ្ឋាភិបាល ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង.ស្រុក បានអនុវត្តលើការងារតែងតាំងប្រធាន ឬអនុប្រធានការិយាល័យក្រុង.ស្រុក (ក្នុងដែនសមត្ថកិច្ចរដ្ឋបាលក្រុង.ស្រុក)

-បានផ្ទេរបុគ្គលិក បៀវត្ស ថវិកាដំណើរការអង្គភាព និងទ្រព្យសម្បត្តិរដ្ឋនៅការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ឱ្យរដ្ឋបាល.ក្រុង.ស្រុក

-អនុវត្តតាមអនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាល ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុកសរុបចំនួន ៧៤២នាក់ ស្រី ៤០៧ នាក់ (គ្រូមត្តេយ្យសិក្សា ៣៧នាក់ ស្រី ៣៥នាក់ និងគ្រូបឋមសិក្សា ៧០៥នាក់ ស្រី ៣៧២នាក់) និងដោយឡែកសម្រាប់គ្រូជាប់កិច្ចសន្យាចំនួន ៥០នាក់ ស្រី ២៨នាក់ ក្នុងនោះគ្រូជាប់កិច្ចសន្យាអប់រំ ក្រៅប្រព័ន្ធ ១៨ នាក់ ស្រី ៧នាក់ និងគ្រូបជាប់កិច្ចសន្យាបឋមសិក្សា ៣២នាក់ ស្រី ២១នាក់ ។

-អនុវត្តការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ លើមុខងារការគ្រប់គ្រង ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និង ការអប់រំក្រៅប្រព័ន្ធ

-អនុវត្តរាល់កម្រងការកិច្ចនានាដូចមានចែងក្នុងអនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

-អនុវត្តការគ្រប់គ្រងបុគ្គលិកអប់រំ ស្ថិតិអប់រំ ការគ្រប់គ្រងហិរញ្ញវត្ថុ និង ការងារផ្សេងទៀត តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

-អនុវត្តយន្តការពិនិត្យតាមដាន និងវាយតម្លៃ ផ្អែកលើសមិទ្ធកម្ម រៀបចំរបាយការណ៍សមិទ្ធកម្ម

-ធ្វើប្រតិភូកម្ម អំណាច មុខងារ ធនធាន ផែនការសកម្មភាពនានា ដល់សាលារៀន

-អនុវត្តយន្តការទទួលព័ត៌មានត្រឡប់ និងដោះស្រាយបណ្តឹងតវ៉ានានា

-សហការលើការធ្វើអធិការកិច្ច និងសវនកម្ម

-រៀបចំផែនការតម្រូវការ និងផ្គត់ផ្គង់គ្រូបង្រៀន

-អនុវត្តការប្រើប្រាស់គ្រូបង្រៀន ផ្អែកតាមនិយាម និងគោលការណ៍ប្រើប្រាស់បុគ្គលិក

-សនិទានកម្មបុគ្គលិកតាមតម្រូវការធនធានគ្រូបង្រៀនជាពិសេសនៅតំបន់ដាច់ស្រយាល

-កំណត់តំបន់ដែលមានតម្រូវការគ្រូបង្រៀនជាអាទិភាព

-កំណត់តំបន់ជួបការលំបាកទៅតាមកម្រិតនីមួយៗ ក្នុងការផ្តល់ប្រាក់ឧបត្ថម្ភ

-អនុវត្តការប្រើប្រាស់គ្រូក្របខណ្ឌ គ្រូបង្រៀនថ្នាក់គួប គ្រូកិច្ចសន្យា ឱ្យមានប្រសិទ្ធភាព

-អភិវឌ្ឍសមត្ថភាពជូនបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់។

២.១.៣.១-ទស្សនភាពនៃការអនុវត្តស្តង់ដាសាលារៀនគំរូ

ក្នុងកិច្ចប្រជុំដំបូងរបស់គណៈរដ្ឋមន្ត្រីនីតិកាលទី៧ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់អនុសាសន៍លើការលើកកម្ពស់គុណភាពអប់រំដោយផ្តោតលើសាលារៀនតាមរយៈ៖ ១)ការពង្រឹងអភិបាលកិច្ចសាលារៀន ២)ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាព ក្រៅម៉ោងសិក្សាឱ្យស្រប ទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស ៣).ការយកចិត្តទុកដាក់លើសុខភាព របស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និង ការត្រួតពិនិត្យគុណ ភាពចំណី

អាហារនៅតាមសាលារៀន និង ៤) ការជំរុញនិងលើកទឹកចិត្តឱ្យមានការចូលរួមរបស់មាតាបិតាអ្នកអាណា ព្យាបាល និងសហគមន៍ ក្នុងការអប់រំស្របតាមពាក្យ ស្លោក " ភាពជាដៃគូរដ្ឋ និងសហគមន៍ដើម្បីការអប់រំ " ។

ដើម្បីឆ្លើយតបនឹងអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឱ្យ មានស្តង់ដាសាលា រៀនគំរូ ជាមូលដ្ឋានសម្រាប់សម្រាប់គ្រឹះស្ថានសិក្សា និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ធ្វើការវាយតម្លៃ និងកែលម្អការអនុវត្តការងារ ប្រកបដោយគណនេយ្យភាព ស្វ័យភាព និងឆន្ទៈម្ចាស់ការ ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពនៃការអប់រំ ។

២.១.៣.១.១ វឌ្ឍនភាពនៃការអនុវត្តការពង្រឹងអភិបាលកិច្ចសាលារៀន

ការពង្រឹងអភិបាលកិច្ចសាលារៀនសំដៅ ដល់ការពង្រឹងការប្រមូលកុមារចូលរៀន លទ្ធផលនៃការសិក្សា ការងារ បង្រៀន និងរៀន ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន គណនេយ្យភាពសង្គមរបស់សាលារៀន... ជាដើម។ លទ្ធផល ដែលអនុវត្តបានកន្លងមករួមមាន៖

-ប្រមូលកុមារចូលរៀនតាមរយៈការរៀបចំយុទ្ធនាការប្រមូលកុមារចូលរៀន ការរៀបចំផែនទីសិក្សា ការធ្វើ ជំរឿន ស្ថិតិប្រជាជន ការចុះប្រមូលកុមារដល់មូលដ្ឋាន អនុវត្តការអប់រំបរិយាបន្ន ការបង្កើន ថ្នាក់រៀន សាងសង់អគារ សិក្សា បណ្ណាល័យបង្កើតសាលារៀនបន្ថែមឱ្យដល់មូលដ្ឋាន។
-បានរៀបចំតេស្តផ្នាំវាយតម្លៃសមត្ថភាពសិស្ស ការជួយគាំទ្រសិស្ស ពិសេសសិស្សមានតម្រូវការ ការផ្តល់ អាហារូប ករណ៍ អាហារូបត្ថម្ភ ចុះកិច្ចព្រមព្រៀងជាមួយសិស្ស អាណាព្យាបាលសិស្ស ប្រជុំជាមួយ អ្នក អាណាព្យាបាល សិស្ស ផ្តល់សម្ភារៈសិក្សាដល់សិស្សក្រីក្រ...ដើម្បីធានាបានសមធម៌ ក្នុងការទទួលបាន ចំណេះដឹង និងកាត់ បន្ថយអត្រាត្រួតថ្នាក់ និង អត្រាបោះបង់ការសិក្សា ។
-រៀបចំផែនការថ្នាក់រៀន អនុវត្តវិធីសាស្ត្រថ្មីៗដូចជា ការសិក្សាតាមបែបគម្រោង ការសិក្សាស្របតាម សមត្ថភាពសិស្សម្នាក់ៗ អនុវត្តម៉ោងសិក្សាស្របតាមការណែនាំ ការផ្តល់ព័ត៌មានប្រឡប់ ដល់សិស្ស បង្រៀន កម្មវិធី បន្ថែម ដូចជាកុំព្យូទ័រ ភាសាអង់គ្លេស (មត្តេយ្យសិក្សា) បំណិនជីវិតតាមមូលដ្ឋាន ការអប់រំ សីលធម៌ ចរិយាធម៌ មានសម្ភារៈបង្រៀនគ្រប់គ្រាន់...។
-សាលារៀនបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រ ថវិកា ផែនការថវិកាប្រចាំឆ្នាំ រៀបចំគណៈកម្មការគ្រប់គ្រងសាលារៀន រៀបចំរដ្ឋបាលសាលារៀន ថ្នាក់រៀនបាន ប្រសើរ កែលម្អហេដ្ឋារចនាសម្ព័ន្ធ សាលារៀន...។
-ផ្សព្វផ្សាយលទ្ធផលនៃការសិក្សារបស់សិស្ស ចំណូល-ចំណាយរបស់សាលារៀនជាសាធារណៈ ចូលរួម វេទិការសាធារណៈ និងកិច្ចប្រជុំផ្សេង ៗ របស់អាជ្ញាធរមូលដ្ឋាន។
-ការិយាល័យអធិការកិច្ចបានចូលរួមសហការជាមួយការិយាល័យជំនាញពាក់ព័ន្ធក្នុងមន្ទីរ ចុះជួយគាំទ្រស្តង់ ដាសាលារៀនគំរូ នៅមត្តេយ្យសិក្សាចំនួន ០៣សាលា(មត្តេយ្យធនធានអូរអោម មត្តេយ្យសិក្សាស្រែព្រះ និង មត្តេយ្យធនធាន ហ៊ុន សែន កោះញែក)

-អនុវត្តតេស្តវាយតម្លៃលទ្ធផលសិក្សាកម្រិតបឋមសិក្សាថ្នាក់តំបន់អាស៊ីអាគ្នេយ៍(SEA-PLM)ថ្នាក់ទី៥ដែលមានសិស្សចូលរួមធ្វើតេស្តសរុប ៣៥៩នាក់ ស្រី ១៩៣នាក់

-ចុះតេស្តអំណាន និងគណិតវិទ្យាថ្នាក់ដំបូង-ថ្នាក់ទី១ (EGMA&EGRA)ដល់សិស្សសរុបចំនួន ៦៦នាក់ ស្រី ៣១នាក់

-ចូលរួមសហការជាមួយនាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ ចុះធ្វើអធិការកិច្ច និងគាំទ្រស្តង់ដាសាលារៀនគំរូ នៅវិទ្យាល័យអូររាំង ក្នុងស្រុកអូររាំង

-ចូលរួមសហការជាមួយនាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ ចុះធ្វើអធិការកិច្ច និងគាំទ្រស្តង់ដាសាលារៀនគំរូនៅសាលាមត្តេយ្យធនធានស្រុកមេមត់ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

-ចូលរួមសហការជាមួយការិយាល័យជំនាញពាក់ព័ន្ធក្នុងមន្ទីរ ចុះជួយគាំទ្រស្តង់ដាសាលារៀនគំរូ នៅមធ្យមសិក្សាចំនួន ០៤សាលា(វិទ្យាល័យហ៊ុន សែនកែវសីមា វិទ្យាល័យហ៊ុន សែនកោះញែក អនុវិទ្យាល័យស្រែព្រះ និងអនុវិទ្យាល័យសុខសាន្ត)។

-ចូលរួមសហការជាមួយការិយាល័យជំនាញពាក់ព័ន្ធក្នុងមន្ទីរ ចុះជួយគាំទ្រស្តង់ដាសាលារៀនគំរូ នៅបឋមសិក្សាចំនួន ០៣សាលា(បឋមសិក្សាស្រែក្លែង បឋមសិក្សាប៊ូរ៉ាង និងបឋមសិក្សាពូហ្សាម)

២.១.៣.១.២ វឌ្ឍនភាពនៃការអនុវត្តការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោង សិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស

-រៀបចំក្លឹបសិក្សាជួយសិស្សរៀនយឺត ជំរុញឱ្យសិស្សអនុវត្តស្វ័យសិក្សា ដាក់កិច្ចការផ្ទះសម្រាប់សិស្ស អនុវត្តសិក្សាស្រាវជ្រាវបន្ថែម និងសកម្មភាពបណ្ណាល័យ

-ប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍ និងធ្វើថ្នាក់និទស្សន៍ប្រចាំខែនៅតាមសាលារៀនគ្រប់កម្រិតសិក្សា

-បញ្ចូលការអប់រំសីលធម៌ ចរិយាធម៌ នៅក្នុងកាលវិភាគសិក្សា

-លើកទឹកចិត្តសិស្សចូលរួមការងារសង្គមនានា

-ចុះពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សានៅកម្រិតសាលារៀន ថ្នាក់រៀនជាប្រចាំ

-ធ្វើអធិការកិច្ចសាលារៀន ដោយភ្ជាប់ជាមួយការធ្វើតេស្តសមត្ថភាពសិស្ស ។

-ការអប់រំសីលធម៌ សុភាវធម៌ ចរិយាធម៌(ស្អាត សុភាព របៀប ទៀងពេល និងសមាធិ) និងការអប់រំតាមបែបសាសនា

២.១.៣.១.៣ វឌ្ឍនភាពនៃការអនុវត្តការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភ ដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន

-ផ្តល់អាហារូបករណ៍បឋមសិក្សា និងមធ្យមសិក្សា

-អនុវត្តកម្មវិធីស្បៀងអាហារពេលព្រឹកដោយប្រើប្រាស់កសិផលក្នុងសហគមន៍

-រៀបចំបន្ទប់សុខភាព បំពាក់ប្រអប់សង្គ្រោះបឋម តាមសាលារៀន

-ណែនាំសាលារៀនអំពីការត្រៀមខ្លួនជាមុនបង្ការផលប៉ះពាល់ពីគ្រោះមហន្តរាយនានា

-ផ្តល់ថ្នាំបង្ការជំងឺនានាដល់សិស្ស ដោយសហការជាមួយវិស័យសុខាភិបាល
-អនុវត្តសកម្មភាពអប់រំកាយ និងកីឡាក្នុងម៉ោងសិក្សា និងក្រៅម៉ោងសិក្សា
-ពង្រីកហេដ្ឋារចនាសម្ព័ន្ធអប់រំកាយ និងកីឡា ហេដ្ឋារចនាសម្ព័ន្ធអនាម័យ និងសុខភាពតាមសាលារៀន
-សហការចុះផ្សព្វផ្សាយនិងត្រួតពិនិត្យលើគុណភាពចំណីអាហារ ការងារសុខភាព អនាម័យ ការនុវត្ត សកម្មភាព អប់រំកាយ និងកីឡាតាមសាលារៀន
-បែងចែកសៀវភៅសិក្សាគោលអប់រំកាយ និងកីឡាដល់សាលារៀន
-រៀបចំតម្រូវការបង្គន់អនាម័យ កន្លែងលាងសម្អាតដៃ ប្រព័ន្ធទឹកស្អាត និងសម្ភារកីឡា។
-បំប៉នសមត្ថភាពដល់នាយក/នាយិកាសាមគ្គេយ្យសិក្សាបឋមសិក្សា និងមធ្យមសិក្សាក្នុងខេត្តមណ្ឌលគិរីបាន ចំនួន ៣វគ្គ ស្តីពីការលើកម្ពស់សុខភាពសិក្សា និងវាស់គំហើញ ការគណនាសន្ទស្សន៍ម៉ាស់រាងកាយបានចំនួន ៧៣សាលា មានសមាសភាពចូលរួមចំនួន ៨៩នាក់ ស្រី ៣៦នាក់ និង បានបំប៉នវិធីសាស្ត្រ និងប្រើប្រាស់ សៀវភៅសិក្សាគោល ការបង្រៀនមុខវិជ្ជា "អប់រំសុខភាព"ថ្នាក់ទី៥ ទី៦ ទី៨ ទី៩ ទី១១ និងទី១២ តាមប្រព័ន្ធ អនឡាញ ផ្នែកបឋមបានចំនួន ៥៥នាក់ ស្រី ២១នាក់ និងក្នុងនោះមានគ្រូមធ្យមសិក្សាបានចូលរួមសរុប ចំនួន ៣៥នាក់ និង ស្រី ១៧នាក់
-បានបញ្ចប់ការសាងសង់បង្គន់អនាម័យដែលគាំទ្រដោយអង្គការ ក្លែនកម្ពុជា ចំនួន ៤ ខ្នងសាលាពហុភាសា (១ខ្នងមាន៣បន្ទប់)និងអាងទឹកចំណុះ ៣០០០លីត្រចំនួន ០២ ចំណាយទឹកប្រាក់ចំនួន ៖ ១១០.៤០០.០០០ ៛
-បានសាងសង់បង្គន់អនាម័យចំនួន ៦សាលា មាន ៨ខ្នង ស្មើនឹង ១៨បន្ទប់ គាំទ្រដោយថិការដ្ឋាភិបាល ចំណាយថវិកាសរុបចំនួន ១១០.៤០០០.០០០៛
-បានផ្តល់ថ្នាំទម្លាក់ព្រូនដល់សិស្សានុសិស្សទាំង២លើកបានប្រមាណ ៤៧% ទូទាំងខេត្ត
-បានចាក់វ៉ាក់សាំងការពារមហារីកដៃស្បូនដល់កុមារីអាយុ៩ឆ្នាំ បានចំនួន ៦៧%
-ការបង្រៀនមុខវិជ្ជាអប់រំសុខភាពតាមគ្រឹះស្ថានសិក្សាសាធារណៈទូទាំងខេត្ត បានចំនួន៣៩% នៃផែនការ ប្រចាំឆ្នាំ

២.១.៣.១.៤ វឌ្ឍនភាពនៃការអនុវត្តការជំរុញ និងការលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូរដ្ឋ និងសហគមន៍ដើម្បីការអប់រំ

-អនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន នៅតាមសាលារៀនគោល និងសាលារៀនសហការ
-កៀរគរសប្បុរសជន អង្គការដៃគូរនានា គាំទ្រលើការអភិវឌ្ឍសាលារៀនទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ សម្ភារ គាំទ្រដល់ការបង្រៀន និងរៀន សម្រាប់ការអភិវឌ្ឍសមត្ថភាពដល់គណៈគ្រប់គ្រងសាលា គ្រូបង្រៀន សិស្ស
-រៀបចំគណៈគ្រប់គ្រងសាលារៀន ដោយមានសមាសភាពចូលរួមពីអាជ្ញាធរមូលដ្ឋាន សហគមន៍សាលា រៀន និងអ្នកពាក់ព័ន្ធផ្សេងទៀត
-រៀបចំការប្រជុំនានាដោយមានការចូលរួមពីសហគមន៍ និងអ្នកពាក់ព័ន្ធ ជាប្រចាំ

-រៀបចំគណៈកម្មការគ្រប់គ្រងថ្នាក់រៀនដែលមានសមាសភាពអាណាព្យាលបាលសិស្ស
-រៀបចំផែនការអភិវឌ្ឍន៍សាលារៀន និងផ្សព្វផ្សាយ ស្វែងរកការចូលរួមគាំទ្រ ពីសហគមន៍
-សហការប្រមូលកុមារចូលរៀន និងចូលរួមទប់ស្កាត់មុខសញ្ញាសិស្សបោះបង់ការសិក្សា ។

២.១.៣.២ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់គ្រូបង្រៀន

-បន្តអនុវត្តការជ្រើសរើសបេក្ខជនសម្រាប់ប្រឡងប្រជែងក្នុងប្រខ័ណ្ឌគ្រូបង្រៀន ទៅបណ្តុះបណ្តាលតាមរូបមន្ត (១២+២ និង១២+៤ បរិញ្ញាបត្រ+១ និងបរិញ្ញាបត្រ+២)
-បញ្ជូននាកសាលា និងគ្រូបង្រៀននៅតាមសាលាគោលដៅរបស់គម្រោង GEIP ទៅបន្តការសិក្សានៅសាលាភូមិន្ទភ្នំពេញ ដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រគ្រប់គ្រងអប់រំ
-បញ្ជូនបុគ្គលិកអប់រំចំនួន ២នាក់ ទៅរៀនវគ្គអធិការអប់រំ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ
-ចូលរួមកម្មវិធីលើកកម្ពស់គណៈគ្រប់គ្រងសាលារៀន MA-LUP ចំនួន ០៤ នាក់ស្រី ០០នាក់
-ចូលរួមកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន MA-TUP ចំនួន ១១នាក់ស្រី ០១នាក់ ។
-ចូលរួមកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀនBA-LUP ចំនួន ៣៦ នាក់ស្រី ២៣ នាក់ ។
-ចូលរួមកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ៤ ក្រឹត ក្នុងនោះ មាន កុមារតូច ០៨ នាក់ ស្រី ០៧ នាក់ បឋម ៤២ នាក់ ស្រី ០៧ នាក់ ។

២.១.៣.៣ ការអប់រំឌីជីថល

-ការធ្វើទស្សនកិច្ចសិក្សាដងស្រង់បទពិសោធន៍លើការគ្រប់គ្រងដឹកនាំ និងការអនុវត្តកម្មវិធីសិក្សាតាមបែបស្ទើមនៅសាលាធនធាន
-ការបំពាក់សម្ភារៈពិសោធន៍តាមសាលារៀនគោលដៅ
-ការពង្រឹងសកម្មភាពរបស់សាលាធនធាន និងសាលា
-ពង្រឹងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរបស់របស់សាលាធនធាន
-អនុវត្តម៉ោងសិក្សាបន្ថែមផ្អែកលើមុខវិជ្ជាសំខាន់ៗចាំបាច់
-ការប្រឡងប្រណាំងគ្រូល្អ នាយកល្អ សាលាល្អ និងសាលាស្អាត
-ពង្រឹងលើការបង្រៀនរបស់គ្រូគ្រប់មុខវិជ្ជា ការរៀបចំកិច្ចតែងការបង្រៀន ការប្រើប្រាស់សម្ភារឧបទេស
-អនុវត្តវិធីសាស្ត្របង្រៀនវិទ្យាសាស្ត្រផ្អែកលើគោលវិធីស្ទើម រួមមាន ការប្រើប្រាស់រោងជាង កុំព្យូទ័រ ប្រព័ន្ធបច្ចេកវិទ្យា និងបន្ទប់ពិសោធន៍
-សាលាអនុវត្តគម្រោង SEIP CARE និងអគារធនធានបានបំពាក់សម្ភារឧបទេស និងការធ្វើពិសោធន៍
-គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅសាលាធនធាន និងកម្រងវិទ្យាល័យ អូររាំងបានចូលរួមបំប៉នលើផ្នែកបង្រៀនពិសោធន៍តាមរយៈគ្រូបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិអប់រំ
-រៀបចំយន្តការដើម្បីអនុវត្តការគ្រប់គ្រងតាមសាលារៀន៖ ១).ការរៀបចំការធ្វើតេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ២).ការរៀបចំផែនការកែលម្អសាលារៀន ៣).ការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន ៤).ការរៀបចំកិច្ចព្រមព្រៀងលទ្ធផលបំពេញការងារគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀន

-ធ្វើអធិការកិច្ច និងពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តការអប់រំនៅតាមគ្រឹះស្ថានមធ្យមសិក្សា

-បានរៀបចំកម្មវិធីពិព័ណ៌ស្នាដៃសិស្សផ្នែក STEM និងគណិតវិទ្យាក្នុងខែមករា ឆ្នាំ ២០២៤ នៅវិទ្យាល័យ ជ្រោះប៊ូស្រា ដោយមានវិទ្យាល័យ ហ៊ុន សែន កោះញែក និងវិទ្យាល័យ ហ៊ុន សែន កែវសីមា ដែលមានការឧបត្ថម្ភគាំទ្រពីអង្គការ ខេប កម្ពុជា រយៈពេល១ថ្ងៃ។

-ថ្នាក់អក្ខរកម្មវិជ្ជាជីវៈត្រូវបានសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច ៖តាមរយៈហ្វេសប៊ុក យូធូប តេឡេក្រាម

-បានជំរុញ និងលើកទឹកចិត្តដល់អ្នកសិក្សាឱ្យចូលទៅស្វ័យសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច និងប្រព័ន្ធផ្សព្វផ្សាយផ្លូវការរបស់ក្រសួងអប់រំយុវជននិងកីឡាដូចជា៖(Facebook:https://www.facebook.com/krou.moeys.gov.kh/ YouTube:https://www.youtube.com/moeys)

-វេទិកាសិក្សាតាមអេឡិត្រូនិច (E-Learning) ផ្លូវការរបស់ក្រសួងអប់រំ)

-កម្មវិធីអក្ខរកម្ម សមមូលបឋមសិក្សា ដែលមានតំណភ្ជាប់ (https://eleaning.moeys.gov.kh)

-ថ្នាក់សមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណេត ត្រូវបានសិក្សាតាមកម្មវិធី ប៊ីប ដែលមានតំណ (https://lsep. moeys.gov.kh)

២.១.៣.៤ ការអភិវឌ្ឍយុវជន

-ពង្រឹងការងារសហគ្រិនភាពតាមរយៈការអនុវត្តកម្មវិធីអប់រំសហគ្រិនភាពដល់យុវជនក្នុងនិងក្រៅសាលា

-រៀបចំកម្មវិធីប្រកួតប្រជែងផែនការអាជីវកម្មយុវជន

-រៀបចំបោះជំរំវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ដើម្បីលើកកម្ពស់វប្បធម៌វិទ្យាសាស្ត្រនៅក្នុងសង្គម

-បណ្តុះបណ្តាលអំពីអក្ខរកម្មហិរញ្ញវត្ថុ និងអក្ខរកម្មឌីជីថល

-បណ្តុះបណ្តាលជំនាញទន់ និងភាពជាអ្នកដឹកនាំសម្រាប់យុវជន

-បើកវគ្គបំប៉នផ្សព្វផ្សាយស្តីពី«ការងារយុវជនស្មគ្រចិត្ត»នៅថ្នាក់ក្រុង/ស្រុក ដែលប្រព្រឹត្តិទៅចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០២៤ នៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡា មានសិក្ខាមចូលរួមសរុបចំនួន៥០នាក់ ស្រី៣០នាក់

-បើកវគ្គបំប៉ន«ការផ្សព្វផ្សាយការងារក្រុមប្រឹក្សាយុវជនថ្នាក់ក្រុង/ស្រុក» ដែលប្រព្រឹត្តិទៅចាប់ពីថ្ងៃទី០៨ដល់ថ្ងៃទី០៩ ខែ កក្កដា ឆ្នាំ២០២៤ នៅកម្រងស្រែក្លែង ក្នុងស្រុកពេជ្រាដា មានសិក្ខាមចូលរួមសរុបចំនួន៥០នាក់ ស្រី២៩នាក់

-យុវជនកាយរឹទ្ធិចំនួន ៥០ នាក់ស្រី ៣៥ នាក់បានចូលរួមវគ្គសមាជិភាពកាយរឹទ្ធិកម្មតាមកងឯកភាពក្នុងអនុវិទ្យាល័យទួលព្រីង

- លោកគ្រូដឹកនាំ និងយុវជនចំនួន១៤នាក់ បានចូលរួមវគ្គតម្រង់ទិសយុវជនសម្រាប់អនុវត្តគម្រោងក្នុងកម្មវិធី "ផែនការអាជីកម្មខ្ញុំ" ឆ្នាំ២០២៤ តាមប្រព័ន្ធអនឡាញ
- ប្រតិភូយុវជន ចំនួន០៥នាក់ ស្រី ០៣នាក់ ចូលរួមការប្រកួតម្មវិធី " ជជែកដេញដោលយុវជនថ្នាក់ជាតិ ឆ្នាំ២០២៤ "

- រៀបចំខួបលើកទី៧៥ នៃទិវាកុមារអន្តរជាតិ ០១ មិថុនា ខួបលើកទី២៣ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៤ ក្រោមប្រធានបទ "វិនិយោគលើកុមារថ្ងៃនេះ សំដៅបង្កើនមូលធនមនុស្សក្នុងយុគសម័យបរិវត្តកម្មឌីជីថល"មានអ្នកចូលរួម ៤០០នាក់ ស្រី ២៦៧នាក់ នៅសាលាបឋមសិក្សាស្រែក្លែងស្រុកពេជ្រាដា
- ដឹកនាំប្រតិភូយុវជនចំនួន១០នាក់ ស្រី០៥នាក់ ចូលរួមវគ្គប្រកួតប្រជែងស្នាដៃយុវជនសតវត្សទី២១ ក្រោមប្រធានបទ " STEM ក្នុងវិស័យថាមពល "
- ដឹកនាំប្រតិភូយុវជនកាយរឹទ្ធិរៀមច្បងចំនួន ៦នាក់ ស្រី ០៣នាក់ ចូលរួមក្នុងកម្មវិធីបោះដំរំកាយរឹទ្ធិរៀមច្បងថ្នាក់ជាតិលើកទី២ក្រោមប្រធានបទ"ចូលរួមក្នុងកាយរឹទ្ធិកម្មដើម្បីវឌ្ឍនភាពអនាគត់របស់ខ្ញុំ " នៅខេត្តកំពង់ធំ
- ដឹកនាំប្រតិភូក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា ចំនួន ១០នាក់ ស្រី ០៦នាក់ ចូលរួមការប្រជុំបូកសរុបចលនាប្រឡងប្រណាំងបីល្អ " កូនល្អ សិស្សល្អ មិត្តល្អ " ក្រោមប្រធាបទ" ការចាប់ផ្តើមរបស់កុមារ និងយុវជន ដើម្បីក្លាយខ្លួនជាប្រជាពលរដ្ឋឌីជីថល " នៅខេត្តសៀមរាប ។

២.១.៣.៥ ការអភិវឌ្ឍអប់រំកាយ និងកីឡា

-យោងលិខិតលេខ ០៤៤ មន្ទីរអប់រំយុវជន និងកីឡាបានចេញសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីអប់រំកាយក្នុងម៉ោង និងកីឡាក្រៅម៉ោងសិក្សានៅគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សាឱ្យបានល្អប្រសើរឡើង និងមានប្រសិទ្ធិភាពស្របតាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា។

-រៀបចំលិខិតណែនាំស្តីពីការអនុវត្តកម្មវិធីអប់រំកាយក្នុងម៉ោង និងកីឡាក្រៅម៉ោងសិក្សានៅគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សា

-រៀបចំលិខិតណែនាំស្តីពីការរៀបចំការប្រកួតកីឡាសិស្សបឋម និងមធ្យមសិក្សាថ្នាក់កម្រងក្រុង/ស្រុកនិងថ្នាក់ខេត្ត

-ជំរុញការរៀបចំការប្រកួតកីឡាសិស្សបឋមសិក្សា និងមធ្យមថ្នាក់កម្រង និង ក្រុង/ស្រុក

-រៀបចំការប្រកួតជ្រើសរើសជើងឯកថ្នាក់ខេត្តសម្រាប់កីឡាសិស្សបឋមសិក្សា និងកីឡាសិស្សមធ្យមសិក្សា និង កីឡាមហាជន ថ្នាក់ខេត្ត

-រៀបចំការប្រកួតកីឡាពានរង្វាន់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត

-ពង្រឹងការអនុវត្តសកម្មភាពអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សាឱ្យបានល្អប្រសើរ

-កៀរគរ ទាក់ទាញការចូលរួមឧបត្ថម្ភពីដៃគូវិស័យឯកជន សប្បុរជន និងអង្គការជាតិ អន្តរជាតិ

-ដឹកនាំប្រតិភូកីឡា ចូលរួមប្រកួតកីឡាជាតិលើកទី៥

-បំផុសសមាគមន៍កីឡាមហាជនឱ្យចូលរួមប្រកួតកីឡាគ្រប់ប្រភេទ និងបង្កើតសមាគមន៍កីឡា

-ជំរុញប្រជាជនម្នាក់លេងកីឡាមួយប្រភេទយ៉ាងតិច ប្រចាំជីវិត

២.១.៣.៦ ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព

គុណភាព និងប្រសិទ្ធភាពនៃស្ថាប័នអប់រំជាកត្តាចាំបាច់មួយក្នុងការអភិវឌ្ឍវិស័យអប់រំឱ្យទាន់តម្រូវការនៃអ្នកសិក្សាក្នុងយុគបដិវត្តន៍ឧស្សាហកម្ម ។ កត្តានេះទាមទារឱ្យថ្នាក់ដឹកនាំ និងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ពង្រឹង

សមត្ថភាពទាំងផ្នែកចំណេះដឹងថ្មីៗ វិធីសាស្ត្របង្រៀន ការអប់រំឌីជីថល ការអប់រំកាសា...-ល- និងទាមទារឱ្យមានការគាំទ្រ លើកទឹកចិត្តពីសំណាក់ថ្នាក់ដឹកនាំផងដែរ។

-ចូលរួមវគ្គបំប៉ន សិក្ខាសាលា ការសិក្សាស្រាវ ជ្រាវនានា ដូចជា ការអប់រំឌីជីថល ការរៀបចំផែនការ ការគ្រប់គ្រងដឹកនាំ វិធីសាស្ត្របង្រៀន ការងារបច្ចេកទេសនានា...ល។ចុះពិនិត្យតាម ការធ្វើអធិការកិច្ច ការសម្របសម្រួល និង គាំទ្របច្ចេកទេសលើការងារនានា ក៏ចូលរួមចំណែកពង្រឹងសមត្ថភាព ដល់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ផង តាមរយៈការផ្តល់ព័ត៌មានត្រឡប់ ឬរបាយការណ៍

-ការវាយតម្លៃការងារការតម្លើងឋានន្តរស័ក្តិការវាយតម្លៃនាយកល្អគ្រូបង្រៀនល្អ សាលារៀនស្អាត ការស្នើសុំមេដាយការងារជូនបុគ្គលិកអប់រំ ការធ្វើបម្រែបម្រួលស្ថានភាព បុគ្គលិកអប់រំ ជាដើម

-ផ្សព្វផ្សាយឱកាសប្រឡងប្រជែងនានា ការផ្តល់អាហារូបករណ៍ ទៅបន្តការសិក្សា និងវគ្គបំប៉ន វគ្គបណ្តុះបណ្តាល ដល់បុគ្គលិកអប់រំនៅក្នុងខេត្ត

-បានចូលរួមក្នុងវគ្គបំប៉នពីចម្ងាយតាមរយៈ(ZOOM)ពង្រឹងការរៀបចំផែនការថវិកាសមិទ្ធកម្ម ដោយកំណត់សូចនាករ ដើម្បីបន្សុីនឹងការងាររបស់នាយកដ្ឋាន/អង្គភាពរបស់ខ្លួន

-ពង្រឹងការរៀបចំ និងការអនុវត្តសកម្មភាពឱ្យឆ្លើយតបទៅនឹងចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣

-រៀបចំផែនការសកម្មភាពឱ្យឆ្លើយតបទៅនឹងគោលនយោបាយអប់រំដែលបានកំណត់

-ដំរុញការអនុវត្តក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃនៃការអនុវត្តថវិកាសមិទ្ធកម្ម

២.១.៤-ទស្សនភាពនៃការគ្រប់គ្រង និងអនុទត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ

២.១.៤.១ វឌ្ឍនភាពនៃការអនុវត្តផែនការ ស្ថិតិ និងការពិនិត្យតាមដានវាយតម្លៃ

-បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំខេត្ត ឆ្នាំ២០២៤-២០២៨ និងធ្វើការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ(ថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក និងសាលារៀន)

-បានចុះសម្របសម្រួលនៅតាមសាលារៀនគ្រប់កម្រិតសិក្សា ដើម្បីណែនាំ និងតម្រង់ទិសស្តីពីការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៥ ដល់រដ្ឋបាលក្រុង ស្រុក និងសាលារៀនគ្រប់កម្រិតសិក្សា

-រៀបចំចងក្រង និងបោះពុម្ពប័ណ្ណផ្ទត់ព័ត៌មាន ស្តីពីស្ថិតិ និងសូចនាករអប់រំប្រចាំឆ្នាំ២០២៤

-ពិនិត្យតាមដាន ការរៀបចំផែនការសាលារៀន និងការរៀបចំរបាយការណ៍សមិទ្ធកម្ម

-ពង្រឹងសមត្ថភាពនាយក នាយិកាសាកលា លើការងាររៀបចំធ្វើផែនការតម្រូវការសៀវភៅសិក្សា និងការងារប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

២.១.៤.២ វឌ្ឍនភាពនៃការអនុវត្តហិរញ្ញប្បទានសហប្រតិបត្តិការ

-ផ្តល់របាយការណ៍ធាតុចូលសម្រាប់កម្មវិធីវិនិយោគបីឆ្នាំរំកិល របស់រដ្ឋបាលខេត្ត

-ផ្តល់ និងអនុវត្តកិច្ចព្រមព្រៀងលើកម្មវិធីវិនិយោគឃុំ សង្កាត់

-ចូលរួមសមាហរណកម្មថ្នាក់ក្រុង ស្រុក ដើម្បីគាំទ្រសកម្មភាពអប់រំមួយចំនួនទៅក្នុងកម្មវិធីវិនិយោគ របស់រដ្ឋបាលឃុំ សង្កាត់

-រៀបចំគម្រោងរបស់មន្ទីរអប់រំ យុវជន និងកីឡា ដើម្បីដាក់បញ្ចូលសកម្មភាពទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំ របស់ខេត្ត ដោយមានគម្រោងសរុប ២៦គម្រោង

-រៀបចំលិខិតគាំទ្រស្នើសុំទៅក្រសួងអប់រំ យុវជន និងកីឡា ជូនអង្គការចំនួន ៣គឺ អង្គការ UWS អង្គការ Good Neighbors និងអង្គការ WeWorld ដើម្បីបន្តសកម្មភាពក្នុងការអភិវឌ្ឍវិស័យអប់រំក្នុងខេត្ត

-ទទួលរបាយការណ៍លទ្ធផលសកម្មភាពការងាររបស់អង្គការនានាដែលបានអនុវត្តសកម្មភាពក្នុងខេត្ត

-បញ្ចូលទិន្នន័យគម្រោងរបស់អង្គការដៃគូដែលបានអនុវត្តសកម្មភាពក្នុងខេត្តទៅក្នុងប្រព័ន្ធ AMIS

២.១.៤.៣ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

-អនុវត្តតាមអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៩ របស់រាជរដ្ឋាភិបាល ស្តីពី មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង.ស្រុក បានអនុវត្តលើការងារតែងតាំងប្រធាន ឬអនុប្រធានការិយាល័យក្រុង.ស្រុក (ក្នុងដែនសមត្ថកិច្ចរដ្ឋបាលក្រុង.ស្រុក)

-បានផ្ទេរបុគ្គលិក បៀវត្ស ថវិកាដំណើរការអង្គភាព និងទ្រព្យសម្បត្តិរដ្ឋនៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ឱ្យរដ្ឋបាល.ក្រុង.ស្រុក

-អនុវត្តតាមអនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាល ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុកសរុបចំនួន ៧៤២នាក់ ស្រី ៤០៧ នាក់ (គ្រូមត្តេយ្យសិក្សា ៣៧នាក់ ស្រី ៣៥នាក់ និងគ្រូបឋមសិក្សា ៧០៥នាក់ ស្រី ៣៧២នាក់) និងដោយឡែកសម្រាប់គ្រូជាប់កិច្ចសន្យាចំនួន ៥០នាក់ ស្រី ២៨នាក់ ក្នុងនោះគ្រូជាប់កិច្ចសន្យាអប់រំ ក្រៅប្រព័ន្ធ ១៨ នាក់ ស្រី ៧នាក់ និងគ្រូបជាប់កិច្ចសន្យាបឋមសិក្សា ៣២នាក់ ស្រី ២១នាក់ ។

២.១.៤.៤ វឌ្ឍនភាព នៃការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ

-អនុវត្តការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ លើមុខងារការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និង ការអប់រំក្រៅប្រព័ន្ធ

-អនុវត្តរាល់កម្រងភារកិច្ចនានាដូចមានចែងក្នុងអនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

-អនុវត្តការគ្រប់គ្រងបុគ្គលិកអប់រំ ស្ថិតិអប់រំ ការគ្រប់គ្រងហិរញ្ញវត្ថុ និង ការងារផ្សេងទៀត តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

-អនុវត្តយន្តការពិនិត្យតាមដាន និងវាយតម្លៃ ផ្អែកលើសមិទ្ធកម្ម រៀបចំរបាយការណ៍សមិទ្ធកម្ម

-ធ្វើប្រតិភូកម្ម អំណាច មុខងារ ធនធាន ផែនការសកម្មភាពនានា ដល់សាលារៀន

-អនុវត្តយន្តការទទួលព័ត៌មានត្រឡប់ និងដោះស្រាយបណ្តឹងតវ៉ានានា

-សហការលើការធ្វើអធិការកិច្ច និងសវនកម្ម

-រៀបចំផែនការតម្រូវការ និងផ្តត់ផ្តង់គ្រូបង្រៀន

-អនុវត្តការប្រើប្រាស់គ្រូបង្រៀន ផ្អែកតាមនិយាម និងគោលការណ៍ប្រើប្រាស់បុគ្គលិក

-សនិទានកម្មបុគ្គលិកតាមតម្រូវការធនធានគ្រូបង្រៀនជាពិសេសនៅតំបន់ដាច់ស្រយាល

-កំណត់តំបន់ដែលមានតម្រូវការគ្រូបង្រៀនជាអាទិភាព

-កំណត់តំបន់ជួបការលំបាកទៅតាមកម្រិតនីមួយៗ ក្នុងការផ្តល់ប្រាក់ឧបត្ថម្ភ

-អនុវត្តការប្រើប្រាស់គ្រូក្របខណ្ឌ គ្រូកិច្ចសន្យា ឱ្យមានប្រសិទ្ធភាព

-អភិវឌ្ឍសមត្ថភាពជូនបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់។

២.១.៤.៥ វឌ្ឍនភាព នៃការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

-រៀបចំផែនការថវិកាប្រចាំឆ្នាំ និងផែនការរំកិល៣ឆ្នាំ ជាយន្តការសម្រាប់ការអនុវត្ត និង ប្រើប្រាស់ថវិកាប្រកបដោយប្រសិទ្ធភាព

-ធ្វើការបែងចែកថវិកាដំណើរការសាលារៀនទៅតាមសាលារៀនបានទាន់ពេលវេលា

-ផ្តល់ស្វ័យភាពក្នុងការរៀបចំផែនការថវិកា និងផែនការប្រតិបត្តិដល់កម្រិតសាលារៀន

-ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យានៅកម្រិតសាលារៀន

-សម្របសម្រួលការងារជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការទម្លាក់ថវិកា និងសម្របសម្រួលនីតិវិធីចំណាយ និងទូទាត់ឯកសារ

-ណែនាំដល់មន្ត្រីអប់រំក្រុង ស្រុក និងគណៈគ្រប់គ្រងសាលារៀនស្តីពីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមប្រព័ន្ធថ្មីដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា។

-ចុះណែនាំដល់សាលាក្នុងការធ្វើរបាយការណ៍ចំណាយថវិកា កិច្ចបញ្ជីការ ទាំង៦ រៀបចំគណៈកម្មការសាលា និងផែនការផ្សេងៗ សម្រាប់សាលា អនុវត្តឱ្យបានច្រើនសាលា និង៥ ក្រុង/ស្រុក។

-បើកវគ្គបំប៉នកិច្ចបញ្ជីកាគណនេយ្យដល់នាយក ហិរញ្ញិកសាលា និងការិយាល័យអប់រំ ក្រុង/ស្រុក និងការិ. មន្ទីរឱ្យបានគ្រប់សាលា ដោយប្រមូលផ្តុំនៅតាមស្រុក

២.១.៤.៦ វឌ្ឍនភាពនៃការអនុវត្តហេដ្ឋារចនាសម្ព័ន្ធអប់រំ

-បានរៀបចំតារាងស្ថិតិសាលារៀនដែលចាស់ទ្រុឌទ្រោមផ្ញើទៅក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានសំណង់)

-កំណត់ពីទីតាំងដែលត្រូវសាលាសង់សាលារៀនគ្រប់កម្រិតសិក្សានាពេលខាងមុខ

-ជួសជុលអគារសាលារៀនដែលចាស់ទ្រុឌទ្រោមនៅតាមតំបន់ដាច់ស្រយាល

-រៀបចំគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីធ្វើរបងសាលារៀនដែលមានបញ្ហាដីធ្លីជាមួយប្រជាជន

២.១.៤.៧ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤

មន្ទីរអប់រំ យុវជន និងកីឡា បានរួមគ្នារៀបចំចងក្រងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដោយបានប្រមូលផ្តុំនូវសកម្មភាពការងារសំខាន់ ៗ ដែលការិយាល័យជំនាញក្នុងមន្ទីរ និងដៃគូអភិវឌ្ឍត្រូវអនុវត្តប្រចាំឆ្នាំ ។ ផែនការប្រតិបត្តិប្រចាំឆ្នាំរួមចំណែកក្នុង ការជំរុញឱ្យមានការទទួលខុសត្រូវខ្ពស់ពីគ្រប់ភាគី

ពាក់ព័ន្ធនៅក្នុងវិស័យអប់រំ សំដៅពង្រឹងប្រសិទ្ធភាពអនុវត្តផែនការ សកម្មភាពសុខដុមរម្យនីយកម្ម ការកាត់តម្រឹមនិង ការគ្រប់គ្រងផ្អែកលើលទ្ធផល ។ ជាក់ស្តែងក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ តាមរយៈតារាងឧបសម្ព័ន្ធទី១ នៃ របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ២០២៤ បានបង្ហាញឱ្យឃើញថា: មន្ទីរអប់រំ យុវជន និងកីឡា មានសកម្មភាពគោល ចំនួន ២ និងសកម្មភាពរងចំនួន ១២០សកម្មភាព ក្នុងនោះសកម្មភាពអនុវត្តដោយថវិការដ្ឋាភិបាលមានចំនួន ១២០ សកម្មភាព និងអង្គការដៃគូ គ្មាន ។ នៅក្នុងសកម្មភាពរងនីមួយ ៗ អនុវត្តផ្ទាល់ដោយការិយាល័យជំនាញ និងអង្គការ ដៃគូ ជាលទ្ធផលជាក់ស្តែងសកម្មភាពរងដែលបានអនុវត្តចប់ចំនួន **១២០សកម្មភាព** ស្មើនឹង **១០០%** ។

១-អនុកម្មវិធីការពង្រីកការអប់រំកុមារតូចមានសកម្មភាពរងចំនួន ០២សកម្មភាព បានអនុវត្តចប់ ០២ សកម្មភាព ស្មើនឹង ១០០%

២-អនុកម្មវិធីការពង្រឹងគុណភាព និងប្រសិទ្ធភាពនៅបឋមសិក្សាមានសកម្មភាពរងចំនួន ៨សកម្មភាព បាន អនុវត្តចប់ ៨សកម្មភាព ស្មើនឹង ១០០%

៣-អនុកម្មវិធីការពង្រឹងគុណភាព និងប្រសិទ្ធភាពនៅមធ្យមសិក្សាមានសកម្មភាពរងចំនួន ១២សកម្មភាព បានអនុវត្តចប់ ១២សកម្មភាព ស្មើនឹង ១០០%

៤-អនុកម្មវិធីការពង្រឹងការងារអប់រំក្រៅប្រព័ន្ធមានសកម្មភាពរងចំនួន ១០សកម្មភាព បានអនុវត្តចប់ចំនួន ១០ សកម្មភាព ស្មើនឹង ១០០%

៥-អនុកម្មវិធីការពង្រឹង និងពង្រីកការកម្មវិធីលើកកម្ពស់សុខភាពសិក្សាមានសកម្មភាពរងចំនួន ៥សកម្មភាព បានអនុវត្តចប់ចំនួន ៥សកម្មភាព ស្មើនឹង ១០០%

៦-អនុកម្មវិធីលើកកម្ពស់គុណភាព និងការអភិវឌ្ឍកម្មវិធីអប់រំបច្ចកទេស មានសកម្មភាពរងចំនួន ៦ សកម្មភាព បានអនុវត្តចប់ចំនួន ៦សកម្មភាព ស្មើនឹង ១០០%

៧-អនុកម្មវិធីការអភិវឌ្ឍការងារបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន មានសកម្មភាពរង ៤សកម្មភាព បានអនុវត្តចប់ ៤សកម្មភាព ស្មើនឹង ១០០%

៨-អនុកម្មវិធីការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារ និងបណ្ណាល័យមានសកម្មភាពរង ៣សកម្មភាព បានអនុវត្តចប់ ៣សកម្មភាព ស្មើនឹង ១០០%

៩-អនុកម្មវិធីការអភិវឌ្ឍអប់រំកាយ និងកីឡាសិស្ស និស្សិត មហាជន និងកីឡាកម្រិតខ្ពស់មានសកម្មរង ៩ សកម្ម ភាព បានអនុវត្តចប់ ៩សកម្មភាព ស្មើនឹង ១០០%

១០-អនុកម្មវិធីការពង្រឹងសមត្ថភាពយុវជនមានសកម្មភាពរង ១១សកម្មភាព បានអនុវត្តចប់ ១១សកម្មភាព ស្មើនឹង ១០០%

១១-អនុកម្មវិធីការអភិវឌ្ឍមជ្ឈមណ្ឌលយុវជនមានសកម្មភាពរង ៣សកម្មភាព បានអនុវត្តចប់ ៣សកម្មភាព ស្មើនឹង១០០%

១២-អនុកម្មវិធីការអភិវឌ្ឍកាយវិទ្យកម្មមានសកម្មភាពរង ៣សកម្មភាព បានអនុវត្តចប់ ៣ស្មើនឹង ១០០%

១៣-អនុកម្មវិធីការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធផែនការអប់រំមានសកម្មភាពរង ១ បានអនុវត្តចប់ ១ស្មើនឹង ១០០%

១៤-អនុកម្មវិធីការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្សមានសកម្មភាពរង ១៥សកម្មភាព បានអនុវត្តចប់ ១៥សកម្មភាព ស្មើនឹង ១០០%

១៥-អនុកម្មវិធីការអភិវឌ្ឍសមត្ថភាព ការងារគ្រប់គ្រង ផែនការហិរញ្ញវត្ថុ និងមូលដ្ឋានសម្ភារមានសកម្មភាពរង ២០សកម្មភាព បានអនុវត្តចប់ ២០សកម្មភាព ស្មើនឹង ១០០%

១៦-អនុកម្មវិធីការវាយតម្លៃលទ្ធផលសិក្សានិងអធិការកិច្ចគុណភាពអប់រំមានសកម្មភាពរង ២សកម្មភាព បានអនុវត្តចប់ ២សកម្មភាព ស្មើនឹង ១០០%

១៧-អនុកម្មវិធីការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ មានសកម្មភាពរង ៣សកម្មភាព បានអនុវត្តចប់ ៣ សកម្មភាព ស្មើនឹង ១០០%

១៨-ការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធពិនិត្យ តាមដាន និងវាយតម្លៃមានសកម្មភាពរង ២សកម្មភាព បានអនុវត្តចប់ ២ សកម្មភាព ស្មើនឹង ១០០%

១៩-ការពង្រឹងគុណភាព និងប្រសិទ្ធភាពការងារប្រឡងនៅមធ្យមសិក្សានិងអប់រំបច្ចេកទេស មានសកម្មភាពរង ១ សកម្មភាព បានអនុវត្តចប់ ១សកម្មភាព ស្មើនឹង ១០០%

តារាងទី១៖វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤



២.១.៤.៨ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា២០២៣-២០២៤

បន្ទាប់បទបង្ហាញទៅតាមប្រធានបទនីមួយ ៗ និងការពិភាក្សាពេញដើម្បីស្វែងរកធាតុចូលសំខាន់ ៗ ពីអ្នកពាក់ព័ន្ធប្រកបដោយជោគជ័យ នៅក្នុងរបាយការណ៍បូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០២៣-២០២៤ សមាជិការទាំងអស់នៃអង្គសន្និបាតក៏បានពិភាក្សា និងកំណត់ពីតម្រូវការជាក់ស្តែងដើម្បីរៀបចំទិសដៅការងារសម្រាប់អនុវត្តបន្តនៅក្នុងឆ្នាំសិក្សា២០២៣-២០២៤ ។ លទ្ធផលជាក់ស្តែងដែលសម្រេចបាន នូវទិសដៅអនុវត្តការងារប្រកបដោយការទទួលខុសត្រូវខ្ពស់របស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ និងការជួយជ្រោម ជ្រែងពីអាជ្ញាធរដែនដី មាតាបិតាសិស្ស អ្នកអាណាព្យាលបាលសិស្ស និងអ្នកពាក់ព័ន្ធ រយៈពេលមួយឆ្នាំសិក្សាកន្លងមកនេះ ទិសដៅដែលបានដាក់មានចំនួន **១៤៨ លទ្ធផល** ឬសកម្មភាព ក្នុងនោះបានអនុវត្ត **១៤៥សកម្មភាព** ឬលទ្ធផល ស្មើនឹង ៩៧.៩៧% និងមិនបានអនុវត្តចំនួន ០៣សកម្មភាព ឬលទ្ធផល **ស្មើនឹង ២.០៣%** ដូចមានខាងក្រោម:

១-អនុវិស័យការអប់រំកុមារតូច មានសកម្មភាពចំនួន ១៥ បានអនុវត្ត ១៥ស្មើនឹង ១០០%

២-អនុវិស័យអប់រំបឋមសិក្សា: មានសកម្មភាពចំនួន ២១ បានអនុវត្ត ២១ ស្មើនឹង ១០០%

៣-អនុវិស័យអប់រំនៅមធ្យមសិក្សា: មានសកម្មភាពចំនួន ១៦ បានអនុវត្ត ១៦ ស្មើនឹង ១០០%

៤-អនុវិស័យអប់រំក្រៅប្រព័ន្ធ: មានសកម្មភាពចំនួន ៩ បានអនុវត្ត ៨ស្មើនឹង ៨៨,៩%

៥-អនុវិស័យការអភិវឌ្ឍយុវជន: មានសកម្មភាពចំនួន ១៤ បានអនុវត្ត ១៤ស្មើនឹង ១០០%

៦-អនុវិស័យការអភិវឌ្ឍកីឡា: មានសកម្មភាពចំនួន ១១ បានអនុវត្ត ១១ស្មើនឹង ១០០%

៧-ការិយាល័យរដ្ឋបាល បុគ្គលិក និងបណ្តុះបណ្តាលមានសកម្មភាព១៦ បានអនុវត្ត ១៦ស្មើនឹង ១០០%

៨-ការិយាល័យគណនេយ្យ.សម្ភារនិងទ្រព្យសម្បត្តិរដ្ឋ មានសកម្មភាព ១៨ បានអនុវត្ត ១៨ ស្មើនឹង ១០០%

៩-ការិយាល័យផែនការ និងគ្រប់គ្រងជំនួយ មានសកម្មភាពចំនួន ២២ បានអនុវត្ត ២០ស្មើនឹង ៩០,៩%
សកម្មភាពមិនបានអនុវត្ត ២ ស្មើនឹង ៩,១% (សកម្មភាពដែលមិនបានអនុវត្ត គឺការប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ JTWG មូលហេតុដោយសារមិនទាន់បានធ្វើបច្ចុប្បន្នភាពក្រុមការងារ)

១០-ការិយាល័យអធិការកិច្ច: មានសកម្មភាពចំនួន ២ បានអនុវត្ត ២ ស្មើនឹង ១០០%

១១-ការិយាល័យសុខភាពសិក្សា មានសកម្មភាពចំនួន ៤ បានអនុវត្ត ៤ ស្មើនឹង ១០០%

តារាងទី១៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅក្នុងសន្និបាតអប់រំឆ្នាំ២០២៣-២០២៤



២.២-លទ្ធផលតាមអនុវិស័យ

២.២.១ អនុវិស័យការអប់រំកុមារតូច

ផ្អែកតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩- ២០២៣ និងដើម្បីជំរុញកុមារទាំងអស់ឱ្យទទួលបាន សេវាថែទាំអប់រំប្រកបដោយសមធម៌ ជាក់ស្តែងមន្ទីរអប់រំបានខិតខំ ពុះពារសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូរអភិវឌ្ឍនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ជាពិសេសផ្តោតលើកុមារក្រីក្រ កុមារជនជាតិដើមភាគតិច កុមារតាមព្រំដែន កុមារកំព្រា កុមារផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺឆ្លងនានា ។ ជាក់ស្តែងក្នុងឆ្នាំសិក្សា ២០២៤-២០២៥នេះ ដើម្បីសម្រេចទិសដៅខាងលើ មន្ទីរអប់រំ យុវជន និងកីឡា បានប្រមូលស្ថិតិទិន្នន័យព័ត៌មានកុមារអាយុពី ៣ឆ្នាំ ដល់ក្រោម ៦ឆ្នាំ និងធ្វើយុទ្ធនាការឃោសនាផ្សព្វផ្សាយតាមគ្រប់រូបភាពដោយ សហការជាមួយអាជ្ញាធរ ដែនដី ក្រុមប្រឹក្សាឃុំ/សង្កាត់ មេភូមិ ដូចជាការ បង្ហាញប័ណ្ណផ្ទៃត់ ផ្ទាំងរូបភាព ឯកសារផ្សេងៗនិងការផ្សព្វផ្សាយ តាមរយៈការរៀបចំវេទិការសាធារណៈ ថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត ប្រជុំគណៈកម្មការទ្រទ្រង់សាលារៀន មាតាបិតា អ្នកអាណាព្យាបាល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងសហគមន៍ ដើម្បីឱ្យពួកគាត់បានយល់ពីសារៈសំខាន់នៃការអប់រំកុមារតូច ការលើកកម្ពស់សុខភាពមាតា អនាម័យបរិស្ថានក្នុងនិងក្រៅថ្នាក់ ការងារយេនឌ័រ និងកិច្ចគាំពារកុមារ ដើម្បីផ្តល់ភាពកក់ក្តៅដល់កុមារ ។ បច្ចុប្បន្ននេះមន្ទីរអប់រំ យុវជន និងកីឡា មានសាលាមត្តេយ្យសិក្សាដែលកំពុងដំណើរការបង្រៀនសរុបចំនួន ៧២សាលា (មត្តេយ្យសិក្សាសាធារៈ ៣៥សាលា មត្តេយ្យសិក្សាសហគមន៍ ៣២កន្លែង និងមត្តេយ្យសិក្សាឯកជន ៥សាលា) ដែលមានសិស្សចូលរៀនសរុបចំនួន ២.៧៨៣នាក់ ស្រី ១.៤៣៧នាក់ ប្រុស ១.៣៤១នាក់ (សិស្សមត្តេយ្យសិក្សាសាធារណៈ ១.៧៥៥នាក់ ស្រី ៩០៧នាក់ ប្រុស ៨៤៨នាក់ មត្តេយ្យសិក្សាសហគមន៍ ៨២៤នាក់ ស្រី ៤៣៦នាក់ ប្រុស ៣៨៨នាក់ និងសិស្សមត្តេយ្យឯកជន ២០៤នាក់ ស្រី ៩៤នាក់) ក្នុងនោះសិស្សជនជាតិដើមភាគតិច ៩៦៨នាក់ ស្រី ៥០៨នាក់ ។ កុមារដែលទទួលបានសេវាអប់រំពីអាយុ ៣ឆ្នាំ ដល់ ៥ឆ្នាំគ្រប់រូបភាពសរុបចំនួន ២.៧៨៣នាក់ ស្រី ១,៤៣៧នាក់ ប្រុស ១.៣៤១នាក់ ស្មើនឹង ៣៨,១% ស្រី ៣៨,៧% ប្រុស ៣៧,៤% ហើយក្នុងនោះកុមារអាយុ ៣ឆ្នាំ ទទួលបានសេវាអប់រំសរុបចំនួន ៤៣០នាក់ ស្រី ២១៥នាក់ ប្រុស ២១៥នាក់ ស្មើនឹង ១៦,២% ស្រី ១៦% ប្រុស ១៦,៣% កុមារអាយុ ៤ឆ្នាំ ទទួលបានសេវាអប់រំសរុបចំនួន ១.១០៥នាក់ ស្រី ៦១៥នាក់ ប្រុស ៤៩០នាក់ ស្មើនឹង ៤៧,២% ស្រី ៥១,៧% ប្រុស ៤២,៦% និងកុមារអាយុ ៥ឆ្នាំ ទទួលបានសេវាអប់រំសរុប ១.២៤៨នាក់ ស្រី ៦០៧នាក់ ប្រុស ៦៤១នាក់ ស្មើនឹង ៥៤,១% ស្រី ៥១,៥% ប្រុស ៥៦,៨% ។ លទ្ធផលទាំងនេះបើធៀបនឹងឆ្នាំសិក្សា២០២៣-២០២៤ គឺកុមារដែលទទួលបានសេវាអប់រំនៅគ្រប់រូបភាពពីអាយុ ៣ឆ្នាំដល់៥ឆ្នាំសិស្សកើន ១៩៨នាក់ ស្រី ១៥០នាក់ ប្រុស ៤៣នាក់ ស្មើនឹង ៧,១% ស្រី ១០,៤% ប្រុស ៣,២% កត្តាដែលនាំឱ្យមានកំណើនសិស្សនេះគឺដោយសារមានការពង្រីកថ្នាក់មត្តេយ្យសិក្សាក្នុងបឋមដើម្បីទទួលកុមារចូលរៀន និងការយល់ដឹងពីភាពចាំបាច់នៃការអប់រំនៅកម្រិតថ្នាក់មត្តេយ្យរបស់ប្រជាជននៅតាមសហគមន៍ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ។

ក.១.១៖កុមារបានទទួលសេវាអប់រំតាមគ្រប់រូបភាព

ក្នុងឆ្នាំសិក្សា២០២៤-២០២៥ មត្តេយ្យសិក្សាសាធារណៈ មត្តេយ្យសិក្សាសហគមន៍ និងមត្តេយ្យសិក្សាឯកជន បានទទួលសេវាអប់រំកុមារពីអាយុ ៣ឆ្នាំដល់៥ឆ្នាំ សរុបចំនួន ២.៧៨៣នាក់ស្រី ១.៤៣៧នាក់ ប្រុស ១.៣៤១នាក់ បើធៀបនឹងឆ្នាំសិក្សា២០២៣-២០២៤ គឺកើន ៣សាលា៣ សិស្សកើន ១៩៨នាក់ ស្រី ១៥០នាក់ ប្រុស ៤៣នាក់ ស្មើនឹង ៧,១% ស្រី ១០,៤% ប្រុស ៣,២% ។

កុមារតាមអាយុ	ឆ្នាំសិក្សា២០២៣-២០២៤			ឆ្នាំសិក្សា២០២៤-២០២៥			កើន/ថយ
	សរុប	ស្រី	ប្រុស	សរុប	ស្រី	ប្រុស	
កុមារអាយុ ៣ឆ្នាំ	440	236	204	430	215	215	-10
កុមារអាយុ ៤ឆ្នាំ	991	496	495	1.105	615	490	+114
កុមារអាយុ ៥ឆ្នាំ	1.154	555	599	1.248	607	641	+94
សរុប	**2.585**	**1.287**	**1.298**	**2.783**	**1.437**	**1.346**	**+198**

ក.១.២៖ សាលាមត្តេយ្យសិក្សាដាច់ដោយឡែក៖

ក្នុងឆ្នាំសិក្សា២០២៤-២០២៥ នេះខេត្តមានសាលាមត្តេយ្យដាច់ដោយឡែកចំនួន ៤សាលា បើធៀបនឹង ឆ្នាំសិក្សា២០២៤-២០២៥ គឺសាលាថេរ និងសិស្សកើន ១១នាក់ ស្រី ៨នាក់ ប្រុស ៣នាក់ ស្មើនឹង ១,៦% ស្រី ២,៣% ប្រុស ០,៩% ។

ល.រ	កម្រិតថ្នាក់	ឆ្នាំសិក្សា២០២៣-២០២៤			ឆ្នាំសិក្សា២០២៤-២០២៥			កើន/ថយ
		សរុប	ស្រី	ប្រុស	សរុប	ស្រី	ប្រុស	
០១	កម្រិតទាប	142	78	64	99	46	53	-43
០២	កម្រិតមធ្យម	228	112	116	262	146	116	+34
០៣	កម្រិតខ្ពស់	291	144	147	311	150	161	+20
០៤	ថ្នាក់ចម្រុះ	0	0	0	0	0	0	0
សរុប		**661**	**334**	**327**	**672**	**342**	**330**	**+11**

ក.១.៣៖ មត្តេយ្យសិក្សាក្នុងបឋមសិក្សា៖

មត្តេយ្យសិក្សាដែលស្ថិតនៅក្នុងបឋមសិក្សាមានចំនួន ៣១សាលា ស្មើនឹង ៣៥ ថ្នាក់ គ្រូបង្រៀន ៣២នាក់ ស្រី ៣០នាក់ សិស្សសរុប ១.០៨៣នាក់ ស្រី ៥៦៥នាក់ ប្រុស ៥១៨នាក់ ធៀបនឹងឆ្នាំសិក្សា២០២៣-២០២៤ (សាលា ថេរ និងថ្នាក់រៀនកើន ២ថ្នាក់ និងសិស្សកើន ៩៣នាក់ ស្រី ៦៣នាក់ ប្រុស ៣០នាក់ ស្មើនឹង ៨,៦% ស្រី ១១,២% ប្រុស ៥,៨% ។

តារាងទី២៖ ស្ថិតិសិស្សសាលាមត្តេយ្យសិក្សាក្នុងបឋម

ល.រ	កម្រិតថ្នាក់	ឆ្នាំសិក្សា២០២៣-២០២៤			ឆ្នាំសិក្សា២០២៤-២០២៥			កើន/ថយ
		សរុប	ស្រី	ប្រុស	សរុប	ស្រី	ប្រុស	
០១	កម្រិតទាប	11	7	4	19	9	10	+8
០២	កម្រិតមធ្យម	73	41	32	56	30	26	-17
០៣	កម្រិតខ្ពស់	60	27	33	116	60	56	+56
០៤	ថ្នាក់ចម្រុះ	846	427	419	892	466	426	+46
សរុប		**990**	**502**	**488**	**1.083**	**565**	**518**	+93

ក.១.៤៖ មត្តេយ្យសហគមន៍

មានចំនួន ៣២សាលាស្មើនឹង ៣៣ថ្នាក់ មានកុមារសរុប ៨២៤នាក់ស្រី ៤៣៦នាក់ ប្រុស ៣៨៨នាក់ មានគ្រូបង្រៀន ៣៣នាក់ ស្រី ៣១នាក់ បើធៀបនឹងឆ្នាំ២០២២-២០២៣ កើន ០២សាលា ថ្នាក់រៀនកើន ២ថ្នាក់ និងកុមារកើន ១១៤នាក់ ស្រី ៨៤នាក់ ប្រុសកើន ២៩នាក់ នឹង ១៣,៨% ស្រី ១៩,៣% ប្រុស ៧,៥% ។

តារាងទី៣៖ ស្ថិតិសិស្សមត្តេយ្យសហគមន៍

ល.រ	កម្រិតថ្នាក់	ឆ្នាំសិក្សា២០២៣-២០២៤			ឆ្នាំសិក្សា២០២៤-២០២៥			កើន/ថយ
		សរុប	ស្រី	ប្រុស	សរុប	ស្រី	ប្រុស	
០១	កម្រិតទាប	0	0	0	0	0	0	0
០២	កម្រិតមធ្យម	29	12	17	37	21	16	+8
០៣	កម្រិតខ្ពស់	49	21	28	46	25	21	-3
០៤	ថ្នាក់ចម្រុះ	632	319	313	741	390	351	+109
សរុប		**710**	**352**	**358**	**824**	**436**	**388**	**+114**

ក.១.៥៖ មត្តេយ្យឯកជន

មត្តេយ្យឯកជនមាន ៥កន្លែង ស្មើនឹង ១១ថ្នាក់ បុគ្គលិកសរុប ១៥នាក់ ស្រី ១៣នាក់ មានសិស្សសរុប ២០៤ នាក់ ស្រី ៩៤នាក់ (មានទីតាំងនៅក្រុងសែនមនោរម្យ) បើធៀបទៅនិងឆ្នាំសិក្សា ២០២៣-២០២៤ សាលារៀនកើន ១កន្លែង សិស្សថយ ១១នាក់ ស្រីកើន ០១នាក់ ប្រុសថយ ១២នាក់ ។

តារាងទី៣៖ ស្ថិតិសិស្សមត្តេយ្យសិក្សាឯកជន

ល.រ	កម្រិតថ្នាក់	ឆ្នាំសិក្សា២០២៣-២០២៤			ឆ្នាំសិក្សា២០២៤-២០២៥			កើន/ថយ
		សរុប	ស្រី	ប្រុស	សរុប	ស្រី	ប្រុស	

០១	កម្រិតទាប	54	20	34	60	25	35	+6
០២	កម្រិតមធ្យម	78	30	34	95	50	45	+17
០៣	កម្រិតខ្ពស់	61	31	30	49	19	20	-12
០៤	ថ្នាក់ចម្រុះ	22	12	10	0	0	0	-22
សរុប		**215**	**93**	**122**	**204**	**94**	**110**	**-11**

តារាងទី៤៖ ស្ថិតិកុមារអាយុបានទទួលសេវាអប់រំគ្រប់រូបភាពពីឆ្នាំ២០២២-២០២៣ ដល់ ២០២៤-២០២៥






ភាគរយកុមារអាយុ ៤ឆ្នាំទទួលបានសេវាអប់រំគ្រប់រូបភាព
60
50
40
30
20
10
0
34.19
34.14
34.23
38.7
39.9
37.6
47.2
51.7
42.6
2022-2023
2023-2024
2024-2025
សរុប
ស្រី
ប្រុស


ចំនួនកុមារអាយុ ៥ឆ្នាំទទួលបានសេវាអប់រំគ្រប់រូបភាព
60.00
50.00
40.00
30.00
20.00
10.00
0.00
49.31
47.46
51.23
43.80
43.50
44.20
54.10
51.10
56.80
2022-2023
2023-2024
2024-2025
សរុប
ស្រី
ប្រុស

២.២.២. អនុវិស័យការអប់រំបឋមសិក្សា

អនុវិស័យអប់រំបឋមសិក្សា គឺជាអនុវិស័យមួយដែលជាមូលដ្ឋានគ្រឹះនៃការផ្តល់ចំណេះដឹងសំខាន់ដល់កុមារក្នុងវ័យសិក្សា ដើម្បីឈានទៅសម្រេចបាននូវការអប់រំជាមូលដ្ឋាន៩ឆ្នាំ និងបន្តការសិក្សានៅវិទ្យាល័យ និងឧត្តមសិក្សាប្រកបដោយគុណភាព ។ នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ថ្នាក់ខេត្ត ក៏បានដាក់ចេញនូវយុទ្ធ សាស្ត្រ និងសកម្មភាពចម្បងៗ សម្រាប់អនុវត្តដើម្បីសម្រេចបាននូវសូចនាករនានាដែលមាននៅក្នុងអនុវិស័យអប់រំបឋមសិក្សានាឆ្នាំ២០២៤-២០២៥ ទាំងផ្នែកបរិមាណ និងគុណភាព។ លទ្ធផលជាក់ស្តែងក្នុងឆ្នាំសិក្សា២០២៤-២០២៥ បានបង្ហាញថា: សាលាបឋមសិក្សាសរុបមានចំនួន ៩៦សាលា (បឋមសិក្សាសាធារណៈ: ៩១សាលា និងបឋមសិក្សាឯកជន ៥សាលា) ដែលមានសិស្សសរុបចំនួនន ១៧.០៥៩នាក់ ស្រី ៨.៤៥១នាក់ ក្នុងចំណោមសិស្សទាំងអស់មានសិស្សជនជាតិដើមភាគតិចចំនួន ៦.៥១១នាក់ ស្រី ៣.៣៥២នាក់ ប្រុស ៣.១៥៩នាក់ ។ បុគ្គលិកអប់រំបម្រើការងារនៅកម្រិតបឋមសិក្សាសរុបចំនួន ៧២១នាក់ ស្រី ៣៦១នាក់ ប្រុស ៣៦០នាក់ ក្នុងនោះបុគ្គលិកអប់រំជាជនជាតិដើមភាគតិច ៣៦៤នាក់ ស្រី ១៨៧នាក់ ។ បុគ្គលិកមិនបង្រៀន ៥៤នាក់ ស្រី ១៥នាក់ និងមានថ្នាក់រៀនពីទី១ដល់ទី៦សរុបចំនួន ៧៤៦ថ្នាក់ ។ ដោយចែកចេញជា:

-សាលាបឋមសិក្សាសាធារណៈសរុប ៩១សាលា និង ៧២២ថ្នាក់ បុគ្គលិកសរុប ៦៨៨នាក់ស្រី ៣៥៨នាក់ ក្នុងនោះមិនបង្រៀន ៤៩នាក់ ស្រី ១២នាក់ (បុគ្គលិកជនជាតិដើមភាគតិច ៣៦៤នាក់ ស្រី ១៨៧នាក់) និងមានសិស្សសរុប ១៦.៧៤៩នាក់ ស្រី ៨.៣១៧នាក់ ក្នុងនោះសិស្សជនជាតិដើមភាគតិច ៦.៤៩៨នាក់ ស្រី ៣.៣៤៤នាក់ បើធៀបនឹងឆ្នាំសិក្សា២០២៣-២០២៤ សាលារៀនថែរ ថ្នាក់រៀនកើន ១២ថ្នាក់ សិស្សកើន ១៩នាក់ ស្រីកើន ១៣២នាក់ ប្រុសថយ ២២៨នាក់ ស្មើនឹង +0,១% ស្រី +១,៦% ប្រុស -២,៧%។

-សាលាបឋមសិក្សាឯកជនសរុប ៥សាលា និង ២៤ថ្នាក់ បុគ្គលិកសរុប ៣៣នាក់ ស្រី ៣នាក់ ក្នុងនោះមិនបង្រៀន ៥នាក់ ស្រី ៣នាក់ ដែលមានសិស្សសរុប ៣១០នាក់ ស្រី ១៣៤នាក់ ក្នុងនោះសិស្សជនជាតិដើមភាគតិច ១៣នាក់ ស្រី ៨នាក់ ។

២-តារាងស្ថិតិសិស្សបឋមសិក្សារដ្ឋ និងឯកជនតាមកម្រិតថ្នាក់

ល.រ	កម្រិតថ្នាក់	2022-2023			2022-2023			ផ្សេង ៗ
		ចំ.ថ្នាក់រៀន	ចំនួនសិស្សសរុប		ចំ.ថ្នាក់រៀន	ចំនួនសិស្សសរុប		
			សរុប	ស្រី		សរុប	ស្រី	
1	ថ្នាក់ទី១	136	3.102	1.428	129	3.083	1.430	-19
2	ថ្នាក់ទី២	136	3.445	1.625	132	3.047	1.467	-398
3	ថ្នាក់ទី៣	122	2.997	1.485	125	3.272	1.578	+275
4	ថ្នាក់ទី៤	116	2.653	1.302	116	2.757	1.419	+104
5	ថ្នាក់ទី៥	114	2.308	1.221	111	2.436	1.249	+128
6	ថ្នាក់ទី៦	108	2.225	1.123	109	2.154	1.174	-71
7	សាលាឯកជន	25	333	152	24	310	134	-23
សរុបរួម		**735**	**17.063**	**8.336**	**746**	**17.059**	**8.451**	**-4**

តារាងទី១៖ ស្ថិតិសិស្សសាលារៀនសាធារណៈ និងសាលារៀនឯកជន



តារាងទី២៖ អត្រាពិតចូលរៀនថ្មី



តារាងទី៣៖ អត្រាពិតនៃការសិក្សានៅបឋមសិក្សា



តារាងទី៤៖អត្រាឡើងថ្នាក់នៅបឋមសិក្សា



តារាងទី៤៖អត្រាត្រួតថ្នាក់នៅបឋមសិក្សា



តារាងទី៤៖អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា



២.២.៣ ការអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស

ក្នុងខេត្តមានសាលាមធ្យមសិក្សាសរុបចំនួន ១៦សាលា បុគ្គលិកសរុបចំនួន ៣០៧នាក់ ស្រី ១៣០នាក់ (បុគ្គលិកជនជាតិដើមភាគតិចចំនួន ២៣នាក់ ស្រី ៩នាក់)ក្នុងនោះមិនបង្រៀនចំនួន ១៥នាក់ ស្រី ២នាក់ បុគ្គលិកជនជាតិដើមភាគតិចចំនួន ២៣នាក់ ស្រី ៩នាក់ និងមានសិស្សសរុបចំនួន ៧.០៨៨នាក់ ស្រី ៣.៧៨៩នាក់ ក្នុងនោះសិស្សជនជាតិដើមភាគតិចចំនួន ២.៥២០នាក់ ស្រី ១.៤៤៥នាក់ ប្រុស ១.០៧៥នាក់ និងមានថ្នាក់រៀនចំនួន ១៥៨

ថ្នាក់ ។ បើធៀបនឹងឆ្នាំសិក្សា២០២៣-៣០២៤ សាលារៀនថេរ ថ្នាក់រៀនកើន ៣ថ្នាក់ សិស្សកើន ៥៩៦នាក់ ស្រី ៣១០នាក់ ស្មើនឹង ៨,៤% ស្រី ៨,២% ។ ដោយចែកចេញជា:

-សាលាមធ្យមសិក្សាសាធារណៈមានចំនួន ១៥សាលា ក្នុងចំណោម ២១ឃុំ/សង្កាត់ បុគ្គលិកសរុបចំនួន ២៩៤នាក់ ស្រី ១២៨នាក់ ក្នុងនោះមិនបង្រៀនចំនួន ២៩នាក់ ស្រី ២នាក់ (បុគ្គលិកជនជាតិដើមភាគតិច ចំនួន ២៣នាក់ ស្រី ០៩នាក់) និងសិស្សសរុបចំនួន ៦.៩២១នាក់ ស្រី ៣.៧០៨នាក់ ប្រុស ៣.២១៣នាក់ ក្នុងនោះសិស្សជនជាតិដើមភាគតិចចំនួន ២.៥២០នាក់ ស្រី ១.៤៤៥នាក់ ប្រុស ១.០៧៥នាក់ និងមានថ្នាក់រៀនចំនួន ១៥១ថ្នាក់ បើធៀបនឹងឆ្នាំសិក្សា២០២២-២០២៣ សាលារៀនថេរ ថ្នាក់រៀនកើន ៣ថ្នាក់ សិស្សកើន ៥៨៣នាក់ ស្រី ៣០១នាក់ ប្រុស ២៨២នាក់ ស្មើនឹង ៨,៤% ស្រី ៨,១% ប្រុស ៨,៨%។ ក្នុងចំណោមសាលាមធ្យមសិក្សាទាំង ១៥សាលា ដោយចែកចេញជាពីរផ្នែកគឺ ១-សាលមធ្យមសិក្សាបឋមភូមិមានចំនួន ១៤កន្លែង បុគ្គលិកបម្រើការងារ ១៨៩នាក់ ស្រី ៨៣នាក់ ប្រុស ១០៦នាក់ បុគ្គលិកមិនបង្រៀន ៤នាក់ ស្រី ១នាក់ ប្រុស ៣នាក់ ក្នុងនោះបុគ្គលិកជនជាតិដើមភាគតិច ១៩នាក់ស្រី ៨នាក់ និងមានសិស្សសរុប ៤.៤៥១ នាក់ ស្រី ២.៣៧៨នាក់ ប្រុស ២.០៧៣នាក់ សិស្សជនជាតិដើមភាគតិច ១.៦៤៩នាក់ ស្រី ៩៤៣នាក់ និងមានថ្នាក់រៀនសរុប ៩៥ថ្នាក់(ថ្នាក់ទី៧មាន ៣៧ថ្នាក់ -ថ្នាក់ទី៨ មាន ៣១ថ្នាក់ និងថ្នាក់ទី៩ មាន ២៧ថ្នាក់) សម្រាប់មធ្យមសិក្សាទុតិយភូមិមានចំនួន ៦សាលា បុគ្គលិកបម្រើការងារ ១០៥នាក់ ស្រី ៤៥នាក់ បុគ្គលិកមិនបង្រៀន ១១នាក់ ស្រី ១នាក់ ប្រុស ១០នាក់ ក្នុងនោះបុគ្គលិកជនជាតិដើមភាគតិច ៨នាក់ ស្រី ១នាក់ មានសិស្សសរុបចំនួន ២.៤៧០នាក់ ស្រី ១.២៧៣នាក់ ប្រុស ១.៣៣០នាក់ ក្នុងនោះសិស្សជនជាតិដើមភាគតិច ៨៧១នាក់ ស្រី ៥០២នាក់ ប្រុស ៣៦៩នាក់ និងមានថ្នាក់រៀនសរុប ៥៦ថ្នាក់ (ថ្នាក់ទី១០មាន ២២ថ្នាក់ -ថ្នាក់ទី១១ មាន ១៨ថ្នាក់ និងថ្នាក់ទី១២ មាន ១៦ថ្នាក់) ។

-សាលាមធ្យមសិក្សាឯកជនមានចំនួន ១កន្លែង ស្មើនឹង ៧ថ្នាក់ បុគ្គលិកសរុបចំនួន ១៣នាក់ ស្រី ២នាក់ ក្នុងនោះមិនបង្រៀនចំនួន ០នាក់ ស្រី ០នាក់ (បុគ្គលិកជនជាតិដើមភាគតិចចំនួន គ្មាន)និងសិស្សសរុបចំនួន ១៦៧នាក់ ស្រី ៨១នាក់ (សិស្សជនជាតិដើមភាគតិចគ្មាន) ។

តារាងទី១៖ស្ថិតិសិស្ស-បុគ្គលិក និងថ្នាក់រៀន សាលារៀនសាធារណៈ

បរិយាយ	២០២៣-៣០២៤	២០២៤-២០២៥	កើ ថយ
មធ្យមសិក្សាបឋមភូមិ (ពីថ្នាក់ទី ៧ ដល់ ទី ៩)			
សាលារៀន	14	14	ថេរ
ថ្នាក់រៀន	94	95	+1
សិស្សសរុប	4.041	4.451	+410
សិស្សស្រី	2.134	2.378	+244

សិស្សប្រុស	1.907	2.073	+166
បុគ្គលិកសរុប	197	189	-8
បុគ្គលិកជាស្ត្រី	84	83	-1
បុគ្គលិកមិនបង្រៀនសរុប	9	4	-5
បុគ្គលិកមិនបង្រៀនជាស្ត្រី	2	1	-1
មធ្យមសិក្សាទុតិយភូមិ (ពីថ្នាក់ទី ១០ ដល់ ១២)			
សាលារៀន	7	7	ថេរ
ថ្នាក់រៀន	54	56	+2
សិស្សសរុប	2.297	2.470	+173
សិស្សស្រី	1.273	1.330	+57
សិស្សប្រុស	1.024	1.140	+116
បុគ្គលិកសរុប	96	105	+9
បុគ្គលិកជាស្ត្រី	42	45	+3
បុគ្គលិកមិនបង្រៀនសរុប	13	11	-2
បុគ្គលិកមិនបង្រៀនជាស្ត្រី	2	1	-1

សំគាល់៖សញ្ញា (+ កើន) សញ្ញា (- ថយចុះ)

កត្តាដែលនាំឱ្យវិស័យអប់រំផ្នែកមធ្យមសិក្សាចំណេះទូទៅ និងបច្ចេកទេសមានការរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំគឺដោយសារកត្តា ៖

- ការប្រែប្រួលស្ថានភាពអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធអប់រំ (សាលារៀនភាគច្រើនមានអគារសិក្សាទើបសាងសង់ថ្មី មានបន្ទប់រៀន បង្គន់អនាម័យ បណ្តាញអគ្គិសនី បន្ទប់ពិសោធដោយបំពាក់សម្ភារពិសោធ បន្ទប់កុំព្យូទ័រដែលប្រើប្រាស់បាន និងបណ្តាញអ៊ីនធឺណែតដែលអាចបម្រើដល់ការការរៀន និងបង្រៀន សិស្សបានចូលធ្វើការងារពិសោធជាក់ស្តែង)

  ការប្រែប្រួលស្ថានភាពចូលរៀនរបស់សិស្សានុសិស្សមិនមានការរើសអើងប្រកាន់ពូជសាសន៍ មិនរើសអើងលើសិស្សស្រី ឬសិស្សប្រុស ជាពិសេសផ្តោតទៅលើបញ្ហាឆ្លងវិស័យដូចជា យេនឌ័រ ជនជាតិភាគតិច កុមារជួបការលំបាក មេរោគអេដស៍/ជំងឺអេដស៍ និងតំបន់ព្រំដែនឡើយ
- សាលារៀនដែលមានបណ្ណាល័យដាច់ដោយឡែក មានបណ្ណារក្សប្រចាំការ
- សិស្សទទួលអាហារូបករណ៍គ្រប់ប្រភេទដូចជាអាហារូបករណ៍សិស្សក្រីក្រ និងពូកែ អាហារូបករណ៍សិស្សក្រីក្រទទួលបានការឿបត្តម្ភពីអង្គការដៃគូ អាហារូបករណ៍ស្នាក់នៅ និងហូបចុកនៅអន្តេវាសិកដ្ឋានខេត្ត កន្លែងស្នាក់របស់សិស្សជានារី
- បានបង្កើតក្រុមប្រឹក្សាកុមារ យុវជន និងកាយវិទ្ធិ ឱ្យមានដំណើរការជាប្រចាំក្នុងការជួយដល់សាលារៀន

- នៅអគារធនធានមានកម្មវិធីបណ្តុះបណ្តាលជំនាញ (ជំនាញឌីជីថល សហគ្រិនភាព ជំនាញវិជ្ជាជីវៈ និងបច្ចេកទេស សហគ្រិនភាព ភាពជាអ្នកដឹកនាំ ជាដើម)

តារាងទី១៖ ស្ថិតិសិស្សមធ្យមសិក្សាសាធារណៈ



តារាងទី២៖ ស្ថិតិសិស្សមធ្យមបឋមភូមិសាលារៀនសាធារណៈ



តារាងទី៣៖ ស្ថិតិសិស្សមធ្យមទុតិយភូមិសាលារៀនសាធារណៈ



តារាងទី៤៖អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ



តារាងទី៥៖អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិភូមិ



តារាងទី៦៖អត្រាឡើងថ្នាក់នៅមធ្យមសិក្សាបឋមភូមិ



តារាងទី៧៖អត្រាត្រួតនៅមធ្យមសិក្សាបឋមភូមិ



តារាងទី៨៖អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ



តារាងទី៩៖អត្រាឡើងថ្នាក់នៅមធ្យមសិក្សាទុតិយភូមិ



តារាងទី១០៖អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ



តារាងទី១១៖ភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ



តារាងទី១២៖ភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ



២.២.៤ អនុវិស័យការអប់រំក្រៅប្រព័ន្ធ

ក.ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា

ក្នុងឆ្នាំ២០២៤ កន្លងទៅនេះការងារអប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន បានចូលរួមសម្រេចតាមគោលនយោបាយអប់រំធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា ។ ជាក់ស្តែងការងារអប់រំក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៤ បានផ្ញើមុខងារទៅឱ្យរដ្ឋបាលក្រុង/ស្រុកទាំងផ្នែកបុគ្គលិក និងថវិកា មានកម្មវិធីអក្ខរកម្មវិជ្ជាជីវៈចំនួន១០ថ្នាក់ គ្រូបង្រៀនចំនួន១០នាក់ ស្រី ០៦នាក់ និងមានសិស្សចុះឈ្មោះចូលរៀនដើមឆ្នាំសរុបចំនួន ១៦២នាក់ ស្រី ៨២នាក់ ។ កម្មវិធីក្រោយអក្ខរកម្មមានបណ្ណាល័យ១កន្លែងមានអ្នកចូលអានសរុបចំនួន ៣៦៤នាក់ស្រី២០២នាក់ ។ កម្មវិធីបង្កើនប្រាក់ចំណូល មានមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន ០៥កន្លែង ដោយមានបង្រៀនជំនាញមុខរបរ ៤ថ្នាក់ ជំនាញកុំព្យូទ័រ ០២ថ្នាក់មានអ្នករៀនចំនួន ៣២នាក់ស្រី ២៣នាក់ សំអាងកាយ ១ថ្នាក់មានអ្នករៀនចំនួន ១០នាក់ស្រី ១០នាក់ និង ថ្នាក់ចាក់កាបូប ចំនួន ១ថ្នាក់ មានអ្នករៀនចំនួន ៣០នាក់ ស្រី ២៦នាក់ និងគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍សរុបចំនួន ២៥នាក់ ស្រី០៩នាក់ ។ កម្មវិធីសមមូលបឋមសិក្សាមានចំនួន៣ថ្នាក់ គ្រូបង្រៀនចំនួន៣នាក់ ស្រី១នាក់ មានសិស្សសរុបចំនួន៥៧នាក់ ស្រី៩នាក់ ។ ការងារបំពេញវិជ្ជាមានចំនួន ០១ថ្នាក់ មានបេក្ខជនដាក់ពាក្យប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំនួន ២៤ នាក់ ស្រី ២១ នាក់ និងបានប្រឡងជាប់ ១៨ នាក់ស្រី ១៥ នាក់ ។បេក្ខជាស្ម័យរៀនបំពេញវិជ្ជាបានដាក់ពាក្យ ០១ នាក់ស្រី ០០ នាក់ ប្រឡងជាប់ ០១ នាក់ ។

ក្រាបស្ថិតិប្រជាជន អនក្ខរជន ខេត្តមណ្ឌលគិរី២០២៤ (យកតាមស្ថិតិមន្ទីរផែនការខេត្តមណ្ឌលគិរី)



តារាងស្ថិតិកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ ឆ្នាំ២០២៤

ល.រ	ក្រុង ស្រុក ខណ្ឌ	ចំនួនថ្នាក់	ចូលរៀន		រៀនចប់		តេស្តបញ្ចប់ជាប់		បំណិនផ្នែកអក្សរ		បំណិនផ្នែកលេខ	
			សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
1	កែវសីមា	2	34	25	21	15	21	15	21	15	21	15
2	កោះញែក	3	53	22	45	17	45	17	45	17	45	17
3	អូររាំង	1	26	17	22	14	19	12	15	8	13	8
4	ពេជ្រាដា	2	27	18	21	16	17	13	17	13	17	13
5	សែនមនោរម្យ	2	22	0	17	0	12	0	9	0	8	0
សរុប		**10**	**162**	**82**	**126**	**62**	**114**	**57**	**107**	**53**	**104**	**53**

តាមតារាងស្ថិតិថ្នាក់ សិស្សក្នុងកម្មវិធីអក្ខរកម្មឆ្នាំ២០២៤នេះ បានបង្ហាញថាៈទាំង៥ក្រុង/ស្រុក បានអនុវត្តបើកដំណើរការថ្នាក់អក្ខរកម្មវិជ្ជាជីវៈចំនួន១០ថ្នាក់ ដែលមានអ្នកចូលរៀនសរុប ១៦២នាក់ ស្រី៨២នាក់។ ដែលនៅក្នុងនោះស្រុកកែវសីមា មានចំនួន០២ថ្នាក់ អ្នករៀនសរុប៣៤នាក់ ស្រី២៥នាក់ បានបញ្ចប់សរុបចំនួន២១នាក់ ស្រី១៥នាក់ ហើយក្នុងនោះដៃរអ្នកបានធ្វើតេស្តបញ្ចប់ជាប់សរុបចំនួន២១នាក់ ស្រី១៥នាក់ ហើយក្នុងចំណោមអ្នករៀនចប់ទាំងអស់ សុទ្ធតែមានបំណិនផ្នែកអក្សរ និងបំណិនផ្នែកលេខ គឺ សរុបចំនួន២១នាក់ ស្រី១៥នាក់ ។ ចំណែកឯក្នុងកោះញែកវិញ មានថ្នាក់ចំនួន៣ថ្នាក់ អ្នកចូលរៀនសរុបចំនួន៥៣នាក់ ស្រី២២នាក់ បានបញ្ចប់សរុបចំនួន៤៥នាក់ ស្រី១៧នាក់ ហើយនៅក្នុងដៃរអ្នកបានធ្វើតេស្តបញ្ចប់ចប់ចំនួន៤៥នាក់ ស្រី១៧នាក់ ហើយក្នុងចំណោមអ្នករៀនចប់ទាំងអស់ សុទ្ធតែមានបំណិនផ្នែកអក្សរ និងបំណិនផ្នែកលេខគឺ៤៥នាក់ ស្រី១៧នាក់ ។ រីឯស្រុកអូររាំង បានបើកដំណើរការថ្នាក់ចំនួន១ថ្នាក់ មានអ្នករៀនសរុប២៦នាក់ ស្រី១៧នាក់ បានបញ្ចប់សរុបចំនួន២២នាក់ ស្រី១៤នាក់ ហើយក្នុងនោះដៃរបានធ្វើតេស្តបញ្ចប់ចប់សរុបចំនួន១៩នាក់ ស្រី១២នាក់ ហើយអ្នកដែលមានបំណិនផ្នែកអក្សរសរុបចំនួន១៥នាក់ ស្រី៨នាក់ ហើយអ្នកដែលមានបំណិនផ្នែកលេខមានសរុបចំនួន១៣នាក់ ស្រី៨នាក់ ។ ចំណែកឯស្រុកពេជ្រាដាវិញ បានបើកដំណើរការថ្នាក់អក្ខរកម្មចំនួន២ថ្នាក់ មានអ្នករៀនសរុបចំនួន២៧នាក់ ស្រី១៨នាក់ បានបញ្ចប់សរុបចំនួន២១នាក់ ស្រី១៦នាក់ ហើយក្នុងនោះដៃរអ្នកដែលបានធ្វើតេស្តបញ្ចប់ចប់ អ្នកបំណិនផ្នែកអក្សរ និងអ្នកបំណិនផ្នែកលេខ មានចំនួនស្មើគ្នាទាំងអស់ គឺសរុប១៧នាក់ ស្រី១៣នាក់ ។ រីឯក្រុងសែនមនោរម្យវិញ បានបើកដំណើរការថ្នាក់អក្ខរកកម្មចំនួន២ថ្នាក់ មានអ្នករៀនសរុប២២នាក់ ស្រី០០នាក់ បានបញ្ចប់សរុបចំនួន ១៧នាក់ ស្រី០០នាក់ ហើយបានធ្វើតេស្តបញ្ចប់ចប់សរុបចំនួន១២នាក់ ស្រី០០នាក់ អ្នកដែលមានបំណិនផ្នែកអក្សរសរុបចំនួន៩

នាក់ ស្រី០០នាក់ អ្នកបំណិនផ្នែកលេខសរុបចំនួន៨នាក់ ស្រី០០នាក់ (ថ្នាក់អក្ខរកម្មទាំង០២ថ្នាក់នេះ គ្មានអ្នករៀនជាស្រី ដោយសារមាន១ថ្នាក់នៅក្នុងវត្តសែនមនោរម្យ និង១ថ្នាក់ទៀតនៅពន្ធនាគារខេត្តមណ្ឌលគិរី)។

ទិវាអក្ខរកម្មជាតិ ៨ កញ្ញា ជាកម្លាំងចលករជួយជំរុញឱ្យកម្មវិធីនេះ កាន់តែមានប្រសិទ្ធភាព និងចូលរួមកាត់បន្ថយអត្រាអនក្ខរភាពគួរឱ្យកត់សម្គាល់។ ជាក់ស្តែងក្រសួងបានផ្សព្វផ្សាយទិវាអក្ខរកម្មជាតិ ៨ កញ្ញា ឆ្នាំ២០២៤ ក្រោមប្រធានបទ «អក្ខរកម្មជាមូលដ្ឋានគ្រឹះនៃចំណេះដឹង បំណិន និងនវានុវត្តន៍»។ ដែលជាប្រធានបទមួយដែលមានសារៈសំខាន់ដែលអាចឆ្លើយតបទៅនឹងការងារអប់រំក្រៅប្រព័ន្ធទាំងមូល ជាពិសេសផ្តោតទៅលើយុវជនក្រៅសាលា និងយុវជន ដែលគ្មានឱកាសទាំងអស់ ដែលមានអ្នកចូលរួមសរុបចំនួន១៨៧នាក់ ស្រី១១៥នាក់ ។

លទ្ធផលអ្នកបានបញ្ចប់កម្មវិធីអក្ខរកម្មឆ្នាំ២០២០-២០២៤



កម្មវិធីក្រោយអក្ខរកម្ម

កម្មវិធីនេះបានជួយបង្កើនចំណេះដឹង និងទប់ស្កាត់ការភ្លេចអក្សរដល់អក្ខរជនថ្មី និងប្រជាសហគមន៍។ បណ្ណាល័យនៅក្នុងស្រុកកោះញែកមិនមានដំណើរការ ប៉ុន្តែបានធ្វើការបង្វែរ បំពាក់សៀវភៅ ថវិកា សម្ភារផ្សេងៗ ទាំងអស់មកបណ្ណាល័យខេត្តមណ្ឌលគិរី(ទីរួមខេត្តមណ្ឌលគិរី)ដែលមានអ្នកចូលអានសរុបចំនួន៣៦៤នាក់ ស្រី២០២ នាក់ ។

កម្មវិធីបង្កើនប្រាក់ចំណូល (ថ្នាក់ជំនាញមុខរបរ)

ក្នុងឆ្នាំ២០២៣-២០២៤នេះ កម្មវិធីបង្កើនប្រាក់ចំណូលនៅតាមផ្សេមណ្ឌលសិក្សាសហគមន៍មានចំនួន០៤ កន្លែង បង្រៀនជំនាញមុខរបរ៤ថ្នាក់ ជំនាញកុំព្យូទ័រ០២ថ្នាក់មានអ្នករៀនចំនួន ៣២នាក់ស្រី ២៣នាក់ សំអាងកាយ ០១ថ្នាក់មានអ្នករៀនចំនួន ១០នាក់ស្រី ១០នាក់ និង ថ្នាក់ចាក់កាបូប ចំនួន០១ថ្នាក់ មានអ្នករៀនចំនួន៣០នាក់ ស្រី ២៦នាក់សរុបចំនួន ៥៨នាក់ ស្រី ៤៩នាក់ ។

ស្ថិតិថ្នាក់ សិស្សក្នុងកម្មវិធីបង្កើនប្រាក់ចំណូលឆ្នាំ២០២៤

តាមតារាងស្ថិតិថ្នាក់ សិស្សក្នុងកម្មវិធីបង្កើនប្រាក់ចំណូលឆ្នាំ២០២៤ បង្ហាញថា៖ មានស្រុកចំនួន៣ ធ្វើកម្មវិធីនេះ មានសរុបចំនួន០៤ថ្នាក់ (ថ្នាក់កុំព្យូទ័រ សំអាងកាយ ចាក់កាប) ក្នុងនោះ ស្រុកកែវសីមា មានថ្នាក់ជំនាញ ០១ ថ្នាក់ ជាថ្នាក់ជំនាញកុំព្យូទ័រ ដែលមានអ្នកចូលរៀនសរុបចំនួន១២នាក់ ស្រី៧នាក់ បានបញ្ចប់០៨នាក់ ស្រី៥នាក់ ហើយបានប្រឡងជាប់០៨នាក់ ស្រី៥នាក់ ។

ស្រុកកោះញែកចំនួន០២ថ្នាក់៖ មាន០១ថ្នាក់ជាថ្នាក់ជំនាញកុំព្យូទ័រ និង០១ទៀតជាថ្នាក់សំអាងកាយ ដែលមានអ្នករៀនសរុបចំនួន៣០នាក់ ស្រី២៦នាក់ បានបញ្ចប់សរុបចំនួន២៣នាក់ ស្រី២២នាក់ ហើយបានប្រឡងជាប់សរុប២៣នាក់ ស្រី២២នាក់ ហើយអ្នករៀនដែលបានបញ្ចប់ទាំងសុទ្ធតែមានបំណិនផ្នែកទ្រឹស្តី និងបំណិនផ្នែកអនុវត្ត ។ ស្រុកអូររាំងចំនួន០១ថ្នាក់ ដែលមានជំនាញចាក់កាបូប មានអ្នកចូលរៀនសរុបចំនួន១៦នាក់ ស្រី១៦នាក់ បានប្រឡងជាប់ បំណិនផ្នែកទ្រឹស្តី បំណិនផ្នែកអនុវត្ត មានសរុបចំនួន១៦នាក់ ស្រី១៦នាក់ ។

លទ្ធផលអ្នកបានបញ្ចប់កម្មវិធីបង្កើនប្រាក់ចំណូលឆ្នាំ២០២០-២០២៤

ល.រ	ក្រុង ស្រុក ខណ្ឌ	ចំនួន ថ្នាក់	ចូលរៀន		រៀនចប់		ប្រឡងជាប់		បំណិនផ្នែកទ្រឹស្តី		បំណិនផ្នែកអនុវត្ត	
			សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
1	កែវសីមា	1	12	7	8	5	8	5	8	5	8	5
2	កោះញែក	2	30	26	23	22	23	22	23	22	23	22
3	អូររាំង	1	16	16	16	16	16	16	16	16	16	16
សរុប		**4**	**58**	**49**	**47**	**43**	**47**	**43**	**47**	**43**	**47**	**43**

កម្មវិធីសមមូលបឋមសិក្សា



ស្ថិតិថ្នាក់ សិស្សថ្នាក់ឆ្នាំទី១ និងទី២ក្នុងកម្មវិធីសមមូលបឋមសិក្សា ឆ្នាំ២០២៤

ល.រ	ក្រុង ស្រុក ខណ្ឌ	ចំនួនថ្នាក់	ចូលរៀន		មកពីថ្នាក់សមមូលឆ្នាំទី១		បញ្ចប់		ប្រឡងជាប់ឆមាសទី១		ប្រឡងជាប់ឆមាសទី២		ជាប់មធ្យមភាគ	
			សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
1	កោះញែក	1	28	9	28	9	24	9	24	9	24	9	24	9
2	សែនមនោរម្យ	2	29	0	11	0	26	0	26	0	26	0	26	0
	សរុប	3	57	9	39	9	50	9	50	9	50	9	50	9

តាមតារាងស្ថិតិថ្នាក់ សិស្សថ្នាក់ឆ្នាំទី១ និងឆ្នាំទី២ ក្នុងកម្មវិធីសមមូលបឋមសិក្សាឆ្នាំ២០២៤ បង្ហាញថា៖ មានក្រុងស្រុកចំនួន០២ ដែលធ្វើកម្មវិធី គឺស្រុកកោះញែក និងក្រុងសែនមនោរម្យ មានចំនួន០៣ថ្នាក់ ដែលមានអ្នកចូលរៀនសរុបចំនួន៥៧នាក់ ស្រី០៩នាក់ អ្នកបានបញ្ចប់សរុបចំនួន៥០នាក់ ស្រី០៩នាក់ ហើយបានជាប់មធ្យមភាគសរុបចំនួន៥០នាក់ ស្រី០៩នាក់។ ក្នុងនោះ ស្រុកកោះញែកមានចំនួន០១ថ្នាក់ អ្នកចូលរៀនសរុប២៨នាក់ ស្រី០៩នាក់ បានបញ្ចប់សរុបចំនួន២៤នាក់ ស្រី០៩នាក់ ហើយបានជាប់មធ្យមភាគសរុបចំនួន២៤នាក់ ស្រី០៩នាក់ ។ ក្រុងសែនមនោរម្យ មានចំនួន០២ថ្នាក់ (វត្តសែនមនោរម្យ សម្រាប់ព្រះសង្ឃ១ថ្នាក់ និងពន្ធនាគារ១ថ្នាក់)ដែលមានអ្នកចូលរៀនសរុបចំនួន២៩នាក់ ស្រី០០នាក់ បានបញ្ចប់សរុបចំនួន២៦នាក់ ស្រី០០នាក់ ហើយបានជាប់មធ្យមភាពសរុបចំនួន២៦នាក់ ស្រី០០នាក់ ។

ចំនួនអ្នកបានបញ្ចប់កម្មវិធីសមមូលបឋមសិក្សាឆ្នាំ២០២០-២០២៤



កម្មវិធីចូលរៀនឡើងវិញ

កម្មវិធីនេះ ផ្តល់ឱកាសឱ្យសិស្សបោះបង់ការសិក្សាចាប់ពីថ្នាក់ទី៣ ដល់ទី៦ បានបន្តការសិក្សាឡើងវិញនៅតាមសាលាចំណេះទូទៅអប់រំក្នុងប្រព័ន្ធ។ នៅក្នុងខេត្តមណ្ឌលគិរី គ្មានសកម្មភាព ដោយសិស្សបោះបង់គោលដៅ មិនបានគ្រប់និយាយកំណត់របស់ក្រសួងអប់រំ និងមិនមានការប្រើប្រាស់គ្រូ ។

ការងារបំពេញវិជ្ជា

ល.រ	ក្រុង ស្រុក ខណ្ឌ	សិស្សប្រមូលផ្តុំ		សិស្សចុងឆ្នាំ		ជាក់ពាក្យប្រឡង		ប្រឡងជាប់		ស្វែរនជាក់ពាក្យ		ស្វែរនប្រឡងជាប់	
		សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
1	កោះញែក	27	24	24	22	24	21	18	15	1	0	1	0
	សរុប	27	24	24	22	24	21	18	15	1	0	1	0

ការបើកថ្នាក់បំពេញវិជ្ជា ដែលការិយាល័យអប់រំក្រៅប្រព័ន្ធបានធ្វើ គឺបានចូលរួម ផ្តល់សេវាដល់យុវជន បុគ្គលិក មន្ត្រីរាជការ គ្រូបង្រៀន កងកម្លាំងប្រដាប់អាវុធ បានទទួលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នឹងអាចបន្តការសិក្សាពេញមួយជីវិត និងអាចអភិវឌ្ឍគួនាទី ឱ្យកាន់តែរីកចម្រើន ។ ក្នុងឆ្នាំ២០២៣-២០២៤នេះ នៅខេត្តមណ្ឌលគិរី បានការបើកថ្នាក់បំពេញវិជ្ជាទុតិយភូមិ ១ថ្នាក់ ដោយអនុវត្តនៅស្រុកកោះញែក ដែលមានអ្នកចុះឈ្មោះចូលរៀនសរុបចំនួន២៧នាក់ ស្រី២៤នាក់ មកដល់ចុងឆ្នាំអ្នករៀននៅសល់សរុប២៤នាក់ ស្រី២២នាក់ និងបានដាក់ពាក្យប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សរុប២៤នាក់ ស្រី២២នាក់ បានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិសរុបចំនួន១៨នាក់ ស្រី១៦នាក់ ។ រីឯស្វ័យ រៀនបំពេញវិជ្ជា បានដាក់ពាក្យប្រឡងសញ្ញាបត្រ

មធ្យមសិក្សាទុតិយភូមិសរុបចំនួន០១នាក់ ស្រី០០នាក់ បានប្រឡងជាប់ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សរុបចំនួន ០១នាក់ ស្រី ០នាក់។

ការងារមជ្ឈមណ្ឌលសិក្សាសហគមន៍២០២៤

ល.រ	ក្រុង/ស្រុក	ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍		ចំនួនអ្នកគ្រប់គ្រង	
		សរុប	មានដំណើរការ	សរុប	ស្រី
	ស្រុកកែវសីមា	1	1	5	1
	ស្រុកកោះញែក	2	2	10	4
	ស្រុកអូររាំង	1	1	5	3
	ស្រុកពេជ្រាដា	1	គ្មានដំណើរ	5	1
សរុប		5	4	25	9

តាមតារាងការងារមជ្ឈមណ្ឌលសិក្សាសហគមន៍ឆ្នាំ២០២៤នេះ បង្ហាញថា៖មានស្រុកចំនួន០៣ស្រុក ដែលមានមជ្ឈមណ្ឌលសិក្សាសហគមន៍ដំណើរការ ក្នុងនោះមាន ស្រុកកែវសីមាចំនួន០១មសស ស្រុកកោះញែកមានចំនួន០២មសស ស្រុកអូររាំងមានចំនួន០១មសស ស្រុកពេជ្រាដាមានចំនួន០១មសស (គ្មានដំណើរការ រកគ្រូជំនាញមិនបាន) ។ ហើយនៅក្នុងនោះ មានគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍សរុបចំនួន២៥នាក់ ស្រី៩នាក់ ។ ដែលគណៈគ្រប់គ្រងទាំងអស់បានចូលរួមធ្វើការងារអភិវឌ្ឍមជ្ឈមណ្ឌលសិក្សាសហគមន៍រយៈពេល១២ខែក្នុងមួយឆ្នាំ និងបានទទួលប្រាក់លើកទឹកចិត្ត ចំនួន១០០.០០០រ (មួយរយពាន់រៀន)ក្នុងមួយខែ ដោយអនុវត្តតាមអនុក្រឹត្យ លេខ២០ អនក្រ.បក ស្តីពី ការគ្រប់គ្រង និងចាត់ចែងសេវាបង្រៀនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធ ចុះថ្ងៃទី០៥ ខែមិនា ឆ្នាំ២០១៥ ។

ខ.ពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

ក្នុងឆ្នាំសិក្សា ២០២៣-២០២៤ នេះ ការិយាល័យអប់រំក្រៅប្រព័ន្ធ មិនបានបើកវគ្គសិក្ខាសាលាស្តីពីការពង្រឹង សមត្ថភាព ភាពជាអ្នកដឹកនាំ គ្រប់គ្រងការងារអប់រំក្រៅប្រព័ន្ធ ដល់មន្ត្រីអប់រំឃុំ/សង្កាត់ ក្រុង/ស្រុក ដែលទទួលបន្ទុកការងារអប់រំក្រៅប្រព័ន្ធ ដោយសារថវិកាយកទៅគាំទ្រស្តង់ដា សាលារៀនគំរូ ។

២.២.៥ អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តបានរៀបចំសេចក្តីណែនាំស្តីពី ការបង្រៀនអប់រំកាយ និងកីឡាក្នុងម៉ោង និងក្រៅម៉ោងសិក្សា ការប្រកួតកីឡាថ្នាក់កម្រង ក្រុង/ស្រុក និងការប្រកួតជ្រើសរើសជើងឯកទូទាំងខេត្ត គ្រប់ភូមិសិក្សា ការប្រកួតកីឡាមហាជនថ្នាក់ក្រុង/ស្រុក ថ្នាក់ខេត្ត និងកីឡាជាតិ ។ អប់រំកាយ និងកីឡា ជាសមាសធាតុសំខាន់មួយរបស់វិស័យអប់រំ ក្នុងការលើកកម្ពស់សុខភាព និងរួមចំណែកជំរុញការសិក្សា ការរៀបចំអភិវឌ្ឍផ្សេងៗ និងរៀបចំកែលម្អហេដ្ឋារចនាសម្ព័ន្ធកីឡាក្នុង និងក្រៅសាលារៀន ដើម្បីជំរុញឱ្យមានការចូលរួមហាត់ប្រាណ លេង

កីឡា និងចូលរួមការប្រកួតកីឡាក្នុងខេត្តមណ្ឌលគិរី ។

- ចុះធ្វើការណែនាំពីការអនុវត្តសៀវភៅគោលកម្មវិធីលម្អិតអប់រំកាយ និងកីឡាបានចំនួន០៧សាលា។
- ចុះជួយសម្របសម្រួលការរៀបចំការប្រកួតកីឡាជ្រើសរើសជើងឯកថ្នាក់ស្រុកប្រចាំឆ្នាំ២០២៣-២០២៤
- រៀបចំការប្រកួតកីឡាសិស្សបឋមសិក្សាជ្រើសរើសជើងឯកថ្នាក់ខេត្តប្រចាំឆ្នាំសិក្សា២០២៣-២០២៤ លើវិញ្ញាសារបាល់ទាត់(កុមារា-កុមារី).បាល់ទះ(កុមារា-កុមារី).អត្តពលកម្ម(កុមារា-កុមារី).ប៊ូល និងប៉េតង់(កុមារា-កុមារី) ដែលមានក្រុមកីឡាករ-កីឡាការិនីសរុបចំនួន២៥៨នាក់ស្រី១១០នាក់ ។
- រៀបចំការប្រកួតកីឡាសិស្សមធ្យមសិក្សាជ្រើសរើសជើងឯកថ្នាក់ខេត្តប្រចាំឆ្នាំសិក្សា២០២៣-២០២៤ លើវិញ្ញាសារ បាលទាត់(បុរស-នារី).បាល់ទះ(បុរស-នារី).អត្តពលកម្ម(បុរស-នារី).ប៊ូល និងប៉េតង់(បុរស-នារី) ដែលមានក្រុមកីឡាករ-កីឡាការិនីសរុបចំនួន៣៧២នាក់ស្រី១៦២នាក់
- ដឹកនាំប្រតិភូកីឡា ចំនួន១២១នាក់ ស្រី៥០នាក់ ចូលរួមការការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិលើប្រភេទកីឡាបាល់ទាត់(កុមារា-កុមារី).បាល់ទះ(កុមារា-កុមារី).អត្តពលកម្ម(កុមារា-កុមារី).ប៊ូល និងប៉េតង់ និងតៃក្វាន់ដូ(កុមារា-កុមារី)ជាលទ្ធផលតៃក្វាន់ដូទទួលបានមេដាយមាស០១គ្រឿង មេដាយប្រាក់០១គ្រឿង
- ដឹកនាំប្រតិភូកីឡា ចំនួន១៣៦នាក់ ស្រី៤៤នាក់ ចូលរួមការការប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ជាតិលើប្រភេទកីឡាបាល់ទាត់(បុរស-នារី).បាល់ទះ(បុរស-នារី). ប៊ូល និងអត្តពលកម្ម(បុរស-នារី).ប៉េតង់ និងតៃក្វាន់ដូ(កុមារា-កុមារី) ជាលទ្ធផល កីឡាអត្តពលកម្មទទួលបានមេដាយ សំរិទ្ធ០១គ្រឿង ។
- រៀបចំការប្រកួតកីឡាមហាជនជ្រើសរើសជើងឯកថ្នាក់ខេត្តពានរង្វាន់បាល់ទាត់ ឯកឧត្តមអភិបាលខេត្តមណ្ឌលគិរី ឆ្នាំ២០២៤ នេះមានប្រតិភូកីឡាចូលរួមសរុបចំនួន ១២ក្រុម ស្មើនឹង ៣០០នាក់
- ដឹកនាំប្រតិភូកីឡាចំនួន១៣១នាក់ ស្រី៥២នាក់ ទៅចូលរួមការប្រកួតកីឡាជាតិលើកទី៤ ទទួលបានមេដាយមាស០១គ្រឿង មេដាយប្រាក់០៧គ្រឿង និងមេដាយសំរឹទ្ធ១២គ្រឿង

តារាងទី១៖ ស្ថិតិទីលានកីឡា

បរិយាយ	ឆ្នាំសិក្សា				
	2019-2020	2020-2021	2021-2022	2022-2023	2023-2024
ទីលានបាល់ទាត់	14	14	14	15	15
ទីលានបាល់ទះ	18	18	18	20	20
ទីលានបាល់បោះ	05	05	05	05	05
ទីលានលោតកម្ពស់	10	10	10	12	10
ទីលានលោតចម្ងាយ	10	10	10	12	12
ទីលានប៊ូល និងបេតង់	03	04	04	05	06
គ្រូអប់រំកាយ និងកីឡា	19/03	21/03	21/03	21/02	21/03

តារាងទី២៖ចំនួនកីឡាករ កីឡាការិនី ចូលរួមប្រកួតថ្នាក់ខេត្ត និងថ្នាក់ជាតិ

បរិយាយ	ឆ្នាំសិក្សា				
	2019-2020	2020-2021	2021-2022	2022-2023	2023-2024
ប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ខេត្ត	192/96	00	00	140/120	258/110
ប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ខេត្ត	408/198	00	390/144	342/171	372/162
ប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិ	00	00	55/12	121/50	96/48
ប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ជាតិ	00	00	00	136/44	00
ប្រកួតកីឡាមហាជនថ្នាក់ខេត្ត	00	00	400/00	325/00	300/00
ការប្រកួតកីឡាកីឡាជាតិ	00	00	76/07	00	131/52

តារាងទី៣៖ ចំនួនមេដាយដែលទទួលបានពីការប្រកួតកីឡា

បរិយាយ	ឆ្នាំសិក្សា				
	2019-2020	2020-2021	2021-2022	2022-2023	2023-2024
ប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិ	00	00	02គ្រឿង	02គ្រឿង	01គ្រឿង
ប្រកួតកីឡាសិស្សមធ្យមសិក្សាថ្នាក់ជាតិ	00	00	00	01គ្រឿង	00
ប្រកួតកីឡាថ្នាក់ជាតិ	04	00	06គ្រឿង	04គ្រឿង	00
ការប្រកួតកីឡាកីឡាជាតិ	00	00	05គ្រឿង	00	20គ្រឿង

២.២.៦ ការអភិវឌ្ឍយុវជន

ក.ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់ទិស័យកីឡា

ក្នុងឆ្នាំសិក្សា២០២៣-២០២៤មន្ទីរអប់រំយុវជន និងកីឡា ដែលមានការិយាល័យយុវជន និងកីឡា បានអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន អនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា អនុវត្តតាមផែនការប្រតិបត្តិប្រចាំឆ្នាំ និងទិសដៅការងារសម្រេចបានក្នុងការងារចុះជួយរៀបចំ និងបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាយុវជនកម្ពុជា និងក្រុមប្រឹក្សាកុមារកម្ពុជា តាមគ្រឹះស្ថានសិក្សា នៃរដ្ឋបាលក្រុង/ស្រុកទាំង៥ ។

ក.ការងារក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជន

- មានក្រុមប្រឹក្សាកុមារចំនួន៦៥ក្រុម ស្មើនឹង២៦៩សាខា ចែកចេញ១.៣៤៥អនុសាខា មានសមាជិកសរុបចំនួន៨.៤០៥នាក់ស្រី៦.៩១៨នាក់ ។
- ក្រុមប្រឹក្សាយុវជនចំនួន០៦ក្រុម ស្មើនឹង៥៤សាខា ចែកចេញ២៧០អនុសាខា មានសមាជិកសរុបចំនួន ២.២៩៧នាក់ស្រី១.២៧៣នាក់ ។
- ចុះជួយរៀបចំរចនាសម្ព័ន្ធក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជនបានចំនួន០៥សាលា។

- ចុះពិនិត្យ និងណែនាំការអនុវត្តការងារក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជន នៅវិទ្យាល័យហ៊ុន សែនកោះញែក និងសាលាបឋមសិក្សាហ៊ុន សែនកោះញែក
- បើកវគ្គបំប៉នផ្សព្វផ្សាយស្តីពី«ការងារយុវជនស្ម័គ្រចិត្ត»នៅថ្នាក់ក្រុង/ស្រុក ដែលប្រព្រឹត្តិទៅចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០២៤ នៅសាលប្រជុំមន្ទីរអប់រំយុវជន និងកីឡា មានសិក្ខាមចូលរួមសរុបចំនួន៥០នាក់ ស្រី៣០នាក់
- បើកវគ្គបំប៉ន«ការផ្សព្វផ្សាយការងារក្រុមប្រឹក្សាយុវជនថ្នាក់ក្រុង/ស្រុក» ដែលប្រព្រឹត្តិទៅចាប់ពីថ្ងៃទី០៨ដល់ថ្ងៃទី០៩ ខែ កក្កដា ឆ្នាំ២០២៤ នៅកម្រងស្រែក្លែង ក្នុងស្រុកពេជ្រាដា មានសិក្ខាមចូលរួមសរុបចំនួន៥០នាក់ ស្រី២៩នាក់
- យុវជនកាយរឹទ្ធិចំនួន៥០នាក់ស្រី៣៥នាក់បានចូលរួមវគ្គសមាជិភាពកាយរឹទ្ធិកម្ម និងពិធីបំពាក់កន្សែងនៅកងឯកភាពក្នុងអនុវិទ្យាល័យទួលព្រីង
- លោកគ្រូដឹកនាំ និងយុវជនចំនួន១៤នាក់ បានចូលរួមវគ្គតម្រង់ទិសយុវជនសម្រាប់អនុវត្តគម្រោងក្នុងកម្មវិធី"ផែនការអាជីកម្មខ្ញុំ" ឆ្នាំ២០២៤ តាមប្រព័ន្ធអនឡាញ
- ប្រតិភូយុវជន ចំនួន០៥នាក់ស្រី០៣នាក់ចូលរួមការប្រកួតម្មវិធី " ជជែកដេញដោលយុវជនថ្នាក់ជាតិ ឆ្នាំ២០២៤ "
- រៀបចំខួបលើកទី៧៥ នៃទិវាកុមារអន្តរជាតិ ០១ មិថុនា ខួបលើកទី២៣ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៤ ក្រោមប្រធានបទ "វិនិយោគលើកុមារថ្ងៃនេះ សំដៅបង្កើនមូលធនមនុស្សក្នុងយុគសម័យបរិវត្តកម្មឌីជីថល"មានអ្នកចូលរួម៤០០នាក់ស្រី២៦៧នាក់នៅសាលាបឋមសិក្សាស្រែក្លែងស្រុកពេជ្រាដា
- ដឹកនាំប្រតិភូយុវជនចំនួន១០នាក់ ស្រី០៥នាក់ ចូលរួមវគ្គប្រកួតប្រជែងស្នាដៃយុវជនសតវត្សទី២១ ក្រោមប្រធានបទ " STEM ក្នុងវិស័យថាមពល "
- ដឹកនាំប្រតិភូយុវជនកាយរឹទ្ធិរៀមច្បងចំនួន០៦នាក់ស្រី០៣នាក់ ចូលរួមក្នុងកម្មវិធីបោះជំរំកាយរឹទ្ធិរៀមច្បងថ្នាក់ជាតិលើកទី២ ក្រោមប្រធានបទ " ចូលរួមក្នុងកាយរឹទ្ធិកម្ម ដើម្បីវឌ្ឍនភាពអនាគត់របស់ខ្ញុំ " នៅខេត្តកំពង់ធំ
- ដឹកនាំប្រតិភូក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា ចំនួន១០នាក់ស្រី០៦នាក់ ចូលរួមការប្រជុំបូកសរុបចលនាប្រឡងប្រណាំងបីល្អ " កូនល្អ សិស្សល្អ មិត្តល្អ " ក្រោមប្រធាបទ" ការចាប់ផ្តើមរបស់កុមារ និងយុវជន ដើម្បីក្លាយខ្លួនជាប្រជាពលរដ្ឋឌីជីផល " នៅខេត្តសៀមរាប ។

ខ.ការងារមជ្ឈមណ្ឌល

- ផ្សព្វផ្សាយជ្រើសរើសយុវជនស្ម័គ្រចិត្ត ១៥នាក់ ស្រី ០៧នាក់ ដើម្បីចូលរួមកម្មវិធីស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ
- ប្រតិភូយុវជនស្ម័គ្រចិត្ត ចំនួន ១៧ នាក់ស្រី ០៧ នាក់ចូលរួមវគ្គបណ្តុះបណ្តាលកម្មវិធី"ការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ " និងទស្សនកិច្ចសិក្សា នៅខេត្តសៀមរាប

- ដឹកនាំប្រតិភូយុវជនស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ពុំ ចំនួន០៦នាក់ ស្រី០៣នាក់ចូលរួមការប្រកួតផ្តាច់ព្រ័ត្រកម្មវិធីស្តីពី ការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ពុំ និងប្រារព្ធទិវាអន្តរជាតិអ្នកស្ម័គ្រចិត្ត ៥ ធ្នូ ២០២៤
- រៀបចំកម្មវិធីយុវជន ដើម្បីដឹកនាំយុវជនចូលរួម អភិវឌ្ឍជំនាញទន់ និងបំណិនជីវិតដើម្បីផ្តល់ឱកាសដល់យុវជន ដើម្បីទទួលបានបទពិសោធន៍ ការលើកទឹកចិត្ត និង ការបំផុសគំនិតពីអ្នកជំនាញ វាគ្មិន និងជនគំរូនានា

គ.ការងារកាយរឹទ្ធិ

- បើវគ្គបំប៉នស្តីពីការពង្រឹកសមាជិកភាពកាយរឹទ្ធិនិងបណ្តុះបណ្តាលជំនាញការឹទ្ធិកម្មមានអ្នកចូលរួម ៥០នាក់ ស្រី ៣៤នាក់ ពិធីបំពាក់កន្សែងដល់សមាជិកថ្មី
- យុវជនកាយរឹទ្ធិ ចំនួន៥០នាក់ ស្រី៣៥នាក់ចូលរួមសម្របសម្រួលក្នុងកម្មវិធី ការប្រកួតកីឡាសិស្សបឋមសិក្សានិងមធ្យមសិក្សាជ្រើសរើសជើងឯកថ្នាក់ខេត្តប្រចាំឆ្នាំសិក្សា២០២៣-២០២៤
- ដឹកនាំប្រតិភូយុវជនកាយរឹទ្ធិរៀមច្បងចំនួន៦នាក់ស្រី០៣នាក់ ចូលរួមក្នុងកម្មវិធីបោះដំរំកាយរឹទ្ធិរៀមច្បងថ្នាក់ជាតិលើកទី២ ក្រោមប្រធានបទ " ចូលរួមក្នុងកាយរឹទ្ធិកម្ម ដើម្បីវឌ្ឍនភាពអនាគត់របស់ខ្ពុំ " នៅខេត្តកំពង់ធំ ជាលទ្ធផលទទួលបានការរស់នៅជាក្រុម មានគំនិតឆ្នៃប្រឌិត ចេះដោះស្រាយបញ្ហា ចេះស្រលាញ់បរិស្ថាន វប្បធម៌ប្រពៃណី។

ខ.ពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីរបស់រំគ្រប់លំដាប់ថ្នាក់

- ការពង្រឹងប្រព័ន្ធគ្រប់គ្រង និងពិនិត្យតាមដានផ្អែតលើលទ្ធផល
- ការអភិវឌ្ឍសមត្ថភាព
- ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនល្អ
- ការលើកទឹកចិត្ត និងការតែងតាំង

៣.បញ្ហាប្រឈម

៣.១ អនុវិស័យ

៣.១.១ អនុវិស័យការអប់រំកុមារតូច

- ការពង្រីកថ្នាក់មត្តេយ្យក្នុងបឋមសិក្សាពុំទាន់បានទូលំទូលាយ ដោយសារខ្វះគ្រូក្របខណ្ឌមត្តេយ្យសិក្សា ខ្វះអគារសិក្សា និងបន្ទប់
- ថ្នាក់មត្តេយ្យសិក្សាសហគមន៍ ពុំទាន់មានដំណើរការល្អប្រសើរនៅឡើយ ដោយសារមានការផ្លាស់ប្តូរគ្រូ
- ថ្នាក់មត្តេយ្យសិក្សាសហគមន៍ពុំមានលទ្ធភាពក្នុងការកែលម្អរបន្ទប់រៀនដោយខ្វះថវិកានិងការគាំទ្រនៅមានកម្រិត
- មត្តេយ្យសិក្សាសហគមន៍ដែលជាប់ស្តង់ដាការបើកប្រាក់ខែមានការយឺតយ៉ាវ ជាហេតុធ្វើឱ្យដំណើរការបង្រៀន និងរៀនមានភាពឬអាក់រអួល(១ត្រីមាសបើកម្តង)

- សិស្សនៅមានការបោះបង់ដោយសារឪពុកម្តាយទៅស្រែចម្ការ និងពុំមានអ្នកដូនមកសាលារៀន
- នាយក/នាយិកា មានការងាររច្រើនការងាររដ្ឋបាល និងការងារបង្រៀន និងរៀន
- សិស្សអវត្តមាន និងមានការផ្លាស់ប្តូរទីលំនៅ
- ទីធ្លាសាលាមិនទាន់មានភាពទាក់ទាញកុមារនៅឡើយសាលាមួយចំនួន
- សាលាដែលអនុវត្តគម្រោង GEIP អនុវត្តសកម្មភាពមិទាន់តាមតម្រូវការនៃកម្មវិធី
- សាលាដែលអនុវត្តគម្រោង GEIPការធ្វើតេស្តភ្នែកមានការពិបាក
- នាយក/នាយិកាជំនាញ ICT នៅមានកម្រិត
- ការិយាល័យពុំមានលទ្ធភាពផ្គត់ផ្គង់សម្ភារៈដល់ថ្នាក់មត្តេយ្យសិក្សាសហគមន៍

៣.១.២. អនុវិស័យការអប់រំបឋមសិក្សា

- សាលារៀនមួយចំនួនជារោងដោល
- ខ្វះគ្រូបង្រៀនតាមសាលារៀនមួយចំនួន
- ការអនុវត្តវិធីសាស្ត្របង្រៀនតាមកញ្ចប់សម្ភារអំណានថ្នាក់ដំបូងមិនតាមដំហាន
- គ្រូឈរថ្នាក់មួយចំនួនមិនប្រើប្រាស់សម្ភារៈឧបទេសជំនួយក្នុងការបង្រៀននិងរៀន
- មិនអនុវត្តពេលវេលាក្នុងការបង្រៀន
- បង្រៀនមិនទាន់កម្មវិធីនិងមិនចប់កម្មវិធី
- ការប្រមូលកុមារដល់វ័យសិក្សាមិនបាន១០០%
- អត្រាត្រួតថ្នាក់អត្រាបោះបង់មិនទាន់ឆ្លើយតមទៅនិងទិសដៅរបស់ក្រសួង
- គ្រូបង្រៀនមួយចំនួនមិនអនុវត្តតាមកាលវិភាគ
- បរិស្ថានសាលារៀនមួយចំនួនមិនមានភាពទាក់ទាញ
- ការងារទំនាក់ទំនងគ្រូនិងនាយក/នាយិកាមិនទាន់បានរលូននៅឡើយ
- ការងារទំនាក់ទំនងរវាងសាលានិងសហគមន៍មិនទាន់បានល្អ
- សាលាដែលការអនុវត្តគម្រោង GEIP នៅសកម្មភាពទាំង១០ និងកិច្ចការទាំង៥របស់នាយក គ្រូមិនទាន់បានគ្រប់សាលានៅឡើយ
- នាយក/នាយិកាមួយចំនួន ការប្រើប្រាស់កុំព្យូទ័រនៅមានកម្រិត
- នាយក/នាយិកា និងលោកគ្រូអ្នកគ្រូមួយចំនួននៅមិនទាន់យល់ច្បាស់ពីសូចនាករស្តង់ដាសាលាគំរូ
- សាលារៀនមួយចំនួនមិនទាន់មានលទ្ធភាពអនុវត្តគ្រប់គ្រាន់សម្រាប់អនុវត្តស្តង់ដាសាលាគំរូ

៣.១.៣ អនុវិស័យការអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស

- គ្រូបង្រៀនមួយចំនួនពុំបានអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ឱ្យបានទាន់នឹងសភាពការអភិវឌ្ឍនាពេលបច្ចុប្បន្ន (ការបង្រៀននៅអនុវត្តលើវិធីសាស្ត្រដដែលៗ)
- ខ្វះអគារសិក្សានៅវិទ្យាល័យ ហ៊ុន សែន កែវសីមា និងវិទ្យាល័យ មេម៉ង់ ដោយសាលារៀបចំបង្រៀនជាពីរវេណ

- អនុវិទ្យាល័យមិនទាន់មានគ្រប់ឃុំ សង្កាត់ដែលធ្វើឱ្យសិស្សមួយចំនួនបោះបង់ការសិក្សា
- ខ្វះគ្រូបង្រៀនលើមុខវិជ្ជា គីមីវិទ្យា ភូមិវិទ្យា ប្រវត្តិវិទ្យា ភាសាអង់គ្លេស ភាសាបារាំង ព័ត៌មានវិទ្យា និងគ្រូផ្នែកបច្ចេកទេសដើម្បីបង្រៀននៅវិទ្យាល័យចំណេះទូទៅ និងបច្ចកទេស
- សាលារៀនមួយចំនួនខ្វះសម្ភារ និងឧបករណ៍ពិសោធន៍សម្រាប់ប្រើប្រាស់ពេលបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ
- បាត់ម៉ោងសិក្សាច្រើន(កម្មវិធីបុណ្យផ្សេងៗក្រៅផ្លូវការ គ្រូចូលបង្រៀនក្រោយម៉ោង និងចេញមុនម៉ោងកំណត់)
- ការអនុវត្តធ្វើតេស្តស្តង់ដានៅចុងឆ្នាំ ដើមឆ្នាំ ប្រចាំខែ មិនទាន់អនុវត្តបានព្រមគ្នា និងមិនបានប្រើប្រាស់វិញ្ញាសាស្តង់ដារបស់ក្រសួងឱ្យបានត្រឹមត្រូវ
- សាលាអនុវត្តគម្រោង GEIP មួយចំនួនពុំបានអនុវត្តឱ្យបានពេញលេញធ្វើឱ្យលទ្ធផលនៃការសិក្សាមិនទាន់បានល្អប្រសើរ គ្រូបង្រៀនមួយចំនួនតូចមិនសូវយកចិត្តទុកដាក់ក្នុងការជួយដល់សិស្សរៀនយឺតឱ្យទទួលបាននូវលទ្ធផលសិក្សាបានល្អដូចសិស្សដ៏ទៃទៀត
- គណៈគ្រប់គ្រងសាលារៀនមួយចំនួននៅមាការទំនាក់ទំនងរវាងសាលារៀន សហគមន៍ ពុំទាន់បានល្អប្រសើរដើម្បីជួយអភិវឌ្ឍសាលារៀននៅឡើយ
- អត្រាបោះបង់ការសិក្សារបស់សិស្សនៅពុំទាន់បានកាត់បន្ថយ

៣.១.៤ អនុវិស័យការអប់រំក្រៅប្រព័ន្ធ

១-ការផ្តល់សេវាអប់រំ (តំបន់ភូមិសាស្ត្រ ស្ថានភាពសង្គម-សេដ្ឋកិច្ច យេនឌ័រ និងកត្តាឆ្លងផ្នែកផ្សេងៗ)

- ការផ្តល់ក្របខណ្ឌនៃការប្រើប្រាស់គ្រូជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធមានចំនួនតិចតួច
- ភូមិ ឃុំ/សង្កាត់ខ្លះមិនមានការស្នើសុំបើកថ្នាក់កម្មវិធីអប់រំក្រៅប្រព័ន្ធ
- ភូមិ ឃុំ/សង្កាត់ខ្លះ បើកដំណើរការថ្នាក់ហើយ មិនរក្សាលំនឹងនិរន្តរភាពក្នុងដំណើរការថ្នាក់កម្មវិធីអប់រំក្រៅប្រព័ន្ធ (បើកហើយ ក៏បិទទៅវិញ)
- កន្លែងខ្លះ អ្នករៀនមិនបានគ្រប់និយាយតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា ។

២-ការទទួលសេវាអប់រំ (ខ្វះសាលារៀន និងខ្វះបន្ទប់រៀន...)

- ភូមិខ្លះនៅឆ្ងាយ ខ្វះធនធានជាគ្រូបង្រៀន មិនមានអ្នកស្ម័ក្រចិត្តទៅដល់
- ការចូលរួមរបស់ក្រុមមុខសញ្ញាមិនសូវបានពេញលេញ រវល់ការងារបង្កបង្កើនផល និងរវល់រកប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារ ។
- អ្នកសិក្សាមករៀនមិនចប់កម្មវិធី

៣-ប្រសិទ្ធភាព និងគុណភាពនៃសេវាអប់រំ (ខ្វះគ្រូបង្រៀនតាមមុខវិជ្ជា និងខ្វះបណ្ណាល័យ...)

- រយៈពេលពង្រឹងសមត្ថភាពគ្រូកម្មវិធីអប់រំក្រៅប្រព័ន្ធ មានរយៈពេលខ្លីពេក ធ្វើឱ្យការកសាងគ្រូកម្មវិធីអប់រំក្រៅប្រព័ន្ធនៅមានកម្រិត
- ខ្វះគ្រូគ្រប់គ្រងបណ្ណាល័យ(ខ្វះអនុរក្ស)

៤.មន្ត្រីទទួលបន្ទុកការងារអប់រំក្រៅប្រព័ន្ធថ្នាក់ឃុំ/សង្កាត់ ក្រុង/ស្រុក មានការមមាញឹកច្រើនក្នុងការងារក្នុងប្រព័ន្ធ

- ធនធានថវិកាសម្រាប់ដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍នៅមានកម្រិត
- ក្រុមមុខសញ្ញ (អនក្ខរជន និងសិស្សបោះបង់ យុវជនក្រៅសាលា) មិនចង់រៀនសូត្រ

៣.១.៥ អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា

- កង្វះខាតហេដ្ឋារចនាសម្ព័ន្ធកីឡានៅតាមគ្រឹះស្ថានសិក្សា និងមិនត្រូវស្តង់ដា
- ការបង្រៀមេរៀនអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានបឋមសិក្សាមិនទាន់មានគ្រូអប់រំកាយ និងកីឡា
- ការអនុវត្តម៉ោងអប់រំកាយ និងកីឡាក្នុងម៉ោង និងក្រៅម៉ោងសិក្សានៅតាមគ្រឹះស្ថានសិក្សានៅមិនទាន់ពេញលេញ តាមលិខិតណែនាំរបស់ក្រសួង
- មានសៀវភៅសិក្សាគោលអប់រំកាយ និងកីឡា តែមិនទាន់មានការណែនាំ និងផ្សព្វផ្សាយពីការអនុវត្ត
- ការប្រកួតកីឡាថ្នាក់កម្រង និងថ្នាក់ក្រុង/ស្រុកមិនទាន់បានបញ្ចូលគ្រប់វិញ្ញាសាតាមការណែនាំរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត
- សលារៀនមួយចំនួនមិនទាន់មានប្រភេទកីឡាចូលរួមការប្រកួតថ្នាក់កម្រង និងថ្នាក់ក្រុង/ស្រុក
- ការរៀបចំការប្រកួតកីឡាថ្នាក់កម្រង និងថ្នាក់ក្រុង/ស្រុកមិនទាន់ពេលវេលាតាមការការណែនាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្ត

៣.១.៦ អនុវិស័យការអភិវឌ្ឍយុវជន

- ខ្វះលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំសម្រាប់កម្មវិធីអភិវឌ្ឍយុវជន
- កង្វះមន្ត្រីទទួលបន្ទុក ដែលមានសមត្ថភាពជំនាញកិច្ចការយុវជន មជ្ឈមណ្ឌល និងកាយវិទ្ធិកម្មនៅតាមសាលារៀន
- ការងារក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាយុវជន និងក្លឹបសិក្សានៅសាលារៀន ពុំទាន់បានរៀបចំ និងមានដំណើរការល្អនៅឡើយ
- ការចូលរួមគាំទ្រពីក្រុមប្រឹក្សាភិបាល និងទីប្រឹក្សា ដែលជាអ្នកអនុវត្តផ្ទាល់ជាមួយគណៈកម្មាធិការប្រតិបត្តិមិនទាន់ពេញលេញ ខ្វះការគាំទ្រ
- មន្ត្រីទទួលបន្ទុកនៅតាមសាលារៀនផ្លាស់ប្តូរញឹកញាប់
- សកម្មភាពការងារស្ម័គ្រចិត្តរបស់យុវជន ក្នុងការចូលរួមនៅមានកម្រិត ពុំសូវមានយុវជនចូលរួម

៣.២ ឆ្លងអនុវិស័យ

៣.២.១ ការិយាល័យសុខភាពសិក្សា

- ទឹកស្អាតសម្រាប់ទទួលទានក្នុងសាលារៀនមិនទាន់មានគ្រប់សាលារៀន ជាពិសេស តំបន់ឆ្ងាយៗ ពីទីប្រជុំជន
- ការបោះពុម្ពសៀវភៅសិក្សាគោលស្តីពីការបង្រៀន មុខវិជ្ជាការអប់រំ សុខភាពសម្រាប់គ្រូ និងសិស្ស សម្រាប់ បង្រៀន ពីថ្នាក់ទី១ ដល់ទី១២ នៅមិនទាន់គ្រប់គ្រាន់នៅឡើយ។

- បន្ទប់សុខភាពសិក្សា នៅតាមគ្រឹះស្ថានសិក្សា មិនទាន់បានបង្កើតឱ្យបានគ្រប់គ្រាន់ តាមតម្រូវការ។
- សុវត្ថិភាព ការលក់ដូរចំណីអាហារតាមសាលារៀន នៅមិនទាន់មានរបៀបរយនៅឡើយដោយ
- ខ្វះការត្រួតពិនិត្យពី គណៈកម្មការសុខភាពតាមគ្រឹះស្ថាន និងកាំកុងត្រូល
- ការចូលរួម របស់គណៈការសុខភាព ថ្នាក់ស្រុក សាលារៀន និងអាជ្ញាធរគ្រប់លំដាប់មិនទាន់បានទូលំទូលាយ ដោយសារ ខ្វះការយល់ដឹងលើការងារសុខភាពសិក្សា។
- សាលារៀនមួយចំនួនមិនទាន់មានការទទួលខុសត្រូវក្នុងការថែទាំ បង្គន់ អណ្តូង ទឹកស្អាននិងកន្លែងលាងដៃឱ្យបានល្អប្រសើរនៅឡើយ
- ខ្វះសៀវភៅសិក្សាគោលសម្រាប់បង្រៀន និងរៀន មុខវិជ្ជាអប់រំសុខភាពគ្រប់កម្រិតថ្នាក់
- ការបណ្តុះបណ្តាលគ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាព មិនទាន់ឆ្លើយតបតាមតម្រូវការ
- ខ្វះគ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាព (មធ្យមសិក្សា)
- ខ្វះសម្ភារៈសម្រាប់បំពាក់ដាក់បន្ទប់សុខភាពដែលបានបង្កើតថ្មី
- ការលក់ចំណីអាហារនៅតាមសាលារៀនមួយចំនួនពុំមានអនាម័យ
- ការទទួលថ្នាំទម្លាក់ព្រូនពីមណ្ឌលសុខភាពមិនបានគ្រប់ចំនួនតាមផែនការ
- ខ្វះថ្នាំវ៉ាក់សាំងចាក់ការពារ ជំងឺមហារីកដៃស្បូនសម្រាប់កុមារីអាយុ៩ឆ្នាំ
- ខ្វះសៀវភៅតាមដានសុខភាព សម្រាប់ផ្តល់ជូនដល់សិស្សក្នុងសាលាស្តង់ដាគំរូ និងសាលាធម្មតា
- ខ្វះការគាំទ្រផ្នែកអាហារូបត្ថម្ភ ដល់សាលារៀន គ្រប់ភូមិសិក្សា

៣.២.២ ការិយាល័យរដ្ឋបាល .បុគ្គលិក និងបណ្តុះបណ្តាល

- ខ្វះគ្រូបង្រៀនតាមមុខវិជ្ជាឯកទេសនៅតាមវិទ្យាល័យ និងអនុវិទ្យាល័យ
- ការប្រមូលឯកសារពីសាលា /ពីស្រុកមានការយឺតយ៉ាវ
- ការប្រមូលទិន្នន័យក្នុងប្រព័ន្ធធនធានមនុស្ស(HRMIS)តាមសាលាមានការយឺតយ៉ាវ
- មិនមានថវិកាសម្រាប់បំប៉នដល់មន្ត្រីអប់រំតាមក្រុង/ស្រុក និងសាលារៀន
- សាលាមួយចំនួនមិនមានប្រព័ន្ធ Internet ក្នុងការប្រើប្រាស់ប្រព័ន្ធ(HRMIS)

៣.២.៣ ការិយាល័យគណនេយ្យ សម្ភារ និងទ្រព្យសម្បត្តិរដ្ឋ

- ការចុះពិនិត្យតាមដានការអនុវត្តថវិកាកម្មវិធី(រយៈពេលនៃការចុះបេសកកម្មសាលាមួយចំនួនខ្លីមិនសមស្របតាមស្ថានភាពភូមិ សាស្ត្រ និងមានបញ្ហាកញ្ចប់ថវិកាតិចតួច បានតែ១ឆមាស។
- នីតិវិធីរឹទម្រង់របាយការណ៍ចំណាយទូទាត់ថវិកាមានការប្រែប្រួលជារៀងរាល់ឆ្នាំ(មន្ត្រីការិ.គណនេយ្យមួយចំនួនតាមមិនទាន់បច្ចេកទេសព័ត៌មានវិទ្យាបច្ចុប្បន្នសម័យឌីជីថល)
- វគ្គបំប៉នស្តីពីនីតិវិធីឬទម្រង់របាយការណ៍ចំណាយទូទាត់ថវិកាកម្មវិធីមិនបានប្រមូលផ្តុំនៅទីរួមខេត្ត មានតែនៅតាមស្រុកខ្លាច(ប៉ះពាល់ម៉ោងសិក្សារបស់សិស្ស ព្រោះនាយក និងហិរញ្ញិកសុទ្ធតែបង្រៀន)។

៣.២.៤ ការិយាល័យផែនការ និងគ្រប់គ្រងដំឡូយ

- ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀ ៥ឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំមិនទាន់បានគ្រប់ជ្រុងជ្រោយ និងប្រកបដោយគុណភាព ស្របតាមគោលដៅរបស់មន្ទីរអប់រំ និងក្រសួងចង់បាន
- សាលាមួយចំនួនខ្វះទិន្នន័យ ឬស្ថិតិអប់រំគោល ដើម្បីរៀបចំផែនការសាលារៀនឱ្យ ស្របតាមស្ថានភាពជាក់ស្តែងរបស់សាលារៀន
- ការបំពេញទិន្នន័យនៅក្នុងតារាងសម្រង់ពិន្ទុសិស្សតាមមុខវិជ្ជា និងតារាងជំរឿនស្ថិតិសាលារៀនប្រចាំរបស់សាលារៀនមួយចំនួននៅមានកង្វះទិន្នន័យ (បំពេញមិនត្រឹមត្រូវ មិនគ្រប់គ្រាន់ និងទាន់ពេល)
- សាលារៀននៅគ្រប់កម្រិតសិក្សា ភាគច្រើនមិនទាន់ចេះសរសេររបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ

៣.២.៥ ការិយាល័យអធិការកិច្ច

- ការរៀបចំវិញ្ញាសាតេស្តស្តង់ដានៅតាមសាលារៀបពុំទាន់បានសមស្របតាមលក្ខណៈស្តង់ដា
- បុគ្គលិកមានចំនួនតិច(០៣នាក់)មិនគ្រប់គ្រាន់តាមនិយាមប្រើប្រាស់ក្នុងការិយាល័យ
- កញ្ចប់ថវិកាក្នុងការិយាល័យមានចំនួនតិចសម្រាប់ចុះធ្វើអធិការកិច្ចមិនបានតាមផែនការគ្រោងទុករបស់ការិយាល័យ

៤-ទិដ្ឋភាពការងារឆ្នាំសិក្សា២០២៣-២០២៤

៤.១-ទិសដៅអនុវិស័យ

៤.១.១ អនុវិស័យការអប់រំកុមារតូច

១-កំណត់ទីតាំងសម្រាប់បើកថ្នាក់មត្តេយ្យ(កុមារអាយុ៥ឆ្នាំ)ត្រៀមសម្រាប់ចូលរៀនថ្នាក់ទី១ នៅឆ្នាំសិក្សាថ្មី សម្រាប់កម្មវិធី៨សប្តាហ៍
២-បន្តធ្វើយុទ្ធនាការផ្សព្វផ្សាយលិខិតបទដ្ឋាននានានៅតាមសាលានិងការិយាល័យអប់រំក្រុង/ស្រុក
៣-បន្តពង្រីកមត្តេយ្យសិក្សាសហគមន៍ឱ្យបាន២កន្លែង
៤-លើកម្ពស់គុណភាពនិងប្រសិទ្ធភាពការងារអប់រំកុមារតូច តាមរយៈបំណិនទាំង៥របស់កុមារ
៥-បន្តសហការជាមួយអាជ្ញាធរដែនដីនិងអង្គការ ដៃគូអភិវឌ្ឍនានាដើម្បីផ្តល់ថវិកាពង្រីកកម្មវិធីអប់រំមត្តេយ្យសិក្សាតាមគ្រប់រូបភាព
៦-ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការងារអប់រំកុមារតូចដើមឆ្នាំ ឆមាសទី១ និងបំណាច់ឆ្នាំ
៧-បន្តជំរុញថ្នាក់មត្តេយ្យផ្នែកពហុភាសាឱ្យដំណើរការបានល្អ
៨-បង្កើនភាគរយកុមារអាយុ ៣ឆ្នាំឱ្យដល់ ១៨% ស្រី ១៩,៥% កុមារអាយុ ៤ឆ្នាំឱ្យដល់ ៣៩,៥០% ស្រី ៥១% និងកុមារអាយុ ៥ឆ្នាំឱ្យដល់ ៤៤,៥០% ស្រី ៤៥,៥%
៩-ចុះជួយគាំទ្រផ្នែកវិធីសាស្ត្រដល់គ្រូមត្តេយ្យទូទាំខេត្ត
១០-ជួយគាំទ្រថ្នាក់មត្តេយ្យដែលជាប់ស្តង់ដា សម្រាប់ឆ្នាំ ២០២៤-២០២៥

១១-ចុះជួយគាំទ្រការអនុវត្តស្តុកមារ៥ឆ្នាំឱ្យបាន១០ថ្នាក់
១២-ជំរុញមាតាបិតាឱ្យបញ្ជូនកូនមករៀនបានទៀងទាត់
១៣-ចុះជួយរៀបចំថ្នាក់រៀនឱ្យបានសមស្រប(៥សាលា)
១៤-ផ្សព្វផ្សាយការរៀនតាមរយៈការលេងដល់មត្តេយ្យសិក្សាទូទាំងខេត្ត
១៥-រុញការផលិតសម្ភារៈរៀននិងបង្រៀនទាំង៥ក្រុង/ស្រុក

៤.១.២. អនុវិស័យការអប់រំបឋមសិក្សា

១-បង្កើនអត្រាពិតចូលរៀនថ្មីពី ៧២,៦% ទៅ ៨៥%
២-កាត់បន្ថយអត្រាបោះបង់ពី ៧% មកត្រឹម ៦%
៣-បង្កើនអត្រាពិតនៃការសិក្សាពី៩៦% ប្រុស ៩៤,១% ស្រី ៩៨% ទៅ ៩៨% ប្រុស ៩៥% ស្រី ៩៩%
៤-កាត់បន្ថយអត្រារួមនៃការសិក្សាមពី ១១០,៤% ប្រុស១០០,៣% ស្រី ១១០,៦% ទៅ ១០៥% ប្រុស ១០០% ស្រី១០៥%
៥-កាត់បន្ថយអត្រាត្រួតថ្នាក់ ៥% ប្រុស ៦,៨% ស្រី ៣,៣% មកនៅត្រឹម ៤,៥០% ប្រុស៥,៥០% ស្រី២,៥០%
៦-បន្តចុះជួយគាំទ្រដល់គ្រូនិងនាយក/នាយិកាសាលា
៧-ធ្វើការវាយតម្លៃសាលាគំរូទូទាំងខេត្ត
៨-បន្តអនុវត្តប្រឡងសិស្សពូកែអានអត្ថបទ
៩-ជំរុញការប្រឡងបញ្ចប់ថ្នាក់ទី៦ឡើងថ្នាក់ទី៧
១០-ជំរុញនាយក/នាយិកាឱ្យអនុវត្តកម្មវិធីស្តង់ដាសាលារៀនគំរូដើម្បីប្រែក្លាយសាលារៀនទៅជាសាលាគំរូ
១១-បន្តបំប៉នគ្រូថ្នាក់ទី១លើវិធីសាស្ត្របង្រៀនកញ្ចប់គណិតវិទ្យាសម្រាប់ឆមាសទី២
១២-រំលឹកវិធីសាស្ត្របង្រៀនកញ្ចប់អំណានថ្នាក់ដំបូងថ្នាក់ទី១
១៣-បង្កើនអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា ៩៩,៨% ប្រុស ៩៥% ស្រី ១០០%
១៤-បង្កើនអត្រាឆ្លងភូមិសិក្សាពីបឋមទៅមធ្យម បឋមភូមិ ៨៨,៥% ប្រុស ៩០% ស្រី ៩០,៥%
១៥-បង្កើនអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាយ៉ាងតិច ៨៥% ឱ្យបាន ៤ស្រុក ក្នុងចំណោមក្រុង/ស្រុកទាំង ៥
១៦-បន្តពង្រឹងការអនុវត្តពេលម៉ោងសិក្សាឱ្យបានត្រឹមត្រូវតាមនិយាម
១៧-បង្កើនការយកចិត្តទុកដាក់ពង្រឹងការអនុវត្តលើបទបញ្ញត្តិ ប្រកាសនិងសេចក្តីណែនាំផ្សេង ៗ ឱ្យមានប្រសិទ្ធភាពខ្ពស់ និងទាន់ពេលវេលា
១៨-ពង្រឹងលើការរៀបចំកិច្ចតែងការបង្រៀន និងប្រើប្រាស់សៀវភៅតាមដានការសិក្សា សៀវភៅស្រង់ពិន្ទុ សៀវភៅហៅឈ្មោះ សៀវភៅសិក្ខាគារិក និងការតេស្តសិស្សថ្នាក់មធ្យមភាគដើមឆ្នាំនិងចុងឆ្នាំ
១៩-បន្តធ្វើតេស្តស្តង់ដាគ្រប់កម្រិតថ្នាក់(១-៦) សាលាគោលដៅ ទូទាំងខេត្ត (តេស្ត ដើមឆ្នាំឬចុងឆ្នាំ ត្រី

មាស ឆមាស)

២០-ពង្រឹងយន្តការលើការងារបរិយាប័ន្នសម្រាប់កុមារពិការនិងកុមារងាយរងគ្រោះ ពហុភាសា

២១-បន្តការពង្រីកវិធីសាស្ត្របង្រៀនកញ្ចប់សម្ភារអំណានសម្រាប់ថ្នាក់ទី៣ដល់សាលាទូទាំងខេត្ត

២២-ពង្រីកសាលាបឋមសិក្សាអនុវត្តកម្មវិធីកែលម្អការអប់រំចំណេះទូទៅ (GEIP AF) ១៦សាលា

៤.១.៣ អនុវិស័យការអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស

១-កាត់បន្ថយអត្តាត្រួតថ្នាក់នៅមធ្យមសិក្សាបឋមភូមិត្រឹម ១,២០% ស្រី ០,៨%

២-កាត់បន្ថយអត្រាត្រួតថ្នាក់នៅមធ្យមសិក្សាទុតិយភូមិត្រឹម ០,៥% ស្រី ០,២%

៣-កាត់បន្ថយអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិត្រឹម ១០% ស្រី ៩,៥%

៤-កាត់បន្ថយអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិត្រឹម ៦,៥% ស្រី ៦,៣%

៥-បង្កើនអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិឱ្យបាន ៤៣% ស្រី ៣៨%

៦-បង្កើនអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិឱ្យបាន ៣១,៥% ស្រី ២៨%

៧-បង្កើនអត្ររួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិឱ្យបាន ៥៨% ស្រី ៥៨,៥%

៨-បង្កើនអត្ររួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិឱ្យបាន ២៥,៥% ស្រី ២៦,៥%

៩-បង្កើនអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិឱ្យបាន៤៥% ស្រី ៤៤%

១០-បង្កើនអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិឱ្យបាន ១៩% ស្រី ១៨,៥%

១១-ពង្រឹងលើគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀន តាមរយៈការចុះធ្វើអធិការកិច្ច អចិន្ត្រៃយ៍ របស់នាយក/នាយិកាសាលា និងការចុះជួយគាំទ្រពីមន្ទីរអប់រំយុវជន និងកីឡាខេត្ត

១២-ពង្រឹងលើដំណើរការអនុវត្តតេស្តស្តង់ដាប្រចាំខែ ត្រីមាស និងឆមាសនៅតាមសាលារៀនឱ្យមានប្រសិទ្ធភាពតាមរយៈការប្រើប្រាស់វិញ្ញាសាស្តង់ដារបស់ក្រសួង

១៣-ពង្រឹងដល់ការបង្កើតក្លឹបមុខវិជ្ជាឱ្យបានគ្រប់សាលាមធ្យមសិក្សាទាំងអស់ និងការជួយបង្រៀនបន្ថែម

ក្រៅម៉ោង ការដាក់សន្លឹកកិច្ចការឱ្យសិស្សហ្វឹកហាត់មុនការបង្រៀនរបស់គ្រូ ការដាក់កិច្ចការជាគម្រោងឱ្យសិស្សស្រាវជ្រាវ

១៤-ពង្រឹងការចុះជួយដល់សាលារៀនដើម្បីអនុវត្តលើការវាយតម្លៃស្តង់ដាសាលារៀនគំរូ និងប្រែក្លាយឱ្យមានសាលាមធ្យមសិក្សាចំនួន០៣បានក្លាយជាសាលាស្តង់ដាគំរូនិងសាលាចំនួន០១ឱ្យក្លាយជាសាលាផ្តល់សេវាសាធារណៈគំរូ

១៥-ចូលរួមទស្សនកិច្ចសិក្សាជាមួយសិស្សនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសដើម្បីយកបទពិសោធន៍ថ្មីៗមកអនុវត្តនៅសាលាជាក់ស្តែង

១៥-ចូលរួមក្នុងដំណើរការប្រឡងបញ្ចប់ឆ្នាំទី១ ឆ្នាំទី២ និងទី៣នៃសិស្សនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស

៤.១.៤ អនុវិស័យការអប់រំក្រៅប្រព័ន្ធ

១.សហការជាមួយអាជ្ញាធរ អ្នកពាក់ព័ន្ធ សហគមន៍ ដើម្បីឱ្យមានការចូលរួម ដោយប្រសើរ
២.ជំរុញលើកទឹកចិត្តដល់មន្ត្រីអប់រំក្រៅប្រព័ន្ធឃុំ/សង្កាត់ ក្រុង/ស្រុក ដែលអនុវត្តការងារបានល្អប្រសើរ
៣-មន្ត្រីទទួលបន្ទុកការងារអប់រំក្រៅប្រព័ន្ធមានសមត្ថភាពដឹកនាំការអនុវត្តការងារអប់រំក្រៅប្រព័ន្ធបាន នៅតាមមូលដ្ឋានរបស់ខ្លួន
៤-ចំនួនប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្មប្រែប្រួលពី ៦១នាក់ឆ្នាំ២០២៣ ទៅ ១១៥នាក់ នៅឆ្នាំ២០២៤
៥-មជ្ឈមណ្ឌលសិក្សាសហគមន៍មានការប្រែប្រួលទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ១កន្លែង
៦-បង្កើនអ្នកចូលរៀនក្នុងកម្មវិធីបង្កើនប្រាក់ចំណូលឱ្យបាន ៦០នាក់ស្រី ៤៩នាក់
៧-ចំនួនអ្នកបញ្ចប់កម្មវិធីបង្កើនប្រាក់ចំណូលចំនួន ៤៨នាក់ ឆ្នាំ២០២៣ កើន ៥០នាក់ឆ្នាំ២០២៤
៨-ចំនួនអ្នកចូលរៀនក្នុងកម្មវិធីសមមូលបឋមសិក្សា ៣៣នាក់ឆ្នាំ២០២៣ កើន ៣៥នាក់ឆ្នាំ២០២៤
៩-បន្តធ្វើការពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល កម្មវិធីអប់រំក្រៅប្រព័ន្ធនៅទូទាំងខេត្ត ។

៤.១.៥ អនុវិស័យការអភិវឌ្ឍអប់រំកាយ និងកីឡា

- រៀបចំលិខិតណែនាំស្តីពីការអនុវត្តកម្មវិធីអប់រំកាយក្នុងម៉ោង និងកីឡាក្រៅម៉ោងសិក្សានៅគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សា
- រៀបចំលិខិតណែនាំស្តីពីការរៀបចំការប្រកួតកីឡាសិស្សបឋមសិក្សា និងមធ្យមសិក្សាថ្នាក់កម្រង ក្រុង/ស្រុក និងថ្នាក់ខេត្ត
- ជំរុញការរៀបចំការប្រកួតកីឡាសិស្សបឋមសិក្សា និងមធ្យមថ្នាក់កម្រង និង ក្រុង/ស្រុក
- រៀបចំការប្រកួតជ្រើសរើសជើងឯកថ្នាក់ខេត្តសម្រាប់កីឡាសិស្សបឋមសិក្សា និងកីឡាសិស្សមធ្យមសិក្សា និង កីឡាមហាជន ថ្នាក់ខេត្ត
- រៀបចំការប្រកួតកីឡាពានរង្វាន់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត
- ចូលរួមប្រកួតកីឡាតាមកម្មវិធីរបស់ក្រសួងអប់រំ និងសហព័ន្ធកីឡាជាតិរៀបចំ
- សហការរៀបចំកម្មវិធីអភិវឌ្ឍន៍ "កីឡាបាល់ទាត់តាមសាលារៀន" ក្រោមគម្រោងអភិវឌ្ឍន៍របស់សហព័ន្ធកីឡាបាល់ទាត់កម្ពុជា គាំទ្រដោយសហព័ន្ធកីឡាបាល់ទាត់អន្តរជាតិ (FIFA)
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈសម្រាប់កម្មវិធីអប់រំកាយ និងកីឡា
- សម្រិតសម្រាំងកីឡាករឆ្នើមតាមរយៈការប្រកួតកីឡាសិស្ស កីឡាមហាជន ដើម្បីចូលរួមប្រកួតថ្នាក់ជាតិ និងកីឡាជាតិ
- ពង្រឹងការអនុវត្តសកម្មភាពអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សាឱ្យបានល្អប្រសើរ
- កៀរគរ ទាក់ទាញការចូលរួមឧបត្ថម្ភពីដៃគូវិស័យឯកជន សប្បុរជន និងអង្គការជាតិ អន្តរជាតិ។
- ដឹកនាំប្រតិភូកីឡាសិស្សបឋមសិក្សា ដែលទទួលជ័យលាភីនៅថ្នាក់ខេត្ត ទៅចូលរួមប្រកួតថ្នាក់ជាតិ
- ដឹកនាំប្រតិភូកីឡាសិស្សមធ្យមសិក្សា ដែលទទួលជ័យលាភីនៅថ្នាក់ខេត្ត ទៅចូលរួមប្រកួតថ្នាក់ជាតិ

- ដឹកនាំប្រតិភូកីឡា ចូលរួមប្រកួតកីឡាជាតិលើកទី៥
- បំផុសសមាគមន៍កីឡាមហាជនឱ្យចូលរួមប្រកួតកីឡាគ្រប់ប្រភេទ
- ជំរុញប្រជាជនម្នាក់លេងកីឡាមួយប្រភេទយ៉ាងតិច ប្រចាំជីវិត

៤.១.៦ អនុវិស័យការអភិវឌ្ឍយុវជន

- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំសម្រាប់កម្មវិធីអភិវឌ្ឍយុវជន
- ពង្រឹងចលនាប្រឡងប្រណាំង៣ល្អ ក្លឹបក្រុមប្រឹក្សាយុវជននិងកុមារកម្ពុជា ក្លឹបសិក្សា និងបំណិនជីវិត
- ជម្រុញរៀបចំការប្រជុំបូកសរុបចលនា៣ល្អ ថ្នាក់ខេត្ត
- ចេញលិខិតសរសើរ ដល់សមាជិក និងអង្គភាពដែលមានស្នាដៃល្អ
- ចុះជួយផ្នែកបច្ចេកទេសដល់សមាជិកក្រុមប្រឹក្សាកុមារ និងយុវជន តាមសាលារៀន
- រៀបចំកម្មវិធីទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធ និងបោះជំរំ
- ចូលរួមការបោះជំរំកាយរឹទ្ធិថ្នាក់ជាតិ
- ចូលរួមការប្រជុំបូកសរុបចលនាប្រឡងប្រណាំងបីល្អ
- ចូលរួមកម្មវិធីការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ពុំ
- ចូលរួមកម្មវិធីជជែកដេញដោលយុវជនថ្នាក់ជាតិ
- បង្កើនសកម្មភាពការងារយុវជនស្ម័គ្រចិត្ត តាមរយៈកម្មវិធីប្រកួតប្រជែង ផ្សេងៗ
- សហការជាមួយអង្គការដៃគូដើម្បី បើកវគ្គបំប៉ន សមត្ថភាព លើជំនាញទន់ ភាពជាអ្នកដឹកនាំ ការនិយាយជាសាធារណៈ ដល់ក្រុមប្រឹក្សាយុវជន និងកុមារ
- បន្តអភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុកការងារយុវជន និងកុមារការងារមជ្ឈមណ្ឌល និងកាយរឹទ្ធិកម្មតាមសាលារៀន
- អភិវឌ្ឍក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលការងារយុវជន
- ពង្រីកសមាជិក កាយរឹទ្ធិ បន្ថែមទៀតនៅតាមគ្រឹះស្ថានសិក្សា

៤.១-ទិសដៅឆ្លងអនុវិស័យ

៤.២.១ ការិយាល័យសុខភាពសិក្សា

១-បន្តការអនុវត្តការសាងសង់បង្គន់អនាម័យបន្ថែមចំនួន ៨សាលាគោលដៅក្នុងឆ្នាំ ២០២៥
២-បន្តការយកចិត្តទុកដាក់លើការបណ្តុះបណ្តាលគ្រូបង្រៀនមុខវិជ្ជាអប់រំសុខភាពឱ្យបាន ៦០%
៣-បន្តការសហការជាមួយមន្ទីរសុខាភិបាលក្នុងជួយគាំទ្រដល់សាលារៀនក្នុងការផ្តល់ថ្នាំទម្លាក់ព្រូន ឱ្យបាន៨០%ទៅ៩០%នៃចំនួនសិស្សទូទាំងខេត្ត
៤-លើកកម្ពស់ការបណ្តុះបណ្តាលស្តីពីការវាស់គំហើញ និងការស្តាប់តាមគ្រឹះស្ថានសិក្សា
៥-លើកកម្ពស់ពីសុវត្ថិភាពការលក់ដូរចំណីអាហារក្នុងសាលារៀននិងបរិស្ថាន
៦-ចូលរួមសហការជាមួយមន្ទីរ ស្ថាប័ននានា ក្នុងការគាំទ្រការអប់រំផ្សព្វផ្សាយស្តីពីគ្រឿងញៀន គ្រឿង

ស្រវឹងគ្រប់ប្រភេទនៅតាមគ្រឹះស្ថានសិក្សាទូទាំងខេត្ត

៧-បន្តអនុវត្តកម្មវិធីចាក់វ៉ាក់សាំងការពារគ្រប់ប្រភេទ

៨-ពង្រឹងការទប់ស្កាត់ ការជួញដូរ និងការប្រើប្រាស់ បារីអេឡិចត្រូនិកក្នុងគ្រឹះស្ថានសិក្សា

៤.២.២ ការិយាល័យរដ្ឋបាល .បុគ្គលិក និងបណ្តុះបណ្តាល

៤.២.២.១៖ការងាររដ្ឋបាល

១-រៀបចំលិខិត និងឯកសារផ្សេង ៗ ទុកដាក់ទៅតាមឆ្នាំនីមួយៗ

២-រៀបចំទិវាគ្រូបង្រៀន ៥តុលា

៣-ស្នើសុំគ្រឿងឥស្សរយសការងារជូនបុគ្គលិកអប់រំ

៤-ស្នើសុំទង់ជ័យលាភី និងប័ណ្ណសរសើរ សម្រាប់អង្គភាពដែលមានស្នាដៃល្អ

៤.២.២.២៖ការងារបុគ្គលិក

១-បញ្ចូលបុគ្គលិកចេញថ្មីទៅបើកប្រាក់បៀវត្សនៅធនាគារអេស៊ីលីដាបាន១០០%

២-រៀបចំបញ្ចូលប្រាក់តំបន់ដាច់ស្រយាលទៅក្នុងតារាងព័ត៌មានវិទ្យា

៣-កែតម្រូវស្ថានភាពប្រែប្រួលបុគ្គលិកអប់រំទៅក្នុងតារាងព័ត៌មានវិទ្យាជារៀងរាល់ខែ

៤-តែងតាំងមន្ត្រីគ្រប់គ្រងចាប់ពីអនុប្រធានការិយាល័យ និងនាយកនាយរងសាលាកម្រិតមធ្យមសិក្សា

៥-ស្នើសុំដំឡើងថ្នាក់ជូនមន្ត្រីអប់រំ យុវជន និង កីឡា ចំនួន ២២៩ នាក់

៦-ស្នើសុំតែងតាំងស៊ប់ជូនមន្ត្រីកម្មសិក្សា គ្រប់កម្រិតសិក្សា ១២ នាក់

៧-បញ្ចូលទិន្នន័យបុគ្គលិកថ្មីទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា ៤៣ នាក់

៨-ស្នើសុំប្រើប្រាស់គ្រូបង្រៀនថ្នាក់គួប២កម្រិត៣កម្រិតទៅតាមតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថានសិក្សា

៩-ស្នើសុំប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាចំណេះទូទៅស្ថានភាពជាក់ស្តែង

១០-ស្នើសុំប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាចំនួន ០៨នាក់

១១-បំប៉នសមត្ថភាពមន្ត្រីអប់រំក្រុង/ស្រុក និងនាយក ស្តីពីប្រសិទ្ធិភាពនៃការគ្រប់គ្រងធនធានមនុស្ស

១២-បញ្ចូលព័ត៌មានគ្រូចេញថ្មី និងធ្វើបច្ចុប្បន្នភាពបុគ្គលិកអប់រំទូទាំងខេត្ត ក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស

៤.២.៣ ការិយាល័យគណនេយ្យ សម្ភារ និងទ្រព្យសម្បត្តិរដ្ឋ

១-សម្ភារសម្អាត និងអនាម័យ អនុវត្តឱ្យបាន ១០០% (ដំណើរការក្នុងការិយាល័យ)

២-ប្រេងឥន្ធនៈ និងប្រេងរំអិល អនុវត្តឱ្យបាន ១០០% (ដំណើរការសម្រាប់អង្គភាពទាំងមូល)

៣-សម្ភារការិយាល័យ អនុវត្តឱ្យបាន ១០០% (ដំណើរការក្នុងការិយាល័យ)

៤-ស្បៀងសម្រាប់ការងាររដ្ឋបាលអនុវត្តឱ្យបាន១០០%(ដំណើរការក្នុងការិយាល័យ និងមន្ទីរទាំងមូល)

៥-សម្ភារ និងបរិក្ខាបច្ចេកទេសមិនមែនព័ត៌មានវិទ្យាអនុវត្តឱ្យបាន ១០០% (ដំណើរការសម្រាប់អង្គភាពទាំងមូល)

៦-សង្ហារឹម អនុវត្តឱ្យបាន ១០០% ១-ផ្តត់ផ្តង់តុ-កៅអីសិស្សអង្គុយពីរនាក់មតេ្តយ្យសិក្សាចំនួន១៥០គ្រឿង ២-តុ-កៅអីសិស្សអង្គុយពីរនាក់បឋមសិក្សាចំនួន២០០គ្រឿង ៣-តុ-កៅអីសិស្សអង្គុយពីរនាក់មធ្យមសិក្សាចំនួន១៥០គ្រឿង ៣-ក្តារខៀនកុងផ្លាកកេសរសេរសងខាងចំនួន១០ផ្ទាំង និងផ្សេងៗទៀត ។ (សម្រាប់ដំណើរការអង្គភាពទូទាំងខេត្ត)

៧-សម្ភារប្រើប្រាស់ អនុវត្តឱ្យបាន ១០០ % (ដំណើរការក្នុងការិយាល័យ)

៨-សម្ភារនិងបរិក្ខាបច្ចេកទេសព័ត៌មានវិទ្យាអនុវត្តបានឱ្យ១០០% (ដំណើរការសម្រាប់អង្គភាពទាំងមូល)

៩-អគ្គិសនី អនុវត្តឱ្យបាន ១០០% (ដំណើរការសម្រាប់អង្គភាពទាំងមូល)

១០-ទឹក អនុវត្តឱ្យបាន ១០០% (ដំណើរការសម្រាប់អង្គភាពទាំងមូល)

១១-ជួសជុលមធ្យោបាយដឹកជញ្ជូនអនុវត្តឱ្យបាន១០០% (ដំណើរការសម្រាប់អង្គភាពទាំងមូល)

១២-ជួសជុលអគារ និងប្រាសាទ អនុវត្តឱ្យបាន ១០០% (១-ជួសជុលសួនច្បារមុខសាលាបឋមសិក្សាហ៊ុន សែន សែនមនោរម្យ ២-ជួសជុលរំដោះទឹកលានបាល់ទាត់ និងដាំស្មៅកែលម្អរទីលានតារាងបាល់ទាត់ស្ថិតនៅភូមិកណ្តាល ស្ពានមានជ័យ សែនមនោរម្យ ខេតមណ្ឌលគិរី ៣-ជួសជុលអគារសិក្សា១ខ្នង ចំនួន៥បន្ទប់ សាលាបឋមសិក្សាស្រែក្លែង ឃុំប៊ូស្រា ស្រុក ពេជ្រាដា ខេត្តមណ្ឌលគិរី ។

១៣-ទិញសម្ភារៈសម្រាប់សិស្សអន្តេវាសិកដ្ឋានខេត្ត និងសិស្សស្នាក់នៅក្នុងអន្តតាមស្រុកអនុវត្តឱ្យបាន ៩៩%(មានសម្ភារៈសិក្សានិងសម្ភារៈដំណេកនិងសម្ភារប្រើប្រាស់ផ្សេងៗទៀតចែកសិស្សកំពុងសិក្សា)

១៤-ចុះណែនាំដល់សាលាក្នុងការធ្វើរបាយការណ៍ចំណាយថវិកា កិច្ចបញ្ជីការ ទាំង៦ រៀបចំគណៈកម្មការសាលា និងផែនការផ្សេងៗ សម្រាប់សាលា អនុវត្តឱ្យបានច្រើនសាលា និង៥ ក្រុង/ស្រុក។

១៥-បើកវគ្គបំប៉នកិច្ចបញ្ជិកាគណនេយ្យដល់នាយក ហិរញ្ញិកសាលា និងការិយាល័យអប់រំ ក្រុង/ស្រុក និងការិ.មន្ទីរឱ្យបានគ្រប់សាលា ដោយប្រមូលផ្តុំនៅតាមស្រុក។

៤.២.៤ ការិយាល័យផែនការ និងគ្រប់គ្រងថវិកា

៤.២.៤.១៖ការងារសៀវភៅសិក្សា និងបណ្ណាល័យ

១-បំប៉នសមត្ថភាពមន្ត្រីអប់រំក្រុង/ស្រុក និងនាយកសាលារៀន ស្តីពីការគ្រប់គ្រង ប្រើប្រាស់ បែងចែក និងធ្វើផែនការតម្រូវការសៀវភៅសិក្សាគោលឆ្នាំសិក្សា២០២៥-២០២៦ តាមប្រព័ន្ធ TNT

២-ពិនិត្យតាមដាន លើការប្រើប្រាស់ គ្រប់គ្រង បែងចែក និងការប្រមូលសៀវភៅសិក្សាគោលប្រចាំឆ្នាំ

៣-សម្របសម្រួលការបែងចែក និងដឹកជញ្ជូនសៀវភៅសិក្សាទៅតាមសាលារៀនគ្រប់កម្រិតសិក្សា

៤-ណែនាំឱ្យនាយកសាលារៀនគ្រប់កម្រិតសិក្សាធ្វើផែនការតម្រូវការសៀវភៅសិក្សាគោលប្រចាំឆ្នាំ ២០២៥-២០២៦ តាមប្រព័ន្ធTNT

៥-សម្របសម្រួល ក្នុងការបែងចែកសៀវភៅសិក្សាគោលដែលទទួលបានពីគ្រឹះស្ថានបោះពុម្ពទៅដល់សាលារៀនគ្រប់កម្រិតសិក្សាឱ្យទាន់ពេលវេលា

៤.២.៤.២៖ការងារផែនការ

១-សម្របសម្រួលរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២៦ របស់ការិយាល័យទាំង ៩ក្នុងមន្ទីរ និងការិយាល័យអប់រំយុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុក ទាំង៥ ក្រុង/ស្រុក

២-សម្របសម្រួល និងណែនាំ ស្តីពីការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៥ ដល់សាលាបឋមសិក្សា ចំនួន ៩១សាលា -មត្តេយ្យសិក្សាដាច់ ៤សាលា និងមធ្យមសិក្សា ១៥សាលា ដែលមានពិន្ទុចាប់ពី ៨៥% ឡើង

៣-សម្របសម្រួល សហការក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា២០២៦-២០២៨

៤-សម្របសម្រួល និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨ ដល់អ្នកពាក់ព័ន្ធ នៅពេលសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២៣-២០២៤

៥-ធ្វើបច្ចុប្បន្នភាពក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ និងប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំចំនួន ៣ ដង ក្នុងមួយឆ្នាំ

៦-សម្របសម្រួលជាមួយការិយាល័យជំនាញក្នុងមន្ទីរ ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំសិក្សា២០២៥-២០២៦

៧-ចូលរួមរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបសមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលខេត្ត

៨-បញ្ចូលសកម្មភាពហិរញ្ញប្បទានសហប្រតិបត្តិរបស់ដៃគូទៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញប្បទាន AMIS

៩-ពិនិត្យតាមដាន និងណែនាំដល់នាយក នាយិកាសាលាលើការរៀបចំផែនការសាលារៀនគ្រប់កម្រិតសិក្សា ពិសេសសាលារៀនគោលដៅ ដែលត្រូវវាយតម្លៃជាស្តង់ដាលារៀនគំរូ

៤.២.៤.៣៖ការងារប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

១-បែងចែក ប្រមូល ពិនិត្យផ្ទៀងផ្ទាត់ តារាងស្រង់ពិន្ទុសិស្សតាមមុខវិជ្ជាប្រចាំឆ្នាំសិក្សា២០២៤-២០២៥ និងបញ្ចូលទិន្នន័យទៅក្នុប្រព័ន្ធ EMIS

២-បែងចែក ប្រមូល ពិនិត្យផ្ទៀងផ្ទាត់ តារាងជំរឿនស្ថិតិសាលារៀនប្រចាំឆ្នាំសិក្សា២០២៥-២០២៦និងបញ្ចូលទិន្នន័យទៅក្នុប្រព័ន្ធ EMIS

៣-បែងចែក ប្រមូល ពិនិត្យផ្ទៀងផ្ទាត់ តារាងបម្រែបម្រួលអាកាសធាតុតាមសាលាប្រចាំឆ្នាំសិក្សា ២០២៤-២០២៥ និងបញ្ចូលទិន្នន័យទៅក្នុប្រព័ន្ធ EMIS

៤-បែងចែក ប្រមូល ពិនិត្យផ្ទៀងផ្ទាត់ កម្រងសំណួរសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃស្ថានភាពទឹកស្អាត និងបង្គន់អនាម័យ នៅតាមសាលារៀនប្រចាំឆ្នាំសិក្សា២០២៥-២០២៦ និងបញ្ចូលទិន្នន័យទៅក្នុប្រព័ន្ធ EMIS

៥-ចងក្រងស្ថិតិអប់រំ និងសូចនាករអប់រំសម្រាប់ប្រើប្រាស់ដល់អ្នកពាក់ព័ន្ធ

៦-រៀបចំ និងបោះពុម្ពប័ណ្ណផ្ទៃព័ត៌មានសម្រាប់វិស័យអប់រំយុវជន និងកីឡាប្រចាំឆ្នាំ២០២៤-២០២៥

៧-ពិនិត្យតាមដាន និងណែនាំលើការងារប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ នៅតាមសាលារៀនសាធារណៈ (សាលាបឋមសិក្សា ១៥ និងមធ្យមសិក្សា ៨សាលា)

៨-បើកវគ្គបំប៉ងសមត្ថភាពដល់នាយក នាយិកាសាលា លើការងារប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

៩-ចុះគាំទ្របច្ចេកទេសដល់សាលារៀនគោលដៅ ដែលត្រូវវាយតម្លៃជាស្តង់ដាលារៀនគំរូ (មត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា លើការងារសូចនាករសាលារៀន)

៤.២.៤.៤៖ការងារពិនិត្យតាមដាន និងវាយតម្លៃ

១-រៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ឱ្យបានទាន់ពេលវេលា

២-ពិនិត្យតាមដានណែនាំ ស្តីពីការរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំនៅសាលាបឋមសិក្សាចំនួ ១០សាលា និងមធ្យមសិក្សាចំនួន ៥សាលា

៣-សម្របសម្រួលការរៀបចំរបាយការណ៍សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២៤-២០២៥ និង លើកទិសដៅការងារសម្រាប់អនុវត្តបន្តឆ្នាំសិក្សា២០២៥-២០២៦

៤.២.៥ ការិយាល័យអធិការកិច្ច

១-ពង្រឹងយន្តការអធិការកិច្ច តាមកាលកំណត់ឱ្យសម្រេចតាមផែនការ

២-ចុះគាំទ្រស្តង់ដាសាលារៀនគំរូដល់សាលាគោលដៅ

៣-ត្រៀមអនុវត្តតេស្តអំណាន និងគណិតវិទ្យាថ្នាក់ដំបូង

៤-ត្រៀមធ្វើតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ នៅថ្នាក់ទី៣. ទី៦. ទី៨. និងទី១១

៥-ត្រៀមធ្វើតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់តំបន់អាស៊ីអាគ្នេយ៍(SEA-PLM)ថ្នាក់ទី៥

៦-ត្រៀមធ្វើតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់អន្តរជាតិ(PISA) លើសិស្សអាយុ១៥ឆ្នាំ នៅកម្រិតមធ្យមសិក្សា

៥.សេចក្តីសន្និដ្ឋាន

លទ្ធផលដែលសម្រេចបានខាងលើនេះ គឺអាស្រ័យដោយមានការខិតខំប្រឹងប្រែងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ និងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ សកម្មភាពអាទិភាព លិខិតបទដ្ឋានគតិយុត្តិដែលដាក់ចេញដោយក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយនឹងកិច្ចខិតខំប្រឹងប្រែងពី បុគ្គលិកអប់រំគ្រប់ថ្នាក់ ព្រមទាំងការចូលរួមគាំទ្ររបស់សហគមន៍ សប្បុរសជន អាជ្ញាធរដែនដី និងពិសេស ការឧបត្ថម្ភគាំទ្រយ៉ាងពេញទំហឹងពីអង្គការជាតិ អន្តរជាតិ និងអង្គការដៃគូក្នុងខេត្តយើងសម្រេចបាននូវលទ្ធផលសំខាន់ៗ ស្របតាមទិសដៅដែលបានដាក់សម្រាប់អនុវត្តអនុវិស័យនីមួយ ៗ និងមានកិច្ចគាំទ្រពីការិយាល័យជំនាញ។ ការពង្រីកសេវាអប់រំចាប់ពីកម្រិតមត្តេយ្យសិក្សា ដល់ មធ្យមសិក្សាបានទូលំទូលាយ គ្រប់ច្រកល្ហក ពិសេសមានថ្នាក់ មត្តេយ្យសិក្សារដ្ឋគ្រប់ឃុំ សង្កាត់ មានសេវាអប់រំកម្រិតមូលដ្ឋាននៅគ្រប់ឃុំ សង្កាត់ និងសេវាអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិនៅគ្រប់ស្រុក ក្រុង។ ឆ្នាំសិក្សានេះ អគារសិក្សា បន្ទប់រៀន ហេដ្ឋារចនា សម្ព័ន្ធ សម្ភារូបវន្តអប់រំ បរិស្ថានសិក្សាទាំងក្នុងថ្នាក់រៀននិងក្រៅថ្នាក់ ព្រមទាំង

សមត្ថភាពគ្រូបង្រៀនត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ សកម្មភាពយុវជនមានភាពផុលផុស កីឡាសិស្ស និងកីឡាមហាជនកាន់តែរីកចម្រើន ៕

តារាងទី១ ៖ ទស្សនភាពនៃការសម្រេចបានសូចនាករស្នូល

សូចនាករ		ឯកតា	ឆ្នាំគោល	ចំណុចដៅ	ជាក់ស្តែង	ស្ថានភាព
			2023-24	2024-25	2024-25	
គោលនយោបាយទី ១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា						
១.	អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ *(ម.សិក្សាធ្លុ សហគមន៍ និងឯកជន)*	%	43.8	50.4	54.1	↑
	ប្រុស	%	44.2	52.0	51.5	↑
	ស្រី	%	43.5	48.5	56.8	↑
	អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា	%	99.5	99.5	92.5	↓
	ប្រុស	%	93.5	94.5	83.1	↓
	ស្រី	%	106.5	102.0	103.1	↑
	អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ	%	46.8	47.5	53.5	↑
	ប្រុស	%	43.5	44.4	62.0	↑
	ស្រី	%	50.3	53.0	45.5	↓
	ចំនួនស្រុកដែលសម្រេចអត្រាបញ្ចប់ការសិក្សាបឋសិក្សា ៨០ភាគរយ	ចំនួន	3/5	3/5	3/5	→
	ចំនួនស្រុកបានសម្រេចអត្រាបញ្ចប់បឋមភូមិយ៉ាងតិច ៤០ ភាគរយ	ចំនួន	2/5	3/5	3/5	↑
	អត្រាអក្ខរកម្មពេញវ័យ(អាយុ ១៥-៤៥)	%	73.9	74.0	74.0	→
	ភាគរយគ្រូបង្រៀនបឋមសិក្សាមានសញ្ញាបត្រទុតិយភូមិ ១២+២	%	81.4	85.0	81.4	→
	ភាគរយគ្រូបង្រៀនមធ្យមសិក្សាមានសញ្ញាបត្រទុតិយភូមិ ១២+២	%	100	100	100	→
គោលនយោបាយទី២ ពង្រឹងស្ថាប័ន ដើម្បីធានាភាពស័ក្តសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់						
	ភាគរយនាយកមធ្យមសិក្សាបានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន	%	66.0	72.8	66	→
	ភាគរយនៃការទូទាត់ថវិកា	%	90	98		↓

សម្គាល់៖ ↑ សម្រេចបានតាមចំណុចដៅ ➔អាចទទួលយកបាន ↓សម្រេចមិនបានតាមចំណុចដៅ

ឧបសម្ព័ន្ធ២ ៖ វឌ្ឍនភាពនៃការសម្រេចបានសូចនាករអនុវិស័យ

១.អនុវិស័យ ការអប់រំកុមារតូច

សូចនាករ		ឯកតា	ឆ្នាំគោល	ចំណុចដៅ	ជាក់ស្តែង	ស្ថានភាព
			2023-24	2024-25	2024-25	
គោលនយោបាយទី ១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា						
វត្ថុបំណងអនុវិស័យទី១ ៖ បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន						
១.	អត្រាចូលរៀនកុមារអាយុ ៣-៥ឆ្នាំ (ម.សិក្សាវដ្ដ សហគមន៍ និងឯកជន)	%	33.1	33.5	38.1	↑
	ប្រុស	%	32.3	33.5%	37.4	↑
	ស្រី	%	33.9	34.5	38.7	↑
២.	*អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ (ម.សិក្សាវដ្ដ សហគមន៍ និងឯកជន)*	%	43.8	45.9	54.1	↑
	ប្រុស	%	44.2	46.7	51.5	↑
	ស្រី	%	34.5	37.1	56.8	↑
៣.	*អត្រាចូលរៀនកុមារអាយុ៤ឆ្នាំ (ម.សិក្សាវដ្ដ សហគមន៍ និងឯកជន)*	%	38.7	40.2	47.2	↑
	ប្រុស	%	37.6	39.2	42.6	↑
	ស្រី	%	39.9	41.2	51.7	↑
៤.	*អត្រាចូលរៀនកុមារអាយុ៣ឆ្នាំ(ម.សិក្សាវដ្ដ សហគមន៍ និងឯកជន)*	%	16.7	17.4	16.2	➔
	ប្រុស	%	15.1	16.5	16.3	↑
	ស្រី	%	18.4	20.2	16.0	↓
៥.	*អត្រារួមនៃការសិក្សា(ម.សិក្សាវដ្ដ សហគមន៍ និងឯកជន)*	%	33.1	34.9	38.1	↑
	ប្រុស	%	32.3	33.5	37.4	↑
	ស្រី	%	33.9	34.2	38.7	↑
៦.	ភាគរយសាលាមត្តេយ្យសិក្សាមានអគ្គិសនី *(មត្តេយ្យវដ្ដ)*	%	100	100	100	➔

៧.	ភាគរយសាលាមត្តេយ្យសិក្សាមានកន្លែងលាងសម្អាតដៃស្តង់ដាអប្បបរមា *(ម.សិក្សារដ្ឋដាច់ដោយឡែក)*					
	កម្រិត ១	%	50	50	50	➔
	កម្រិត ២	%	50	30	50	↑
	កម្រិត ៣	%	0	20	0	➔
៨.	ភាគរយសាលាមត្តេយ្យសិក្សាមាន *(ម.សិក្សារដ្ឋដាច់ដោយឡែក)*					
	បង្គន់អនាម័យ	%	100	100	100	➔
	ទឹកស្អាតសម្រាប់ទទួលទាន	%	100	100	100	➔
	កន្លែងលាងដៃ	%	100	100	100	➔
	ប្រអប់សង្គ្រោះបឋម	%	100	100	100	➔
វត្ថុបំណងអនុវិស័យទី២ ៖ លើកកម្ពស់គុណភាពសាលាមត្តេយ្យសិក្សាស្របតាមស្តង់ដា						
៩.	ភាគរយសាលាមត្តេយ្យសិក្សារដ្ឋ សម្រេចបានតាមស្តង់ដាអប្បបរមា *(ម.សិក្សារដ្ឋដាច់ដោយឡែក)*	%	4/4	4/4	4/4	➔
១០.	ភាគរយសាលាមត្តេយ្យសិក្សាសហគមន៍សម្រេចបានតាមស្តង់ដាអប្បបរមា	ចំនួន	16.3	16.3	16.3	➔
១១.	ភាគរយសាលាមត្តេយ្យសិក្សារដ្ឋ និងសហគមន៍បានធ្វើតេស្តសមត្ថភាពកុមារអាយុ៥ឆ្នាំ	%	68.3	70.0	70	↑
១២.	ភាគរយកុមារសាលាមត្តេយ្យសិក្សាបានទទួលអាហារូបត្តម្ភ *(ម.សិក្សារដ្ឋ សហគមន៍ និងឯកជន)*	%	0	0	0	➔
១៣.	ភាគរយគ្រូមត្តេយ្យសិក្សាមានគុណវុឌ្ឍិស្របតាម ស្តង់ដាជាតិ (រូបមន្ត១២+២)	%	72.6	73.0	72.6	↑
១៤.	ចំនួនគ្រូបង្រៀនពហុភាសា	ចំនួន	12	12	12	➔
១៥.	ផលធៀបសិស្ស-គ្រូមត្តេយ្យសិក្សារដ្ឋ	ផលធៀប	33.5	27.6	33.5	↑
គោលនយោបាយទី២៖ពង្រឹងស្ថាប័ន ដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់						
វត្ថុបំណងអនុវិស័យទី៣៖ ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងអនុវិស័យ ការអប់រំកុមារតូច						
១៦.	ចំនួននាយកសាលាមត្តេយ្យសិក្សារដ្ឋទទួលបានការបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងតាមសាលារៀន	ចំនួន	3/4	4/4	3/4	➔
១៧.	ចំនួនសាលាមត្តេយ្យសិក្សារដ្ឋបានអនុវត្តការគ្រប់គ្រងតាមសាលារៀន *(ម.សិក្សារដ្ឋដាច់ដោយឡែក)*	ចំនួន	4/4	4/4	4/4	↑

សម្គាល់ប: ↑ **សម្រេចបានតាមចំណុចដៅ** ➔ **អាចទទួលយកបាន** ↓ **សម្រេចមិនបានតាមចំណុចដៅ**

២. អនុវិស័យ ការអប់រំបឋមសិក្សា

	សូចនាករ	ឯកតា	ឆ្នាំគោល	ចំណុចដៅ	ជាក់ស្តែង	ស្ថានភាព
			2023-24	2024-25	2024-25	
គោលនយោបាយទី ១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា						
វត្ថុបំណងអនុវិស័យទី១ ៖ កម្ពស់ការចូលរៀនរហូតដល់ចប់ថ្នាក់ទី៦នៃបឋមសិក្សាសម្រាប់កុមារទាំងអស់ ជាពិសេសក្រុមកុមារជួបការលំបាក						
១.	អត្រាពិតចូលរៀនថ្មី	%	72.6	71.5	87.7	↑
	ប្រុស	%	72.7	66.2	88.3	↑
	ស្រី	%	72.6	76.8	87.1	↑
	អត្រារួមចូលរៀនថ្មី	%	105.9	117.2	123.3	↑
	ប្រុស	%	111.0	119.1	126.2	↑
	ស្រី	%	100.7	117.2	120.2	↑
២.	អត្រាពិតនៃការសិក្សា	%	96.0	81.6	96.3	↑
	ប្រុស	%	94.1	78.9	95.5	↑
	ស្រី	%	98.1	84.2	97.1	↑
	អត្រារួមនៃការសិក្សា	%	119.4	112.2	122.7	↓
	ប្រុស	%	119.3	110.5	122.0	↓
	ស្រី	%	119.6	113.2	123.4	↓
៣.	អត្រាបោះបង់ការសិក្សា	%	7.1	7.5	8.5	↓
	ប្រុស	%	6.0	5.0	10.1	↓
	ស្រី	%	8.0	7.3	6.9	↓
៤.	អត្រាត្រួតថ្នាក់	%	5.0	4.4	5.1	↓
	ប្រុស	%	6.8	5.7	6.5	→
	ស្រី	%	3.3	2.2	3.7	↓
៥.	ចំនួនស្រុកដែលសម្រេចបានអត្រាត្រួតថ្នាក់នៅ បឋមសិក្សា តិចជាងឬស្មើ ១០ ភាគរយ	ចំនួន	5/5	5/5	5/5	→
៦.	អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា	%	99.5	99.5	92.5	↓
	ប្រុស	%	93.2	95.4	83.1	↓
	ស្រី	%	106.5	102.0	103.1	→
៧.	អត្រាគង់វង្សនៅបឋមសិក្សា	%	71.2	72.5	67.2	↓

	ប្រុស	%	75.1	78.5	63.0	↓
	ស្រី	%	67.5	68.5	71.5	↑
៨.	អត្រាឆ្លងកូមិសិក្សាពីបឋមសិក្សាទៅ មធ្យមសិក្សាបឋមភូមិ	%	81.3	80.1	81.3	→
	ប្រុស	%	79.4	77.6	79.4	→
	ស្រី	%	83.1	82.5	83.1	→
៩.	ភាគរយសិស្សថ្មីថ្នាក់ទី១ដែលបានឆ្លងកាត់មត្តេយ្យ	%	44.5	50.0	44.5	→
	ប្រុស	%	44.6	50.0	44.6	→
	ស្រី	%	44.3	50.0	44.3	→
១០.	ភាគរយសាលាកុមារមេត្រីកម្រិត មធ្យម និងអភិវឌ្ឍ	%	82.3	75.5	82.3	→
១១.	ភាគរយសាលារៀនបឋមសិក្សាមានអគ្គិសនីប្រើប្រាស់	%	40.2	40.2	40.2	→
១២.	ភាគរយសាលារៀនបឋមសិក្សាមានស្តង់ដាទឹកស្អាត និងអនាម័យ៖					
	កម្រិត ១	%	35.2	36.0	35.5	↑
	កម្រិត ២	%	48.9	50.0	50.0	↑
	កម្រិត ៣	%	0	10.0	0	↓
១៣.	ភាគរយសាលារៀនបឋមសិក្សាមាន៖					
	បង្គន់អនាម័យ	%	98.0	100	100	↓
	ទឹកស្អាតសម្រាប់ទទួលទាន	%	70.0	75.0	80.0	↓
	កន្លែងលាងដៃ	%	100	100	100	→
	ប្រអប់សង្គ្រោះបឋម	%	100	100	100	→
១៤.	ចំនួនសិស្សបឋមសិក្សាទទួលអាហារនៅតាមសាលារៀន	ចំនួន	64	64	64	→
១៥.	ចំនួនសិស្សទទួលអាហារូបករណ៍នៅបឋមសិក្សា	ចំនួន	1.317	1.317	1.317	→
១៦.	ចំនួនគ្រូបង្រៀនពហុភាសា	ចំនួន	72	80	72	↓
១៧.	ចំនួនគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលកម្រិតឌីប្លូម៉ាស្តីពីការអប់រំពិសេសនៅវិទ្យាស្ថានអប់រំពិសេស	ចំនួន	0	0	0	→
វត្ថុបំណងអនុវិស័យទី២ ៖ កែលម្អការផ្តល់ធាតុចូលប្រកបដោយគុណភាពនៅបឋមសិក្សា						
១៨.	ផលធៀបសិស្ស-គ្រូ	ផលធៀប	26	25.5	25.5	→
១៩.	ភាគរយគ្រូបង្រៀនបឋមសិក្សាមានសញ្ញាបត្រតាមស្តង់ដា (សញ្ញាបត្រមធ្យម.ទុតិយភូមិ+២)	%	15.5	15.5	15.5	→
២០.	ចំនួនគ្រូបង្រៀនបឋមសិក្សាទទួលការបំប៉នសមត្ថភាពបន្ថែម					
	កញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង	ចំនួន	255	270	273	↑
	កញ្ចប់សម្ភារៈគណិតវិទ្យាថ្នាក់ដំបូង	ចំនួន	0	100	137	↑
	ការបំប៉នសមត្ថភាពផ្សេងទៀត	ចំនួន	0	0	0	→

២១.	ចំនួនគ្រូបង្រៀនបឋមសិក្សាដែលបានបញ្ចប់បរិញ្ញាបត្រ នៅ វិ.គរុកោសល្យ (១២+៤)	ចំនួន	2	1	2	↑
២២.	ភាគរយសិស្សបឋមសិក្សាទទួលបានសៀវភៅសិក្សាគោល ១ សម្រាប់ក្នុងម្នាក់	%	100	100	100	→
២៣.	ចំនួនសាលាបឋមសិក្សាមានបន្ទប់កុំព្យូទ័រសម្រាប់សិស្ស	ចំនួន	0	0	0	→
២៤.	ចំនួនសាលាបឋមសិក្សាមានបណ្ណាល័យតាមស្តង់ដា	ចំនួន	1	1	1	→
២៥.	ចំនួនសាលាបឋមសិក្សាអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនមានផ្ទះបាយ និងកន្លែងទទួលទានអាហារតាមស្តង់ដា	ចំនួន	0	5	0	↓
គោលនយោបាយទី២៖ពង្រឹងស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់						
វត្ថុបំណងអនុវិស័យទី៣៖ ពង្រឹងការអនុវត្តស្តង់ដាបឋមសិក្សាតាមរយៈការគ្រប់គ្រងសាលារៀន						
២៦.	ចំនួននាយកបឋមសិក្សាបានទទួលការបំប៉នស្តីពីការគ្រប់គ្រងតាមសាលារៀន	ចំនួន	89	95	89	↑
២៧.	ចំនួនសាលាបឋមអនុវត្តកម្មវិធីការគ្រប់គ្រងសាលារៀន	ចំនួន	39	39	39	→

សម្គាល់ប: ↑ **សម្រេចបានតាមចំណុចដៅ** → **អាចទទួលយកបាន** ↓ **សម្រេចមិនបានតាមចំណុចដៅ**

៣. អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

សូចនាករ	ឯកតា	ឆ្នាំគោល	ចំណុចដៅ	ជាក់ស្តែង	ស្ថានភាព
		2023-24	2024-25	2024-25	
គោលនយោបាយទី ១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា					
វត្ថុបំណងអនុវិស័យទី១ ៖ កែលម្អការចូលរៀននិងរក្សាសិស្សឱ្យបានគង់វង្ស ប្រកបដោយសមធម៌ និងបរិយាបន្ននៅមធ្យមសិក្សា					
១. អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ	%	56.9	57.6	66.6	↑
ប្រុស	%	51.6	54.3	60.8	↑
ស្រី	%	62.7	64.5	72.6	↑
២. អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ	%	36.1	38.3	38.0	↑
ប្រុស	%	31.8	32.0	33.7	↑
ស្រី	%	40.5	41.0	42.5	↑
៣. អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅទុតិយភូមិ	%	83.1	86.9	83.1	→
ប្រុស	%	77.9	86.4	77.9	→
ស្រី	%	87.2	87.3	87.2	→

៤.	អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ	%	46.8	48.0	53.5	↑
	ប្រុស	%	43.5	42.0	45.5	↑
	ស្រី	%	50.3	55.2	62.0	↑
៥.	អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ	%	12.1	11.1	13.3	↓
	ប្រុស	%	14.0	12.7	13.2	→
